ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

## ˝ ទស្សនៈយល់ឃើញរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យសិក្សាអាយុ បី បួន និងប្រាំឆ្នាំ˝

## (ករណីសិក្សាៈ សាលាមត្តេយ្យ ៨ មីនា នៅរាជធានីភ្នំពេញ)

## Parent΄s perspectives on sending children to attend preschool from 3 to 5 years

## Case Study : 8 March Kindergarten in Phnom Penh


**ដោយ / By**

**ហៃយ ចម្លង**

**HAY CHAMLANG**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧-២០១៨


ឧបត្ថម្ភដោយ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

ឧបត្ថមដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

**ក្រសួងអប់រំ យុវជន និងកីឡា**

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ″ ទស្សនៈយល់ឃើញរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យសិក្សាអាយុ បី បួន និងប្រាំឆ្នាំ″

**( ករណីសិក្សា៖ សាលាមត្តេយ្យ ៨ មីនា នៅរាជធានីភ្នំពេញ )**

Parent′s perspectives on sending children to attend preschool from 3 to 5 years

Case Study : 8 March Kindergarten in Phnom Penh

**ដោយ / By**

**ហៃយ ចម្លង**

**HAY CHAMLANG**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំ៖** **ឯកឧត្តមបណ្ឌិត ស៊ិន សេងហុក**

**សាស្ត្រាចារ្យដឹកនាំរង៖** **លោក លុយ អោក**

**ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៦២៥ **អយក.** វក

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម ទៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត នី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី ដោ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។ ៗ

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

# **សេចក្តីអះអាងរបស់បេក្ខជន**

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ទស្សនយល់ឃើញរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យសិក្សាអាយុបី បួន និងប្រាំឆ្នាំ (មត្តេយ្យសិក្សារដ្ឋ ៨មីនា ករណីសិក្សានៅភ្នំពេញ)**" សម្រាប់បំពេញ លក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

**ហត្ថលេខា**

**ហៃយ ចម្លង**

# លិខិតបញ្ជាក់

| | |
|---|---|
| ឯកឧត្តមបណ្ឌិត ស៊ិន សេងហុក | ជាសាស្ត្រាចារ្យដឹកនាំ |
| លោក លុយ អោក | ជាសាស្ត្រាចារ្យដឹកនាំរង |

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោកស្រី **ហៃយ ចម្លង** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ទស្សនយល់ឃើញរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យសិក្សាអាយុបី បួន និងប្រាំឆ្នាំ (មត្តេយ្យសិក្សារដ្ឋ ៨មីនា ករណីសិក្សានៅភ្នំពេញ)** "ពិតប្រាកដមែន។

ថ្ងៃ.................ខែ.................ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...............ខែ...............ឆ្នាំ២០១៩

| ...................................... | ...................................... |
|---|---|
| **បណ្ឌិត ស៊ិន សេងហុក** | **លោក លុយ អោក** |
| ប្រធាននាយកដ្ឋាននីតិកម្ម | សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា Cambodia International Education Support Foundation (CIESF) ដែលបានរៀបចំ និងផ្តល់អាហារូបករណ៍ដល់នាងខ្ញុំបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

នាងខ្ញុំសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ **ឯកឧត្តមបណ្ឌិត ស៊ិន សេងហុក** ដែលតែងតែចំណាយពេលវេលាមកពន្យល់ខ្ញុំបាទគ្រប់ជំហានទើបធ្វើឲ្យការស្រាវជ្រាវរបស់នាងខ្ញុំនាពេលនេះទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរខ្ញុំក៏សូមដល់លោកសាស្ត្រាចារ្យជំនួយ **លុយ អេង** និងមិត្តរួមជំនាន់ទី៦ទាំងអស់ដែលតែងតែផ្តល់ជាគំនិតល្អៗ និងកម្លាំងចិត្ត តាមរយៈការចែករំលែក ចំណេះដឹង បទពិសោធន៍ ព័ត៌មានទាំងឡាយដល់រូបនាងខ្ញុំ ដើម្បីឲ្យការស្រាវជ្រាវនេះមានភាពងាយស្រួល។

បន្ថែមពីនេះទៀតនាងខ្ញុំសូមថ្លែងអំណរគុណដល់ លោកឪពុក អ្នកម្តាយ បងប្អូន និងស្វាមីរបស់នាងខ្ញុំ ដែលបានផ្តល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញ និងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវការថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។

ជាទីបញ្ចប់នាងខ្ញុំសូមប្រសិទ្ធិពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ និងស្វាមីនាងខ្ញុំឲ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**

# មូលន័យសង្ខេប

ការអភិវឌ្ឍធនធានមនុស្សជាមូលធននិរន្តរភាពដែលមានសារៈសំខាន់ខ្លាំងរបស់ប្រទេសកម្ពុជា ដែលមានក្រសួងអប់រំ យុវជន និងកីឡា ខិតខំធ្វើការកំណែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជាអោយមានគុណភាពក្នុងនោះក៏មានការចូលរួមសហការជាមួយនាយកដ្ឋានអប់រំកុមារតូច ដែលមានគោលនយោបាយស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចសហការជាមួយ ១០ ក្រសួងផ្តោតលើការយកចិត្តទុកដាក់កុមារចាប់ពីចាប់កំណើតដល់ក្រោម ៦ ឆ្នាំ ពិសេសគ្រួសារក្រីក្រ ជនជាតិភាគតិច និងកុមារពិការភាព ផ្តោតលើសេវាបួនគឺ មត្តេយ្យសិក្សារដ្ឋ ឯកជន សហគមន៍ និងកម្មវិធីអប់រំមាតាបិតាតាមផ្ទះ ដែលមានការសហការនិងចូលរួមពីអាណាព្យាបាលមាតាបិតាផងដែរ។រីឯការស្រាវជ្រាវលើប្រធានបទ"**ទស្សនៈយល់ឃើញរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យសិក្សាអាយុបី បួន ប្រាំឆ្នាំ**" នៅសាលាមត្តេយ្យ ៨មីនារាជធានីភ្នំពេញ ក្នុងគោលបំណងរកអោយឃើញពីមូលហេតុអ្វីបានជាបញ្ជូនកូនតូចៗចូលរៀននៅសាលាមត្តេយ្យ ៨ មីនានោះ។

តាមការស្រាវជ្រាវបានបង្ហាញអោយឃើញថាមាតាបិតារបស់កុមារដែលបានសម្ភាសន៍នៅសាលាមត្តេយ្យ ៨ មីនាទាំង ១០១ នាក់ មានស្រី ៦២ នាក់ដែលមានមុខរបរខុសគ្នាបានយល់ពីតួនាទី និងភារកិច្ចរបស់ខ្លួនច្បាស់ដោយផ្តោតលើចំណេះដឹង សុវត្ថិភាព ព្រមទាំងការយកចិត្តទុកដាក់ពីលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលាធ្វើអោយពួកគាត់មានទំនុកចិត្ត ក្នុងការបញ្ជូនកូនមករៀននៅសាលានេះផងដែរ ដើម្បីត្រៀមចូលរៀននៅបឋមសិក្សា។

សរុបមកទស្សនៈយល់ឃើញរបស់មាតាបិតា ក្នុងការបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យ ៨ មីនា មានលទ្ធផលកម្រិតខ្ពស់ក្នុងលក្ខណៈវិនិច្ឆ័យដូចជា តួនាទីនិងភារកិច្ចរបស់ឪពុកម្តាយ ការទទួលចំណេះដឹង សុវត្ថិភាព និងពេលទំនេរ ថែមទាំងយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូនពួកគាត់ សំខាន់ពួកគាត់យល់ច្បាស់ពីគុណតម្លៃរបស់សាលាមត្តេយ្យ ៨ មីនានេះតែម្តង ដែលជាចំណុចល្អសម្រាប់អភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

# Abstract

The development of the country's most important human capital, the Ministry of Education, Youth and Sport, seeks to reform the quality of education system in Cambodia, in cooperation with the Department of Early Education. Early Childhood Care and Development, in collaboration with ten ministries, focuses on caring for children from birth to the age of six, especially for poor families, minorities and children with disabilities, the four services are public, private, community, and parental education programs that are run by parents and guardians. The research on the topic "Parent's perception of sending children to preschool three four and five years old." In the March 8$^{th}$ Kindergarten, Phnom Penh, with the purpose of finding out why parents take the kids to attend Brambei Minea .

Research shows that the parents of all 101 Brambei Minea, which have32 females, who has different occupations show that they understood their roles and responsibilities clearly with a focus on knowledge safety, with the attention from teachers, the school board, it gives the parents trust to send their children to school for getting ready to attend elementary school.

In short, parent's perception of sending children to study at Brambei Minea Preschool have a high level of result in criteril such as The roles of parents,the acquisition of the knowledge,safety,free time,and pay more attention on childrent's education.More importantly,thy are well aware of the value of Brambei Minea.which as a good point for development education sector in cambodin.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........ i
លិខិតបញ្ជាក់ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
មូលន័យសង្ខេប ........ iv
Abstract ........ v
មាតិកា ........ vi
បញ្ជីតារាង ........ viii

ជំពូកទី១

សេចក្តីផ្តើម

១.១ លំនាំបញ្ហា ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ៣
១.៤ សំណួរស្រាវជ្រាវ ........ ៤
១.៥ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៤

ជំពូកទី២

រំលឹកទ្រឹស្តី

២.១ ពន្យល់ពាក្យគន្លឹះ ........ ៥
២.២ ស្ថានភាពទូទៅ ........ ៦
២.៣ ស្ថានភាពនៃការអប់រំនៅប្រទេសកម្ពុជាបច្ចុប្បន្ន ........ ៩
២.៤ ទស្សនៈអប់រំសំខាន់ ........ ១១
២.៤.១ សូក្រាត ........ ១១
២.៤.២ ប្លាតុង ........ ១២
២.៤.៣ អារីស្តូត ........ ១៤
២.៤.៤ ចន ដេវី ........ ១៦
២.៤.៥ ម៉ុន តេសូរី ........ ១៨
២.៤.៦ គោលនយោបាយអប់រំ ........ ១៩
២.៤.៧ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨ ........ ១៩
២.៤.៨ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ ២១

២.៤.៩ ផែនការអភិវឌ្ឍជាតិវិស័យអប់រំ......២២
២.៥ អំពីសាលាមត្តេយ្យសិក្សា៨មីនា......២២
២.៦ សាលាមត្តេយ្យសិក្សារដ្ឋល្អ......២៣

## ជំពូកទី៣

## វិធីសាស្ត្រស្រាវជ្រាវ

៣.១ វិធីសាស្ត្រស្រាវជ្រាវ......២៨
៣.២ ទីតាំងនៃការស្រាវជ្រាវ......២៨
៣.៣ ឧបករណ៍ស្រាវជ្រាវក្នុងការប្រមូលទិន្នន័យ......២៩
៣.៤ ការកំណត់ភាគសំណាកក្នុងការប្រមូលទិន្នន័យ......២៩
៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ......២៩
៣.៦ ព័ត៌មានទូទៅ......២៩

## ជំពូកទី៤

## លទ្ធផល និងការពិភាក្សា

៤.១ លទ្ធផលស្រាវជ្រាវ......៣២
៤.១.១ តួនាទី ភារកិច្ចរបស់ឪពុកម្ដាយ......៣២
៤.១.២ ទទួលបានចំណេះដឹង......៣៣
៤.១.៣ សុវត្ថិភាព......៣៦
៤.១.៤ ពេលទំនេរ......៣៧
៤.២ ពិភាក្សា......៣៨

## ជំពូកទី៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ

៥.១ សេចក្តីសន្និដ្ឋាន......៤៥
៥.២ សំណូមពរ......៤៦
៥.៣ ការសិក្សាស្រាវជ្រាវបន្ត......៤៦
ឯកសារយោង......៤៧
ឧបសម្ព័ន្ធ......៤៩

# បញ្ជីតារាង


- ក្រាហ្វិចទី១ ៖ ភេទរបស់អ្នកសម្ភាសន៍
- ក្រាហ្វិចទី២ ៖ អាយុរបស់អ្នកសម្ភាសន៍
- ក្រាហ្វិចទី៣ ៖ មុខរបររបស់អ្នកសម្ភាសន៍
- ក្រាហ្វិចទី៤ ៖ កម្រិតវប្បធម៌របស់អ្នកសម្ភាសន៍
- ក្រាហ្វិចទី៥ ៖ តួនាទី ភារកិច្ច របស់ឪពុកម្តាយដែលបានសម្ភាសន៍
- ក្រាហ្វិចទី៦ ៖ ការទទួលបានចំណេះដឹងរបស់អ្នកសម្ភាសន៍
- ក្រាហ្វិចទី៧ ៖ សុវត្ថិភាពក្នុងការបញ្ជូនទៅសាលារៀននៅសាលា ៨មីនា
- ក្រាហ្វិចទី៨ ៖ ពេលទំនេរនៅពេលបញ្ជូនទៅសាលាមត្តេយ្យ

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហា

ការអភិវឌ្ឍធនធានមនុស្ស គឺជាមូលធននិរន្តភាពដែលមានសារៈសំខាន់ខ្លាំងរបស់ប្រទេសកម្ពុជាយើង ដែលរាជរដ្ឋាភិបាល ដែលមានក្រសួងអប់រំ យុវជន និងកីឡាជាសេនាធិការខិតខំកំណែទម្រង់ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាកាន់តែមានគុណភាព និងមានទំនើបកម្ម។ កម្ពុជាបានទទួលយកការអប់រំបែបឌីជីថល កម្រិតឧស្សាហកម្ម៤.០ ដែលជាការអប់រំបែបបច្ចេកវិជ្ជាក្នុងសម័យទំនើបកម្ម ដើម្បីប្រកួតប្រជែងតម្រូវការទីផ្សារធនធានមនុស្សនៅក្នុងតំបន់និងពិភពលោក។ យើងឃើញថា ឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសកម្ពុជា គឺមិនអាចជានិរន្តភាពសម្រាប់សេដ្ឋកិច្ចប្រទេសតទៅទៀតទេ គឺត្រូវបោះជំហានទៅរកឧស្សាហកម្មធន់ធ្ងន់ ពីប្រទេសនាំចេញវត្ថុធាតុដើម មកជាប្រទេសនាំចេញវត្ថុសម្រេចក្នុងថ្ងៃអនាគតខាងមុខ។ ដើម្បីបម្រើការងារនៅ ក្នុងឧស្សាហកម្មទាំងនេះបាន គឺតម្រូវឱ្យមានធនធានមនុស្សដែលមានជំនាញពិតប្រាកដផ្នែកបច្ចេកទេសមេកានិក ជំនាញទីផ្សារ ទំនាក់ទំនង និងភាសាបរទេសជាដើម។ ការប្រែប្រួលមិនច្បាស់លាស់នៅក្នុងតំបន់និង ពិភពលោកកំពុងធ្វើឱ្យប្រទេសកម្ពុជាកាន់តែត្រូវការធនធានមនុស្សជាច្រើនបន្ថែមទៀត។ ធនធានមនុស្សទាំងនោះនឹងធ្វើឱ្យប្រទេសនេះ ចូលរួមប្រកួតប្រជែងកម្លាំងពលកម្មការងារជំនាញ និងបរិបទនៃការរស់នៅដោយឡែក។ ប្រជានជនកម្ពុជាដែលប្រកបរបរកសិកម្មបែបប្រពៃណីគឺកំពុងតែជួបប្រទះបញ្ហាប្រឈមជាខ្លាំងដោយសារ ពួកគាត់ខ្វះបច្ចេកទេស មិនបានទទួលការអប់រំជំនាញជាដើម។ បញ្ហាទាំងនេះយើងត្រូវគិតពីធនធានមនុស្សទៅថ្ងៃអនាគតដើម្បីរស់ដោយការប្រកួតប្រជែង មានជំនាញក្នុងការគិត ដោះស្រាយបញ្ហា គ្រប់គ្រងបញ្ហា ជំនាញវិភាគ ជំនាញ គ្រប់គ្រងព័ត៌មាន និងជំនាញទំនាក់ទំនងជាដើម។

គោលនយោបាយនិងកំណែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជា ឆ្នាំ២០១៤-២០១៨ ដោយបានកំណត់គោលនយោបាយចម្បងចំនួន២ គឺ ទី១-ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ទី២-ធានាភាពស័ក្តសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់ (របាយការណ៍ពាក់កណ្តាលអណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨)។តាមផែនការយុទ្ធសាស្ត្ររបស់ក្រសួងអប់រំយើងឃើញថា ការធានាគុណភាពអប់រំគឺជាកត្តាសំខាន់នៅក្នុងវិស័យអប់រំ និងផ្តល់ឱកាសសិក្សាពេញមួយជីវិត ដល់សិស្ស នុសិស្សផងដែរ។ សិស្សានុសិស្សត្រូវមានសមភាព និងសមធម៌ក្នុងការសិក្សាក្រេបជញ្ជក់ចំណេះដឹង និងបំនិនផ្សេងៗ ពីសាលារៀនដើម្បីរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ។

គោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូច ទទួលបានការអនុម័តជាផ្លូវការពីគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០។ គោលនយោបាយនេះបានរៀប ចំឡើងក្រោមការដឹកនាំសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងមានកិច្ចសហការពេញលេញពីក្រសួងពាក់ព័ន្ធចំនួន ១០ផ្សេងទៀត ដែលកំពុងពេញការងារពាក់ព័ន្ធ សេវាគាំពារនិងអភិវឌ្ឍកុមារតូច។ ក្រសួងពាក់ព័ន្ធទាំង១០

នោះរួមមាន (១)ក្រសួងសុខាភិបាល (២) ក្រសួងមហាផ្ទៃ (៣)ក្រសួងកិច្ចការនារី (៤)ក្រសួងព័ត៌មាន (៥) ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា (៦)ក្រសួងអភិវឌ្ឍន៍ជនបទ (៧)ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៨)ក្រសួងផែនការ (៩)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង(១០) ក្រសួង បរិស្ថាន។[1]

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារនិង អភិវឌ្ឍន៍កុមារតូចរបស់ប្រទេសកម្ពុជារយៈពេល៥ឆ្នាំចាប់ពីឆ្នាំ២០១៤-ឆ្នាំ២០១៨ ដែលសម្របសម្រួលជាមួយគ្នាទៅវិញទៅមកជាមួយភាគីពាក់ព័ន្ធ។ សកម្មភាពជាតិនេះនឹងចូលរួមចំណែកដោយផ្ទាល់ចំពោះការសម្រេចនៅចំណុចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើនគុណភាពសេវា និងពង្រីកភាពគ្របដណ្តប់នៃសេវាគាំពារនិងអភិវឌ្ឍន៍កុមារតូចឱ្យបានឆាប់រហ័ស។[2]

សកម្មភាពទាំងនោះមានសេវា៤គឺៈ

១-មត្តេយ្យសិក្សារដ្ឋ ជាកន្លែងដែលទទួលកុមារមានអាយុពី៣ឆ្នាំ ទៅក្រោម៦ឆ្នាំឱ្យចូលរៀនប្រកបដោយសមធម៌។ វាជាការទទួលខុសត្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការកសាងអគារសិក្សា ការជ្រើសរើសគ្រូបង្រៀន ការបណ្តុះបណ្តាលនិងបំប៉នបន្ថែម ការផ្គត់ផ្គង់សម្ភារៈ និងឯកសារពាក់ព័ន្ធ ហើយក្រសួងជាអ្នកគ្រប់គ្រងដឹកនាំ និងនាយកដ្ឋាន កុមារតូចជាអ្នកអនុវត្ត។ មត្តេយ្យសិក្សារដ្ឋចែកចេញជាសាលាមត្តេយ្យសិក្សាដាច់ដោយឡែកនិងសាលា/ថ្នាក់មត្តេយ្យនៅក្នុងសាលាមត្តេយ្យសិក្សា។ កុមារដែលចូលរៀនសាលា មត្តេយ្យសិក្សារដ្ឋគឺជាកុមារដែលមានអាយុពី៣ឆ្នាំដល់ក្រោម៦ឆ្នាំ មកពីភូមិដែលចំណុះឱ្យសាលា កុមារទាំងនោះត្រូវបែងចែកឱ្យរៀននៅតាមកម្រិតថ្នាក់ៈ[3]

- កុមារមានអាយុ៣ឆ្នាំ រៀនថ្នាក់កម្រិតទាប
- កុមារមានអាយុ៤ឆ្នាំ រៀនថ្នាក់កម្រិតមធ្យម
- កុមារមានអាយុ៥ឆ្នាំ រៀនថ្នាក់កម្រិតខ្ពស់
- កុមារមានអាយុ៣ ទៅដល់ក្រោម៦ឆ្នាំ រៀនថ្នាក់ចម្រុះ

២-មត្តេយ្យសិក្សាឯកជន គឺជាសាលាមត្តេយ្យដែលមានកុមារតូចអាយុពី៣ឆ្នាំទៅដល់ក្រោម៦ឆ្នាំ ដែលបានទទួលការបណ្តុះបណ្តាលសេវាអប់រំផ្នែកឯកជន។

៣-មត្តេយ្យសិក្សាសហគមន៍ គឺជាសាលាមត្តេយ្យសិក្សានៅក្នុងសហគមន៍ផ្តល់សេវាអប់រំកុមារតូច នៅក្នុងសហគមន៍របស់ខ្លួន។

---

[1]គជគក, ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច, ថ្ងៃ១៣ខែសីហាឆ្នាំ២០១៨,ទំ១

[2] -ដដែល-

[3] នាយកដ្ឋានអប់រំកុមារតូច, វគ្គបំប៉ននាយក នាយិកាសាលាមត្តេយ្យសិក្សា/សាលាមត្តេយ្យសិក្សាស្តីពីការគ្រប់គ្រងតាមស្តង់ដាគុណភាព,ស្លាយទី២,ឆ្នាំ២០១៦

៤-ការអប់រំកុមារតូចតាមផ្ទះ គឺជាយុទ្ធនាការចុះអប់រំកុមារតូច និងមាតាបិតាតាមខ្នង ផ្ទះដើម្បីឱ្យពួកគាត់ស្វែងយល់ពីសារៈសំខាន់ក្នុងការសិក្សារបស់កូននៅផ្ទះ និងការបញ្ជូនកូនទៅសិក្សានៅតាមសាលា។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយអង្កេតឃើញថា ការបញ្ជូនកូនតូចដែលមានអាយុត្រឹមតែ៣ ៤ និង៥ឆ្នាំចូលរៀននៅសាលាមត្តេយ្យ ក្នុងរាជធានីភ្នំពេញកើនឡើង ជាពិសេសនៅសាលាមត្តេយ្យ៨មីនា នៅរាជធានីភ្នំពេញ មានចំណោទបញ្ហាជាច្រើន ជុំវិញការបញ្ជូនកូនមករៀននេះ ដោយសារពីមុនមកឪពុកម្តាយ អាណាព្យាបាល តែងតែបញ្ជូនកូនទៅសាលា នៅអាយុ៦ឆ្នាំ ឬ៧ ២ខែ ហើយកម្របញ្ជូនកូនចូលមត្តេយ្យណាស់។ សម័យបច្ចុប្បន្ននេះ គឺជាសម័យកាលមានការរីកចម្រើន មានការប្រកួតប្រជែងក្នុងការងារ និងការរកស៊ីជាដើម ម្យ៉ាងវិញទៀត វិស័យអប់រំជាវិស័យមួយអទិភាពក្នុងការចូលរួមអភិវឌ្ឍប្រទេសជាតិផង។ ចំពោះបរិបទកម្ពុជាបច្ចុប្បន្ន ជាពិសេសអ្នកនៅភ្នំពេញគឺយកចិត្តទុកដាក់ខ្លាំងណាស់ពីការបញ្ជូនទៅសាលារៀននៅវ័យក្មេងៗ ដូចជាពួកគេតែងលើកឡើងថា កូនខ្ញុំចូលរៀននៅសាលានេះ សាលានោះ ដោយចំណាយអស់ប៉ុណ្ណេះ ប៉ុណ្ណោះ ហើយអ្នកខ្លះក៏ជ្រើសរើសយកសាលារដ្ឋក្នុងការបញ្ជូនកូនចូលរៀនផងដែរ។ ជុំវិញករណីដែលលើកឡើងនេះ ជាចំណោទបញ្ហាដល់រូបនាងខ្ញុំដែលកំពុងសិក្សាផ្នែក អប់រំនៅវិទ្យាស្ថានជាតិអប់រំ ដែលថា បរិបទការអប់រំនៅមត្តេយ្យសិក្សាកម្ពុជា ជាពិសេសសាលាមត្តេយ្យ៨មីនា ដែលជាមត្តេយ្យសិក្សារដ្ឋមួយនៅភ្នំពេញដែលទទួលបានការចាប់អារម្មណ៍ និងជាគោលដៅមួយក្នុងចំណោមគោលដៅជាច្រើនដែលឪពុកម្តាយ និងអាណាព្យាបាលជ្រើសរើសបញ្ជូនកូនតូចរបស់ពួកគេទៅរៀនទៅទីនោះបណ្តាល មកពីកត្តាជំរុញណាខ្លះ។ ការបញ្ជូនកូនតូចចូលមត្តេយ្យបែបនេះ គឺដើម្បីត្រឹមតែទទួលបានចំណេះដឹងឬ ក៏មានកត្តាអ្វីផ្សេងទៀត។

## ១.៣ គោលបំណងស្រាវជ្រាវ

ក្នុងនាមនាងខ្ញុំជាមន្ត្រីអប់រំម្នាក់ ដែលកំពុងបំពេញការងារនៅនាយកដ្ឋានអប់រំកុមារតូច បន្ទាប់ពីបានចោទជាបញ្ហាដូចខាងលើ គឺចង់ស្រាវជ្រាវដើម្បីៈ

- រកឱ្យឃើញពីមូលហេតុក្នុងការបញ្ជូនកូនអាយុបី បួន ប្រាំឆ្នាំ ចូលរៀននៅសាលាមត្តេយ្យ៨មីនា

ចំណុចខាងលើនេះគឺគោលបំណងសំខាន់របស់នាងខ្ញុំ ដោយសារតែឥរិយាបថខ្មែរយើងមានការប្រែប្រួលខ្លាំងក្នុងការបញ្ជូនកូនតូចចូលមត្តេយ្យសិក្សា ជាពិសេសនៅសាលាមត្តេយ្យ៨មីនា ជាសាលាមត្តេយ្យសិក្សារដ្ឋនៅរាជធានីភ្នំពេញនេះតែម្តង។ គោលបំណងចង់ចេះ ចង់ដឹង ឱ្យច្បាស់លាស់ពិតប្រាកដថា នៅពីក្រោយការបញ្ជូនកូន របស់ពួកគាត់ចូលរៀន មានអ្វីខ្លះទៀត គឺជារឿងពិសេសមួយទាក់ទងនិងការប្រែប្រួល និងចំណាប់អារម្មណ៍អ្នកអប់រំ ទូទៅ។

- ស្វែងយល់ពីទស្សនៈទូទៅរបស់មាតាបិតាក្នុងការយកចិត្តទុកដាក់ចំពោះកូនតូច ចំពោះការសិក្សារៀននៅសាលាមត្តេយ្យ ៨មីនា
- ស្វែងយល់ពីគុណសម្បត្តិនិងគុណវិបត្តក្នុងការបញ្ជូនកុមារតូចចូលរៀននៅមត្តេយ្យសិក្សារដ្ឋ

- ស្វែងយល់តម្រូវការរបស់មាតាបិតាចំពោះមត្តេយ្យសិក្សារដ្ឋ
- ចូលរួមផ្តល់ទស្សនៈទានខ្លះៗ ដល់ការអប់រំកុមារតូច

## ១.៤ សំណួរស្រាវជ្រាវ

មានសំណួរ ដែលបានលេចឡើង ដើម្បីធ្វើការស្រាវជ្រាវចំណុចដែលរំពឹងទុកថាៈ

- តើមាតាបិតាយល់ឃើញដូចម្តេចចំពោះការបញ្ជូនកូន អាយុបី បួន ប្រាំឆ្នាំ ទៅរៀននៅសាលាមត្តេយ្យ ៨មីនា?

សំនួរនេះ គឺជាការចង្អុលផ្លូវជាក់លាក់ដល់ការស្រាវជ្រាវមួយស្របតាមគោលបំណងរបស់នាងខ្ញុំ។ វានឹងក្លាយជាមូលដ្ឋានប្រមូលនូវទិន្នន័យគាំទ្រ និងការធ្វើសេចក្តីសន្និដ្ឋានបានច្បាស់លាស់ នឹងដោះស្រាយបញ្ហាដែល បានលេចឡើងខាងលើ។

## ១.៥ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៥.១-វិសាលភាពនៃការស្រាវជ្រាវ

-ដាក់កម្រងសំណួរដល់មាតាបិតាសិស្ស ដែលមានកូនតូចរៀននៅសាលាមត្តេយ្យ៨មីនាចំនួន ១០១នាក់ ។

-អ្នកចូលរួមចំនួន១០១នាក់ ស្រីចំនួន៦៩នាក់

### ៥.២-ដែនកំណត់នៃការស្រាវជ្រាវ

-រយៈពេលនៃការស្រាវជ្រាវ ចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩-០៥ខែតុលា ឆ្នាំ២០១៩

-ទីកន្លែងចុះស្រាវជ្រាវ នៅសាលាមត្តេយ្យ៨មីនា តែមួយគត់ សម្រាប់មត្តេយ្យសិក្សា (រាជធានីភ្នំពេញ)

# ជំពូកទី២

# រំលឹកទ្រឹស្តី

នៅក្នុងប្រធានបទនេះ "**ទស្សនៈយល់ឃើញរបស់មាតាបិតា ក្នុងការបញ្ជូនកូនទៅរៀននៅមត្តេយ្យសិក្សា អាយុ ៣ឆ្នាំ ៤ឆ្នាំ និង៥ឆ្នាំ (ករណីសិក្សានៅភ្នំពេញ)**" ដែលត្រូវធ្វើការស្រាវជ្រាវរកឱ្យឃើញពីការយល់ឃើញរបស់មាតាបិតាដែលបានសម្រេចចិត្តបញ្ជូនកូនរបស់គាត់ទៅកាន់មត្តេយ្យសិក្សា ដែលករណីនេះត្រូវបានធ្វើការសិក្សាស្រាវជ្រាវនៅសាលាមត្តេយ្យ ៨មីនា នៅរាជធានីភ្នំពេញ។ ដើម្បីឈានដល់ការស្វែងយល់ពីអត្ថប្រយោជន៍មុនឈានដល់ការស្រាវជ្រាវគប្បីស្វែងយល់ពីទ្រឹស្តី និងចំណុចសំខាន់ៗដែលជាប់ពាក់ព័ន្ធជាមុនក្នុងការទទួលបានមូលដ្ឋានបកស្រាយពន្យល់។

## ២.១ ពន្យល់ពាក្យគន្លឹះ

យោងតាមវីគីភីឌា (Wikipedia) បង្ហាញថា មត្តេយ្យសិក្សា គឺជាសួនច្បាររបស់កុមារ ( Kindergarten literally meaning 'garden for the children') ការអប់រំផ្តោតទៅលើ ការលេង ការច្រៀង ការធ្វើលំហាត់ផ្សេងៗដូចជាការគូសរូប រៀនស្គាល់គ្នា ទំនាក់ទំនងគ្នាបែបសង្គមដែលផ្នែកនៃការផ្លាស់ប្តូរបែបការរស់នៅក្នុងផ្ទះ មកកាន់សាលារៀនដែលជាការឈានជើងចូលសង្គមដំបូងរបស់កុមារ។ សាលាមត្តេយ្យត្រូវបានគេបង្កើតឡើងដំបូងបង្អស់នៅសតវត្សទី១៨ នៅបាវ៉ារៀ (Bavaria) និង ស្ត្រាស្ប៊ើហ្គ (Strasbourg)ដើម្បីមើលថែកុមារដែលមានឪពុកម្តាយរបស់គេធ្វើការទាំងពីរនាក់នៅក្រៅផ្ទះ។ ពាក្យនេះបង្កើតដោយជនជាតិអាល្លឺម៉ង់ឈ្មោះ ហ្វ្រេដឺរិច ហ្វ្រូបែល (Friedrich Frobel) ហើយបច្ចុប្បន្ននេះត្រូវបានប្រើប្រាស់ជាច្រើនប្រទេសនៅជុំវិញពិភពលោកទៅតាមស្ថាប័នអប់រំ សម្រាប់កុមារដែលមានអាយុជុំវិញ២ឆ្នាំ ទៅ៧ឆ្នាំ វាអាស្រ័យទៅតាមវិធីបង្រៀនដោយឡែកពីគ្នា។

ការឱ្យនិយមន័យចំពោះមត្តេយ្យសាលានៅក្នុងប្រទេសអូស្ត្រាលី គឺមានន័យថាសប្បុរស គឺមានន័យថាអ្វីៗដែលងាយនឹងប្លែក។ វាជាឆ្នាំដំបូងរបស់មត្តេយ្យសិក្សា។ នៅក្នុងរដ្ឋវិចធើរីយ៉ា kindergarten គឺជាទម្រង់របស់ Preschool ហើយពាក្យនេះមានន័យដូចគ្នា។ សម្រាប់មត្តេយ្យសាលាត្រូវបានគេហៅយ៉ាងខ្លីថាព្រីប (Prep) មកពី (Preparation) មានន័យថាការរៀបចំ ដោយចាប់ផ្តើមពីថ្នាក់ទី១។ នៅទីក្រុងឃ្វីនឡែន មត្តេយ្យសាលា ត្រូវបានគេប្រើជាទូទៅជាសាលាសម្រាប់កុមារដែលមានអាយុប្រហែល៤ឆ្នាំដែលត្រូវចូលរៀននៅមត្តេយ្យ។ នៅភាគខាងត្បូង និងភាគខាងលិចអូស្ត្រាលី ពាក្យ មត្តេយ្យសាលា (kindergarten) ត្រូវបានគេហៅថា មុន មត្តេយ្យ (Pre-primary)។

នៅក្នុងប្រទេសចិនមត្តេយ្យសិក្សា គឺជាការអប់រំដល់កុមារមុនចូលរៀនផ្លូវការនៅសាលារៀននៅអាយុ៦ឆ្នាំដែលគេបែងចែកជាបីប្រភេទ គឺទារកដ្ឋាន មត្តេយ្យកម្រិតទាប និងមត្តេយ្យកម្រិតខ្ពស់។ ទារកដ្ឋាន ឬក្រុមលេង មានអាយុ ពី៣ឆ្នាំ ទៅ៤ឆ្នាំ។ មត្តេយ្យកម្រិតទាប មានអាយុពី៤ឆ្នាំ ទៅ៥ឆ្នាំ និងមត្តេយ្យកម្រិតខ្ពស់ អាយុចាប់ពី៥ឆ្នាំទៅ៦ឆ្នាំ។ ហើយនៅតំបន់ខ្លះក្នុងប្រទេសចិន កុមារអាយុពី៥ឆ្នាំទៅ៦ឆ្នាំ គឺត្រូវការ

បន្ថែម ឬហៅថាថ្នាក់ត្រៀម គឺសំដៅទៅលើការរៀបចំកុមារមុនចូលរៀនផ្លូវការ។ សម្រាប់សាលាមត្តេយ្យរបស់រដ្ឋទទួលកុមារចូលរៀននៅអាយុ៣ឆ្នាំ សម្រាប់មត្តេយ្យឯកជនវិញមិនមានកំណត់ទេ។

នៅប្រទេសជប៉ុន ការអប់រំដំបូងគឺចាប់ផ្តើមឡើងនៅផ្ទះ តាមរយៈការប្រើប្រាស់សៀវភៅជាច្រើនរួមជាមួយទូរទស្សន៍ សម្រាប់ជួយកុមារតាមរយៈឪពុកម្តាយមុនកូនចូលសាលាមត្តេយ្យ។ ការអប់រំនៅផ្ទះគឺសង្កត់ធ្ងន់លើការអប់រំឥរិយាបថ អាកប្បកិរិយាសង្គមល្អ និងការសំដែងទៅតាមឋានានុក្រម ម្យ៉ាងវិញគឺអប់រំកូននៅជំនាញ ការនិយាយ និងគណនាលេខ។ ឪពុកម្តាយមានការប្តេជ្ញាចិត្តខ្លាំងក្នុងការអប់រំកូនក្នុងវ័យដំបូងបន្ទាប់មកយកកូនទៅចុះឈ្មោះចូលរៀននៅមត្តេយ្យសាលា។

សម្រាប់ប្រទេសកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បានបែងចែកសាលាមត្តេយ្យជាបួនប្រភេទគឺះ

១-មត្តេយ្យសិក្សារដ្ឋ ជាកន្លែងដែលកុមារមានអាយុពី៣ឆ្នាំ ទៅក្រោម៦ឆ្នាំឱ្យចូលរៀនប្រកបដោយសមធម៌។ វាជាការទទួលខុសត្រូវរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការកសាងអគារសិក្សា ការជ្រើសរើសគ្រូបង្រៀន ការបណ្តុះបណ្តាលនិងបំប៉នបន្ថែម ការផ្គត់ផ្គង់សម្ភារៈ និងឯកសារពាក់ព័ន្ធ ហើយក្រសួងជាអ្នកគ្រប់គ្រងដឹកនាំ និងនាយកដ្ឋាន កុមារតូចជាអ្នកអនុវត្ត

មត្តេយ្យសិក្សារដ្ឋចែកចេញជាសាលាមត្តេយ្យសិក្សាដាច់ដោយឡែកនិងសាលាថ្នាក់មត្តេយ្យនៅក្នុងសាលាមត្តេយ្យសិក្សា។ កុមារដែលចូលរៀននៅសាលា មត្តេយ្យសិក្សារដ្ឋគឺជាកុមារដែលមានអាយុពី៣ឆ្នាំដល់ក្រោម៦ឆ្នាំ មកពីភូមិដែលចំណុះឱ្យសាលា កុមារទាំងនោះត្រូវបែងចែកឱ្យរៀននៅតាមកម្រិតថ្នាក់ះ[4]

- កុមារមានអាយុ៣ឆ្នាំ រៀនថ្នាក់កម្រិតទាប
- កុមារមានអាយុ៤ឆ្នាំ រៀនថ្នាក់កម្រិតមធ្យម
- កុមារមានអាយុ៥ឆ្នាំ រៀនថ្នាក់កម្រិតខ្ពស់
- កុមារមានអាយុ៣ ទៅដល់ក្រោម៦ឆ្នាំ រៀនថ្នាក់ចម្រុះ

២-មត្តេយ្យសិក្សាឯកជន គឺជាសាលាមត្តេយ្យដែលមានកុមារតូចអាយុពី៣ឆ្នាំទៅដល់ក្រោម៦ឆ្នាំ ដែលបានទទួលការបណ្តុះបណ្តាលសេវាអប់រំផ្នែកឯកជន។

៣-មត្តេយ្យសិក្សាសហគមន៍ គឺជាសាលាមត្តេយ្យសិក្សានៅក្នុងសហគមន៍ផ្តល់សេវាអប់រំកុមារតូចនៅក្នុងសហគមន៍របស់ខ្លួន។

៤-ការអប់រំកុមារតូចតាមផ្ទះ គឺជាយុទ្ធនាការចុះអប់រំកុមារតូច និងមាតាបិតាតាមខ្នងផ្ទះដើម្បីឱ្យពួកគាត់ស្វែងយល់ពីសារៈសំខាន់ក្នុងការសិក្សារបស់កូននៅផ្ទះ និងការបញ្ជូនកូនទៅសិក្សានៅតាមសាលា។

## ២.២ ស្ថានភាពទូទៅ

ស្ថានភាពអប់រំនៅប្រទេសកម្ពុជា បានកំពុងខិតខំឆ្ពោះទៅសម្រេចគោលនយោបាយអប់រំស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG-4) "ធានាការអប់រំបរិយាប័ន្ន សមធម៌ គុណភាព និងលើក

[4] នាយកដ្ឋានអប់រំកុមារតូច, វគ្គបំប៉ននាយក នាយិកាសាលាមត្តេយ្យសិក្សា/សាលាមត្តេយ្យសិក្សាស្តីពីការគ្រប់គ្រងតាមស្តង់ដាគុណភាព,ស្លាយទី២,ឆ្នាំ២០១៦

កម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"។ មេដឹកនាំពិភពលោកបានជួបជុំគ្នានៅអង្គការសហប្រជាជាតិ នៅញូវយ៉កដើម្បីអនុម័តរបៀបវារៈ ឆ្នាំ២០៣០ សម្រាប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ គោលដៅសកលគឺមានលក្ខណៈជាសកល ហើយត្រូវបានអំពាវនាវឱ្យធ្វើសកម្មភាពដើម្បីធានាការអភិវឌ្ឍសេដ្ឋកិច្ច វឌ្ឍនភាពសង្គម និងនិរន្តរភាពបរិស្ថានទូទាំងពិភពលោក។ សេដ្ឋវិទូ អ្នកនយោបាយ មេដឹកនាំសាសនា អ្នកឯកទេសខាងអភិវឌ្ឍន៍ និងអ្នកល្បីល្បាញបានសាទរចំពោះគោលដៅពិភពលោកទាំង១៧ ដែលជាឱកាសពិតប្រាកដមួយដើម្បីដោះស្រាយបញ្ហាបន្ទាន់បំផុតដែលប្រឈមនឹងមនុស្ស និងភពផែនដី។ ការសន្យាជាសកលនៃគោលដៅសកល "កុំឱ្យនរណាម្នាក់នៅពីក្រោយ" មានន័យថាសហគមន៍សកលលោកត្រូវតែរួបរួមគ្នាក្នុងចក្ខុវិស័យសមូហភាពដើម្បីផ្លាស់ប្តូរពិភពលោករបស់យើង។[5]

ប្រទេសកម្ពុជាបានដាក់គោលដៅអភិវឌ្ឍជាតិនៅឆ្នាំ២០៣០ នឹងក្លាយជាប្រទេសដែលមានចំណូលមធ្យម កំរិតខ្ពស់ គឺមានន័យថា ប្រជាជនម្នាក់ទទួលបានចំណូលមធ្យមប្រហាក់ប្រហែលប្រជាជនថៃបច្ចុប្បន្ន(ឆ្នាំ២០១៩) និងឆ្នាំ២០៥០ក្លាយជាប្រទេសអភិវឌ្ឍដែលមានចំណូលជាមធ្យមស្មើនឹងប្រទេសសិង្ហបុរីបច្ចុប្បន្ន (២០១៩)។ នៅក្នុងឆ្នាំ២០១៩នេះ រដ្ឋាភិបាលដែលមានក្រសួងអប់រំជាសេនាធិការបានពង្រឹងប្រព័ន្ធអប់រំកម្ពុជាដើម្បីឆ្លើយតបនិងការប្រកួតប្រជែងក្នុងតំបន់ និងពិភពលោកតាមរយៈគោលនយោបាយគ្រូបង្រៀន ដោយផ្តោតទៅការតំឡើងប្រាក់បៀវត្សនិងការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនផងដែរ។ រដ្ឋាភិបាលក៏បានចំណាយថវិកាកាន់តែច្រើនឡើង សម្រាប់វិស័យអប់រំពីមួយអាណត្តិទៅមួយអាណត្តិ។

ការប្រមូលសិស្សចូលរៀនបានកើនឡើងរហូតដល់៩៨% តែចំពោះកុមារតូចមានការចូលរៀននៅតិចនៅឡើយ បើយោងតាមរបាយការណ៍អង្គការ យូនីសេហ្វបានបង្ហាញថាកុមារតូចបានចូលរៀនត្រឹមតែ៥៦%ប៉ុណ្ណោះនៅឆ្នាំ២០១៦។ ការចូលរៀនរបស់កុមារតូច មានចំនួនតិចនៅឡើយ គឺវាបណ្តាលមកពីកត្តាផ្សេងៗដូចជាភាពក្រីក្រ ភូមិសាស្ត្រ សាលារៀន មធ្យោបាយធ្វើដំណើរ បញ្ហាយេនឌ័រជាដើម។ កុមារតូចនៅតំបន់ដាច់ស្រយាល គឺមិនមានឱកាសច្រើនបានចូលរៀនទេដោយសារគ្រួសារក្រីក្រ ខ្វះសាលារៀនមត្តេយ្យ និងភូមិសាស្ត្រដែលប្រឈមសម្រាប់ពួកគាត់។

ផែនការយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍជាតិ និងផែនការយុទ្ធសាស្ត្រអប់រំសិក្សា ធិការនៅកម្ពុជាបានបើកឲ្យទទួលបានការអប់រំ សិក្សាកាន់តែទូលាយ នៅក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ។ អត្រាចុះឈ្មោះចូលរៀនថ្នាក់មត្តេយ្យបានកើនឡើងគួរឲ្យកត់សម្គាល់ ដោយឥឡូវនេះក្មេងស្រីមានឱកាសស្មើក្មេងប្រុសក្នុងការទទួលបានការរៀនសូត្រ។ប្រទេសកម្ពុជាបានផ្តល់ការសិក្សាដល់សិស្សប្រមាណ៣,៥លាននាក់ពីកម្រិតមុនថ្នាក់មត្តេយ្យរហូត ដល់មហាវិទ្យាល័យ និងបានផ្តល់ការងារដល់គ្រូបង្រៀនប្រមាណ៨៥០០០នាក់ នៅក្នុងកម្រិតមុនមត្តេយ្យសិក្សាទៅដល់អនុវិទ្យាល័យ។

[5] https://www.unicef.org/cambodia/km/

របាយការណ៍របស់ធនាគារពិភពលោក ដែលបានចេញផ្សាយ កាលពីថ្ងៃព្រហស្បតិ៍ បានបញ្ជាក់ឲ្យដឹងថា តំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិកជាកន្លែងប្រមូលផ្ដុំនូវប្រព័ន្ធអប់រំសិក្សាធិការចំនួនប្រាំពីរ ក្នុងចំណោមប្រព័ន្ធអប់រំមានដំណើរការខ្ពស់ចំនួន១០ នៅទូទាំងពិភពលោក ដែលក្នុងនោះ ប្រទេសចិន និងប្រទេសវៀតណាម បានបង្ហាញវឌ្ឍនភាព ជាដុំកំភួនក្នុងការបង្កើនគុណភាព បង្រៀននៅតាមសាលារៀននៅក្នុងប្រទេសរៀងៗខ្លួន។ វឌ្ឍនភាពនេះ ជាសមិទ្ធផលធំធេងមួយ ដែលផ្ដល់មេរៀនមានសារៈសំខាន់ដល់បណ្ដាប្រទេសឯទៀត នៅជុំវិញពិភពលោក។ របាយការណ៍នេះបានសរសេរក្នុងន័យដើមថា៖ «យ៉ាងណាក៏ដោយ មួយផ្នែកធំនៃតំបន់នេះ នៅមានសិស្សរហូតដល់ទៅ ៦០ភាគរយ ដែលកំពុងរៀននៅតាមសាលាដែលដំណើរការខ្វះគុណភាព ក្នុងការបំពាក់ឲ្យពួកគេនូវជំនាញចាំបាច់ សម្រាប់ឈានទៅសម្រេចជោគជ័យ នាពេលអនាគត»។ ប្រព័ន្ធអប់រំសិក្សាធិការដែលល្អបំផុតឈរក្នុងលំដាប់កំពូលចំនួន៧រួមមាន ប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ ប្រទេសសិង្ហបុរី កោះតៃវ៉ាន់ តំបន់រដ្ឋបាលពិសេសហុងកុង តំបន់រដ្ឋបាលពិសេស ម៉ាកាវ និងតំបន់រដ្ឋបាលពិសេសសៀងហៃ។ របាយការណ៍ឲ្យដឹងថា ប្រទេសកម្ពុជាឋិតក្នុងប្រទេសដែល កំពុងខំប្រឹងបង្កើតប្រព័ន្ធល្អមួយនៅក្នុងតំបន់។ ប្រទេសដទៃដែលមានស្ថានភាពដូចគ្នានឹងកម្ពុជា ក្នុងនោះ រួមមានប្រទេសលាវ ម៉ុងហ្គោលី មីយ៉ាន់ម៉ា ឬភូមា ប៉ាពួញូវគីណេ (Papua New Guinea) និង ទីម័រខាងកើត (Timor-Leste) ជាដើម។[6]

នាយកដ្ឋានអប់រំកុមារតូចកំពុងបានអនុវត្តកម្មវិធីនានាគាំទ្រដល់សាលារៀន។ ថវិកា ដំណើរការសាលារៀន និងថវិកាកែលម្អសាលារៀន ដោយសាលាមត្តេយ្យសិក្សាដាច់ដោយឡែកទាំងអស់បានទទួលថវិកាដំណើរការ និង ថវិកាលម្អសាលារៀនសម្រាប់អភិវឌ្ឍសាលារៀនដោយផ្អែកលើស្តង់ដាសេវាអប់រំ ក្នុងគោលបំណងបង្កើនស្វ័យភាព ក្នុងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ពង្រឹងគណនេយ្យភាពលើការគ្រប់គ្រងថវិកា និងជានាភាពឆ្លើយតបទៅនិងសមិទ្ធផលសិក្សារបស់សិស្ស។

កម្មវិធីអប់រំពហុភាសា សម្រាប់ជនជាតិដើមភាគតិច បានអនុវត្តក្នុងក្រុង ស្រុក១៩ ក្នុងខេត្តគោលដៅ៥ មានខេត្តរតនគិរី ស្ទឹងត្រែង មណ្ឌលគិរី ព្រះវិហារ និងក្រចេះ។ កម្មវិធីនេះបានអនុវត្តនៅតាមសាលាមត្តេយ្យសិក្សារដ្ឋ ៣កន្លែង មានសិស្ស១០២នាក់ ស្រី៥៨នាក់ កើន៨នាក់ ស្រី៧នាក់ និងមត្តេយ្យសិក្សាសហគមន៍៩៥កន្លែង កើន១៤ មានសិស្ស១៧៥៩នាក់ ស្រី៨៩៩នាក់ កើន២៨៥នាក់ ស្រី១១៥នាក់។ ភាសាដែលប្រើប្រាស់រួមមាន ភាសាទំពួន គ្រឹង ព្នង កួយ ក្រោល ការ៉ែត ព្រៅ។ កម្មវិធីមត្តេយ្យសិក្សាចល័តបានគ្រប់ដណ្តប់លើកុមារមានអាយុពី៣ឆ្នាំទៅ៥ឆ្នាំ រស់នៅតំបន់ជនជាតិដើមភាគតិច ដែលមានគ្រួសារបម្លាស់ទីលំនៅ និងមានចម្ងាយឆ្ងាយពីសាលាមត្តេយ្យសិក្សារដ្ឋ ឬមត្តេយ្យសិក្សាសហគមន៍។ កម្មវិធីអនុវត្តតាមរយៈការចល័តដោយប្រើយានជំនិះផ្សេងៗ និងចល័តតាមរដូវកាលមាន៥ភូមិ ឃុំតាវែងក្រោម ឃុំតាវែងលើ ស្រុកតាវែង ឃុំកោះពាក្យ ស្រុកវើនសៃ និងឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី។ ការអប់រំកុមារតូចនៅតំបន់ជន

[6] https://khmer.voanews.com/a/education-sector-in-cambodia-struggles-to-emerge-but-more-works-need-to-be-done/4316829.html

ជាតិដើមភាគតិច ដែលមានទម្រង់ជាថ្នាក់មត្តេយ្យសិក្សាចល័តដោយ សហការជាមួយដៃគូអភិវឌ្ឍបានផ្តល់បានផ្តល់ឧត្តមានុវត្តន៍ សម្រាប់អនុវិស័យអប់រំកុមារតូច។[7]

ការអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាពនៅមត្តេយ្យសិក្សា បានអនុវត្តនៅខេត្តសៀមរាប បាត់ដំបង កំពង់ធំ ព្រៃវែង រតនគិរី ក្រចេះ និងរាជធានីភ្នំពេញ។ កម្មវិធីនេះ បានផ្សារភ្ជាប់ជាមួយមត្តេយ្យសិក្សារដ្ឋ១៨៣សាលា កើន៧ មានកុមារ៣៦៨នាក់ ស្រី១៦៧នាក់ កើន២០៣នាក់ ស្រី១១៨នាក់។ គ្រូមត្តេយ្យសិក្សារដ្ឋបានទទួលការបំប៉នការអប់រំបរិយាបន្ន ១៣០នាក់ ស្រី១២២នាក់ ថយ ១០៥នាក់ ស្រី១០១នាក់។ មត្តេយ្យសិក្សាសហគមន៍បានអនុវត្តកម្មវិធីអប់រំបរិយាបន្ន ៦៤កន្លែង កើន២៣ មានសិស្ស១៣៤នាក់ ស្រី ៤៩នាក់ កើន២៨នាក់។ គ្រូមត្តេយ្យសិក្សាសហគមន៍បានទទួលការបំប៉នការអប់រំបរិយាបន្ន២៤នាក់ ស្រី ២៤នាក់ ថយ១៧នាក់ ស្រី១៣នាក់។[8]

ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍ ពង្រីកវិសាលភាពអនុវត្តកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់ នឹងមត្តេយ្យ សិក្សាសហគមន៍៣៨៤ភូមិ មានមាតាបិតាជាបង្គោល៣៨៤នាក់ ស្រី៣១២នាក់ ដោយសហការជាមួយមេភូមិនិងគ្រូ មត្តេយ្យសិក្សាសហគមន៍។

ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍ សាកល្បងកម្មវិធីមត្តេយ្យសិក្សាបណ្តែតទឹកមាន៧កន្លែង និងមត្តេយ្យសិក្សាសហគមន៍តំបន់លិចទឹក៤កន្លែងនៅខេត្តកំពង់ឆ្នាំងនិងពោធិ៍សាត់ ដោយបានបណ្តុះបណ្តាលគ្រូមត្តេយ្យ សិក្សាសហគមន៍ក្នុងតំបន់គោលដៅស្របតាមស្តង់ដា៦១នាក់ ស្រី៥៧នាក់។[9]

សរុបមកមកក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងដុតដៃ ដុតជើងក្នុងការ គៀងគរកុមារឱ្យចូលរៀនបានច្រើន ជាពិសេសកុមារតូច តាមរយៈមធ្យោបាយនានាដែលបានរៀបរាប់ខាងលើ។

## ២.៣ ស្ថានភាពអប់រំកម្ពុជាបច្ចុប្បន្ន

បន្ទាប់ពីបានឆ្លងកាត់ការបំផ្លិចបំផ្លាញ ក្នុងរបបខ្មែរក្រហមប្រជាធិបតេយ្យមក ប្រទេសកម្ពុជាបានចាបផ្តើមកសាងជាតិឡើងវិញដោយបាតដៃទទេ ជាពិសេសការកសាងឡើងវិញនៅប្រព័ន្ធអប់រំជាតិគឺជាបញ្ហាចម្បងមួយដែលត្រូវយកចិត្តទុកដាក់បំផុត។ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៦៥ និង៦៦ បានចែងពីការធានាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលបានការអប់រំមួយដែលមានស្តង់ដារនិងមានគុណភាព។ រាជរដ្ឋាភិ បាលដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការបានយកចិត្តទុកធ្វើការសហការជាប់លាប់ជាមួយដៃគូអភិវឌ្ឍ ស្ថាប័នពាក់ព័ន្ធ សហគមន៍ និងឯកជនជាដើមដើម្បីអភិវឌ្ឍប្រព័ន្ធអប់រំនៅមត្តេយ្យសិក្សា។ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញកំណែទម្រង់វិស័យអប់រំចាប់តាំងពីឆ្នាំ២០០១មក ដោយបានអនុម័តគោលនយោបាយ ផែនការសកម្មភាព និងបទដ្ឋានជាច្រើនសំដៅបង្កើនការទទួលបានការអប់រំ និងពង្រឹង

[7] នាយកដ្ឋានអប់រំកុមារតូច, *របាយការណ៍បូកសរុបលទ្ធផលការងារអប់រំកុមារតូចឆ្នាំសិក្សា២០១៦-២០១៧ និងលើកទិសដៅ ឆ្នាំសិក្សា២០១៧-២០១៨*,ទំព័រ៥-៦ ត្រូវថ្ងៃចន្ទ-ពុធ ៣-៥កើត ខែចេត្រ ឆ្នាំកា នព្វស័ក ២៥៦១ ត្រូវថ្ងៃទី ១៩-២១ ខែមីនា ឆ្នាំ២០១៨

[8] -ដដែល-

[9] -ដដែល-

គុណភាពអប់រំរួមមាន ផែន ការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨) ច្បាប់ស្តីពីការអប់រំ (២០០៧) គោលនយោ បាយសាលាកុមារមេត្រី(២០០៧) និងផែនការគោល សាលាកុមារមេត្រី(២០១៥-២០១៨) គោលនយោបាយស្តីពីការអប់រំកុមារពិការ(២០០៨) គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច(២០១០) ស្តង់ដារបណ្ណាល័យមត្តេយ្យសិក្សា(២០១១) គោលនយោ បាយស្តីពីគ្រូបង្រៀន (២០១៣) ផែនការសកម្មភាពសម្រាប់គោលនយោបាយ ស្តីពីគ្រូបង្រៀន(២០១៥) និងគោលនយោបាយស្តីពីកិច្ចការការពារកុមារនៅសាលារៀន (២០១៦)។ យើងមានគោលនយោបាយ និងផែនការសកម្មភាពជាច្រើន ដែលជាវឌ្ឍនភាពដ៏ប្រសើររបស់យើង តែថាបញ្ហាប្រឈមនានាក៏នៅមានច្រើន ដូចជាថ្នាក់អនុវត្តមូលដ្ឋាន ចំណេះដឹងក្នុងការអនុវត្តនៅកម្រិតសាលារៀនជាដើម ដែលជាកត្តាគួរឱ្យភ័យខ្លាចបំផុតក្នុងវិស័យអប់រំរបស់យើង គឺថាវាកំពុងតែប្រឈមបញ្ហាខ្លាំងជាមួយភាពមិនប្រាកដប្រជាក្នុងការប្រែប្រួលក្នុងតំបន់និងពិភពលោកនេះ គឺការផ្លាស់ប្តូរកាន់តែកើនឡើង តម្រូវឱ្យថ្នាក់សម្រេចចិត្តមានសមត្ថភាពខ្ពស់ អ្នកអនុវត្តមានសមត្ថភាពឆ្លើយតប។

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងយកចិត្តទុកដាក់ចំពោះការអប់រំកុមារតូច ដោយបង្កើនការចូលរៀននៅថ្នាក់មត្តេយ្យសិក្សា វាជាមធ្យោបាយក្នុងការកសាងមូលដ្ឋានអប់រំ ដែលធ្វើឱ្យលទ្ធផលសិក្សារបស់កុមារកាន់តែប្រសើរឡើង ហើយកម្រិតនៃការបោះបង់ធ្លាក់ចុះ។ គេដឹងហើយថា កាលណាកុមារចូលរៀនយឺតពួកគេប្រឈមនឹងការបោះបង់ណាស់ ដោយសារតែកត្តាអាយុ និងលទ្ធផលសិក្សារបស់ពួកគេ។ ការអប់រំកុមារតូចមានភាពប្រសើរឡើងដោយមានកុមារតូចអាយុ៥ឆ្នាំចំនួន៦៤.០៧% ទទួលបានការអប់រំក្នុងឆ្នាំសិក្សា២០១៥-២០១៥ បើប្រៀបធៀបនឹង អត្រា៣៥% ឆ្នាំ២០០៨-២០០៩។[10] ប៉ុន្តែទោះជាយ៉ាងនេះក្តីមានកុមារអាយុ៣ឆ្នាំប្រហែល២០% និងកុមារអាយុ៤ឆ្នាំប្រហែល៣០%ប៉ុណ្ណោះ ដែលទទួលបានការអប់រំសម្រាប់កុមារតូចក្នុងឆ្នាំសិក្សា២០១៤-២០១៥។[11] ដូច្នេះយើងឃើញថាការចូលរៀនរបស់កុមារអាយុ៣ឆ្នាំដល់៥ឆ្នាំនៅមានកម្រិតទាបនៅឡើយ ជាពិសេស កុមារនៅតំបន់ជនបទ កុមារជនជាតិភាគតិច កុមារពិការ និងកុមារមកពីគ្រួសារក្រីក្រ។[12]

ការចុះឈ្មោះចូលរៀនវត្តមាន និងការបញ្ចប់ការសិក្សានៅមត្តេយ្យសិក្សានិងអនុវិទ្យាល័យនៅតែជាបញ្ហាប្រឈម។ ការស្រាវជ្រាវមួយនៅឆ្នាំ២០១២ បង្ហាញថា អ្នកផ្តល់ចម្លើយជាសិស្ស៩៣% និងមាតាបិតា៦៧% បាននិយាយថា ពួកគាត់ត្រូវចំណាយប្រាក់លើសម្ភារសិក្សា ដែលគួរជាការទទួលខុសត្រូវរបស់សាលា និងក្រសួងអប់រំ។ ការចំណាយនេះប្រហែល១១៩ដុល្លាសហរដ្ឋអាមេរិកក្នុងមួយឆ្នាំសម្រាប់សិស្សមួយនាក់[13]

[10] World Vision, ការអប់រំ-គោលនយោបាយសង្ខេបឆ្នាំ២០១៧,ទំព័រ២,ឆ្នាំ២០០៧

[11] -ដដែល-

[12] MoEYS(2016) Education Congress-p.18

[13] NEP(2012), Promoting Rights in School: The State of Children's Right in Cambodia Primary School

ដែលនេះជាកត្តាមួយដែលបណ្តាលឱ្យមានការបោះបង់ការសិក្សា ជាពិសេសសម្រាប់គ្រួសារក្រីក្រ មានកូនច្រើន មិនមានលទ្ធភាពឱ្យកូនបន្តការសិក្សាទៀតបាន។

ចំពោះគុណភាពអប់រំនៅមត្តេយ្យសិក្សា គឺកម្រិតខ្ពស់នៃអត្រាពិតនៃការសិក្សា និងកម្រិតខ្ពស់នៃអត្រាបញ្ចប់ការសិក្សាមិនប្រាកដ បង្ហាញពីគុណភាពនៃការអប់រំនោះឡើយ ហើយការចូលរៀនក្នុងប្រព័ន្ធអប់រំផ្លូវការ ក៏មិនធានាថាកុមារយកចិត្តទុកដាក់រៀនសូត្រផងដែរ។ វេទិកាសេដ្ឋកិច្ចពិភពលោកបានឱ្យពិន្ទុគុណភាពអប់រំនៅមត្តេយ្យសិក្សានៃប្រទេសកម្ពុជាត្រឹមតែ២.៩លើ៧ (កម្ពុជាស្ថិតក្នុងលេខរៀងទី១១៤ ក្នុងចំណោម១៤០ប្រទេស)។[14] មានកុមារអាយុ៣ឆ្នាំដល់៥ឆ្នាំចំនួន៣០%ប៉ុណ្ណោះ ដែលមានការីកលូតលាស់ផ្នែកគិតលេខ និងអានអក្សរត្រឹមត្រូវតាមកម្រិត។

## ២.៤ ទស្សនៈអប់រំសំខាន់ៗ

### ២.៤.១ សូក្រាត

សូក្រាត (៤៦៩-៣៩៩ មុន គ.ស) លោកមិនបានសរសេរស្នាដៃអ្វីទាំងអស់ អ្វីដែលបន្សល់ទុកដល់បច្ចុប្បន្ននេះគឺ ប្លាតុងជាសិស្សរបស់លោកជាអ្នកនិពន្ធទុកមក។

#### ក. ទ្រឹស្តីអំពីតម្លៃ

សូក្រាតជឿជាក់ថា មនុស្សមានចំណេះដឹងផ្សេងពីគ្នា គឺចំណេះដឹងចាំបាច់ និងចំណេះដឹងទូទៅ។ គាត់ ពន្យល់ថា យើងមានចំណេះដឹងទូទៅ (មិនសំខាន់)ច្រើន។ គាត់បានលើកឡើងពីចំណេះដឹងរបស់អ្នកត្បាញក្រមា ថាជាចំណេះដឹងចាំបាច់ ដោយគាត់បានអនុវត្តជាមួយក្រមារបស់គាត់ ប៉ុន្តែវាចាំបាច់សម្រាប់តែខ្លួនគាត់តែម្យ៉ាង ដែលជាអ្នកត្បាញក្រមា។ នេះមិនមែនជាចំណេះដឹងដែលសូក្រាតចង់បាននោះទេ។ ចំណេះដឹងដែលសំខាន់បំផុតគឺចំណេះដឹងទាំងឡាយណា ***ធ្វើឱ្យការរស់នៅល្អប្រសើរឡើង*** ។ គាត់លើកឡើងថា នេះពិបាករកចម្លើយខ្លាំងណាស់ វាមិនងាយស្រួលទេ ដោយសារមនុស្សជាច្រើនរស់នៅក្នុងភាពមិនខ្មាសអៀននិងអវិជ្ជា មិនមានអភិសម្មាចារ និងសីលធម៌សោះឡើយ (Brickhouse & Smith 1, p.30)។ តាមវិធីសាស្ត្រនៃការសួរសំណួរ គាត់បានចង្អុលបង្ហាញដល់សិស្សរបស់គាត់ស្វែងយល់ពីមនុស្ស ជាជាងប្រាប់ពួកគេពីអ្វីដែលពួកគេត្រូវដឹង។ គោលដៅនៃការអប់រំគឺស្គាល់ពីអ្វីដែលអ្នកអាចធ្វើបាន និងចាំបាច់ ចេះពីអ្វីដែលមិនទាន់ចេះ។

#### ខ. ទ្រឹស្តីនៃពុទ្ធិ

សូក្រាតអះអាងថា មានប្រភេទពុទ្ធិពីរផ្សេងពីគ្នា។ មួយគឺពុទ្ធិដំបូង (Ordinary Knowledge) វាជាព័ត៌មានដំបូងបំផុត និងជាក់លាក់(Brickhouse & Smith 1, p.118) គាត់អះអាងថា មានចំណេះដឹងជាច្រើន ដែលមិនបានផ្តល់នូវចំណេះដឹងពិតប្រាកដឡើយ វាមិនបានធ្វើឱ្យយើងក្លាយទៅជាអ្នកជំនាញ និងតម្លៃគតិបណ្ឌិត អ្វីឡើយ។ ចំណេះដឹងខ្ពស់ អាចនិយាយបានថាជាចំណេះដឹងដែលអាចកំណត់បាន (Definitional Knowledge)។ សូក្រាតគឺចាប់អារម្មណ៍ខ្លាំងក្នុងការកំណត់ពីស័ព្ទ (ពាក្យ) និងបញ្ញត្តិ។

[14] WEF(2015) Global Competitiveness Report, World Economic Forum

គាត់ទទួលស្គាល់ថា ចំណេះដឹងដែលអាចកំណត់បាន គឺជាចំណេះដឹងដែលអាចពិភាក្សាបែបទស្សនវិជ្ជាបាន។ ចំណេះដឹងខ្ពស់ អាចធ្វើឱ្យមនុស្សមានកុសល និងសច្ចភាព ដោយមិនវង្វេងជាមួយការបំភ័ន្តក្នុងជំនឿ គឺវាពោរពេញទៅដោយតក្កវិទ្យា និងគតិបណ្ឌិត។

### គ. ទ្រឹស្តីពីធម្មជាតិមនុស្ស

មនុស្សគឺអាត្មាខ្លួនឯង។ អាត្មាខ្លួនឯងគឺធម្មជាតិ។ ធម្មជាតិរបស់មនុស្សបង្កប់នៅទេពកោសល្យផ្សេងៗពីគ្នា វានឹងលេចឡើងបន្ទាប់ពីបានគាស់កកាយដោយវិធីនៃការអប់រំដែលមានប្រសិទ្ធភាព។ ធម្មជាតិរបស់មនុស្ស គឺមានបង្កប់នូវពាក្យ អាច ស្គាល់ពីកុសល ហើយក៏ស្គាល់វាដែរ អាចដើរតាមកុសល មនុស្សដែលមិនស្គាល់ច្បាស់ ពីកុសល ពួកគេមានសេរីភាពជ្រើសរើសយកអំពើអាក្រក់។

### ឃ. ទ្រឹស្តីនៃការសិក្សា

ការរៀន គឺជាស្វែងរកអ្វីដែលជាសច្ចភាព ហើយវាកើតឡើងបន្ទាប់ពីការសួរដេញដោល និងស្រាយពន្យល់ពីគតិបណ្ឌិត និងចំណេះដឹងផ្សេងៗ ហើយធ្វើឱ្យទទួលស្គាល់ថាខ្លួនគឺជាមនុស្សល្ងង់។ ជំនាញនិងចំណេះ ដឹងអាចកើតឡើងដោយៈ (១). ពន្យល់បកស្រាយឃ្លាប្រយោគ (២). ការធ្វើតេស្ត ឬការប្រឡង (៣).បង្ហាញពីភាពមិនឆ្លាតវៃ (៤). រៀនសូត្រពីអ្នកដែលឆ្លាតវៃ (៥). ត្រួតពិនិត្យមើលខ្លួនឯង (៦). ដាស់តឿន (៧). ត្រួតពិនិត្យការរស់នៅជាមួយអ្នកដទៃ (៨). ចំណេះដឹងពីសីលធម៌លំអិត(Benson p.17)

### ង.ទ្រឹស្តីនៃការផ្ទេរចំណេះ

គាត់លើកឡើងថា ការសន្ទនាគឺជាតិចនិកផ្សារភ្ជាប់រឿងផ្សេងៗ និងធ្វើឱ្យមានភាពរឹងមាំសម្រាប់ការពិភាក្សា។ សូក្រាតជឿជាក់ថា មិនមានមនុស្សណាម្នាក់ ឬសាលារៀនណាមួយ មានភាពប្រាកដប្រជា ឬមានគតិបណ្ឌិតក្នុងការបង្រៀននោះទេ។ សូក្រាត ក៏តែងតែគោរពកោតសរសើរគ្រូអស្ចារ្យផងដែរ។ វិធីសូក្រាតគឺជាគ្រូ ម្នាក់ដែលចេះសួរសំណួរ ដឹកនាំសិស្សស្វែងយល់ច្បាស់លាស់។ វាគឺជាវិធីបដិសំយោគ ដែលបង្ហាញពីការរិះរកបែបស៊ីជម្រៅ ស្វែងយល់ពីពហុភាពនៃភាពទូលំទូលាយរបស់ឯកសារ (Brickhouse & Smith 1, p.53)។

### ច. ទ្រឹស្តីពីសង្គម

សូក្រាតកើតនៅទីក្រុងអាថែន ប្រទេសក្រិក ដែលជាកន្លែងមួយល្អប្រសើរសម្រាប់ជីវិតឯកជនរបស់គាត់។ អ្វីដែលល្អប្រសើរ ដូចសូក្រាតបានលើកឡើងនេះគឺ គុណធម៌ ឬក៏ភាពឥតខ្ចោះ។ មនុស្សម្នាក់ដែលមានគុណ ធម៌គឺតែងតែជោគជ័យក្នុងរឿងធំៗក្នុងការដឹកនាំរដ្ឋ ការគោរពច្បាប់ ការគោរពឪពុកម្តាយ និងដូនតា និងរដ្ឋាភិបាលរបស់ពួកគេ។

### ២.៤.២ ឆ្លាតុខ

មួយឆ្នាំដំបូងនៃជីវិតរបស់កុមារគឺមានសារសំខាន់ណាស់ នេះជាសម្តីរបស់សូក្រាត ហើយជា ហេតុផលគាត់អះអាងថាកុមារមិនអនុញ្ញាតិឱ្យស្តាប់រឿងកុហក និងអាកប្បកិរិយាច្រងេងច្រងាង ដែលរឿងទាំងនេះវានឹងកើតមានចំពោះគាត់នៅថ្ងៃអនាគត។ យើងត្រូវគិតថាជីវិតគឺជាលទ្ធផលនៃការអភិវឌ្ឍ ដូចជាការរីកចម្រើនដែលមាននៅក្នុងភាវៈមួយៗ វាដូចជាផ្លែឈើដែលដុះចេញពីដើមឈើ ហើយដើម ឈើនោះដុះចេញពី

គ្រាប់របស់វា ហើយរឿងទាំងនេះវានឹងកើតឡើងដោយចាប់ផ្តើមឡើងនៅជំហានដំបូង។ ទាំងនេះជាគំនិតមួយដែលសំខាន់ ដោយសារជាចំណុចមួយដែលជឿជាក់បាននៅឆ្នាំដំបូងរបស់កុមារ។ ហេតុផលនេះ ការយកចិត្តទុកដាក់មើលថែរក្សាជាពិសេសក្នុងដំណាក់កាលដំបូងនៃជីវិតវាមិន មែនជារឿងស្មុគស្មាញណាស់ណាទេ តែជាអ្វីដែលយើងត្រូវធ្វើសម្រាប់ឱ្យកូនរបស់យើងល្អប្រសើរនៅថ្ងៃក្រោយ។ សម្រាប់កុមារដែលនឹងក្លាយជាពលរដ្ឋ និងជាអ្នកនយោបាយ។ ដំណាក់កាលនៃការអប់រំរបស់ប្លាតុងត្រូវបានបែងចែកជា៧ដំណាក់កាល ទៅតាមដំណាក់កាលជីវិតផ្សេងៗគ្នាដែលធ្វើឱ្យមានការអប់រំកាន់តែប្រសើរឡើង។

**ដំណាក់កាលអប់រំទី១** ចាប់ផ្តើមនៅពេលកុមារមានអាយុចាប់ពី៧ឆ្នាំឡើងទៅ។ នៅក្នុងដំណាក់នេះ កុមារត្រូវតែទទួលបានការអប់រំពីឪពុកម្តាយរបស់ពួកគេ ឬអ្នកអប់រំកុមារនៅក្នុងផ្ទះ។ យុវជនត្រូវប្រាប់កុមារពីរឿងនិទានទាក់ទងនិងសីលធម៌ ដើម្បីបណ្តុះឆន្ទៈល្អរបស់ពួកគេ។ នៅពេលកុមារមានអាយុចាប់ពី៦ឆ្នាំឡើងទៅ កុមារទាំងពីរភេទគួរតែលេងជាមួយគ្នា។ បន្ទាប់ពីអាយុ៦ឆ្នាំ គប្បីឱ្យពួកគេ លេងដាច់ដោយឡែកពីគ្នា។

**ដំណាក់កាលអប់រំទី២** ការអប់រំកុមារ ដែលមានអាយុ៧ឆ្នាំ។ មុខវិជ្ជាតន្ត្រី និងកាយ សម្ព័ន្ធត្រូវយកមកបង្រៀនដល់កុមារនៅក្នុងដំណាក់កាលនៃ អាយុ៧ឆ្នាំនេះ។ កីឡា និងល្បែងសិក្សា គឺមានសារសំខាន់សម្រាប់អភិវឌ្ឍកាយសម្បទា និងស្មារតីរបស់ កុមារ។

**ដំណាក់កាលអប់រំទី៣** គឺកុមារចាប់ពីអាយុ៧ឆ្នាំ ទៅដល់អាយុ២០ឆ្នាំ។ នៅក្នុងដំណាក់កាលនេះត្រូវបានបង្ហឹក និងអនុវត្តច្រើន កុមារគប្បីចូលរួមក្នុងកន្លែងអនុវត្តជាក់ ស្តែង។

**ដំណាក់កាលអប់រំទី៤** របស់ប្លាតុង ដំណាក់កាលនេះ គឺចាប់ពីអាយុ២០ឆ្នាំ ទៅដល់៣០ឆ្នាំ។ សម្រាប់ការបង្ហឹកនៅដំណាក់កាលនេះគឺត្រូវជ្រើសរើសឥរិយាបថជាពិសេស។ ពួកគេត្រូវបង្ហឹកផ្នែកគណិតវិទ្យា ដើម្បីឈានទៅរៀនបដិសំយោគ។ ការបង្ហឹកនេះត្រូវរយៈពេល១០ឆ្នាំ រហូតដល់អាយុ៣០ឆ្នាំ ការជ្រើសរើសផ្សេងទៀតត្រូវបានធ្វើឡើង។ ការជ្រើសរើសម្តងនេះ គឺត្រូវសិក្សាពីបដិសំយោគ។

**ដំណាក់កាលអប់រំទី៥** គឺចាប់ពីអាយុចាប់ពី៣០ឆ្នាំ ដល់អាយុ៣៥ឆ្នាំ រហូតដល់អាយុ៥០ឆ្នាំ ក្នុងវ័យនេះប្លាតុងសង្កត់ថាត្រូវតែរៀនមុខវិជ្ជាបដិសំយោគរនៅក្នុងវ័យចុងក្រោយ។ ហេតុផលគឺដោយសារតែភាព ចាស់ទុំគ្រប់គ្រាន់ក្នុងការបន្តសិក្សាពីមុខវិជ្ជានេះកាន់តែប្រសើរឡើង។

**ដំណាក់កាលអប់រំទី៦** ក្នុងដំណាក់កាលនេះ គឺចាប់ផ្តើមពីអាយុ៣៥ឆ្នាំ ដល់អាយុ៥០ឆ្នាំ ក្នុងដំណាក់កាលនេះគឺជាវ័យត្រៀមរួចរាល់ក្លាយខ្លួនទៅជាអ្នកដឹកនាំ ឬទស្សនវិទូ។ ក្នុងវ័យនេះ គាត់ត្រៀមខ្លួនជាស្រេចក្នុងការចូលប្រឡូកក្នុងសមរភូមិ និងជាមន្ត្រីរបស់រដ្ឋ ដើម្បីដឹកនាំយុវជនជំនាន់ក្រោយ។

**ដំណាក់កាលអប់រំទី៧** ដំណាក់កាលនេះគឺបន្ទាប់ពីអាយុ៥០ឆ្នាំ ក្នុងដំណាក់កាលនេះ គប្បីប្រព្រឹត្តអំពើកុសល ដែលជាសីលធម៌ គឺមានន័យថា គាត់ត្រូវគោរពច្បាប់រដ្ឋ ពុទ្ធិស៊ីជម្រៅបែបបដិសំយោគដើម្បីដឹកនាំជីវិតល្អប្រសើររបស់ខ្លួន ដើម្បីបង្កើតទស្សនវិជ្ជាផ្ទាល់ខ្លួន ដើម្បីចូលរួមក្នុងនយោបាយ និងដឹកនាំសម្រាប់ប្រជាជនរស់នៅក្នុងភាពល្អប្រសើរ។

យោងតាម **ប្លាតុង** បង្ហាញឱ្យយើងឃើញថាក្នុងវ័យដំបូងរបស់កុមារគឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបណ្តុះបណ្តាលអប់រំ ចិត្តគំនិត ស្មារតី សីលធម៌របស់ពួកគេក្នុងដំណាក់នេះ។ កុមារគឺជាធនធាន មួយសម្រាប់ប្រទេសជាតិដែលនឹងដឹកនាំប្រទេសទៅកាន់ភាពរីកចម្រើន និងជឿនលឿន។ កុមារត្រូវមាន ចំណេះដឹងខ្ពស់ជាងមនុស្សជំនាន់ដើម ដើម្បីដឹកនាំមនុស្សជំនាន់បន្តទៀត ទៅរកភាពភ្លឺស្វាង។ ក្នុងនាមជា ឪពុកម្តាយ ត្រូវដឹងថាកុមារត្រូវការបណ្តុះបណ្តាលជាប្រចាំ ដើម្បីឱ្យពួកគាត់កាន់តែរឹងមាំ និងស្វាហាប់ ឆ្លើយតបតម្រូវការចាំបាច់របស់សង្គមក្នុងសម័យទំនើប ប្រកួតប្រជែងទីផ្សារការងារ និងរស់នៅក្នុងភាពមិន ច្បាស់លាស់របស់សង្គមសម័យបច្ចុប្បន្ន។ កុមារត្រូវមានសីលធម៌ គុណធម៌ ដែលជាតម្លៃកម្រមួយរបស់ សង្គមដែលត្រូវតែបណ្តុះបណ្តាលដល់កុមារ។ ឪពុកម្តាយត្រូវបណ្តុះគុណធម៌ ដល់កុមារដើម្បីមានទុន ក្នុងការរស់នៅ និងការប្រកួតប្រជែងស្មើភាព ដោយយុត្តិធម៌ តម្លាភាពនៅក្នុងសង្គម។ សង្គមគឺជាគម្រូរបស់ មនុស្ស ដូចនេះសង្គមត្រូវតែប្រកាន់ភ្ជាប់នូវគោលការណ៍ច្បាប់ឱ្យបានតឹងរឹង ដោយបែងចែកឱ្យបានច្បាស់ លាស់រវាងទណ្ឌកម្ម និងរង្វាន់។ មានតែច្បាប់ទេ ដែលជួយឱ្យសង្គមមានសណ្តាប់ធ្នាប់ល្អ មនុស្សមានគម្រូ ល្អ សម្រាប់អនុវត្តជាប្រចាំ។

### ២.៤.៣ អារីស្តូត

**អារីស្តូត**គឺជាជននវានុវត្តផ្នែកអប់រំនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដែលប្រភពមកពីក្រិកបុរាណសិល្បៈទូទៅ និងកម្មវិធីសិក្សានិងវិទ្យាសាស្ត្រធម្មជាតិ ជីវវិទ្យា រុក្ខសាស្ត្រ សរីរវិទ្យា និងសត្វវិទ្យា។ គាត់បានសិក្សាជាមួយប្លាតុងអស់រយៈពេល២០ឆ្នាំនៅឯសាលា អាកាដឺមី និងបានលេចឡើងនៅក្នុងទស្សនវិជ្ជា សូក្រាតនៅក្នុងប្រព័ន្ធអប់រំបស្ចិមប្រទេស **អារីស្តូត** មានសមត្ថភាពចាប់យកនូវទស្សនវិជ្ជារបស់ផ្លាតុង មកបង្កើតជាទស្សនវិជ្ជារបស់ ខ្លួន។ **អារីស្តូត** ជឿជាក់អ្វីដែលមាននៅក្នុងគំនិតរបស់ប្លាតុង ហើយគាត់បានស្វែងរកភស្តុតាងដើម្បីបញ្ជាក់ពីគំនិតទាំងនោះឱ្យមានភាពពិតប្រាកដ។

**អារីស្តូត** កើតក្នុងឆ្នាំ៣៨៤ មុនគ.ស ក្នុងរដ្ឋ Stageira Chalcidice ក្នុងប្រទេស ក្រិកបុរាណ គាត់ជាគ្រូរបស់ Alexander the Great រយៈពេល៧ឆ្នាំ និងជាអ្នកបង្កើតសាលាដែលមានឈ្មោះល្បីល្បាញនៅទីក្រុងអាថែន ប្រទេសក្រិក គឺLyceum។ គោលបំណងរបស់សាលានេះគឺអភិវឌ្ឍអទិភាពរបស់សិស្សសម្រាប់វិចារណញាណ អាកប្បកិរិយា សីលធម៌ ផ្តល់នូវជំនាញ និងពុទ្ធិជាមូលដ្ឋាន។ សាលានេះគឺអភិវឌ្ឍនូវការរៀបចំ និងទម្លាប់សម្រាប់អនុវត្តវិចារណញាណ និងសីលវិជ្ជារបស់មនុស្ស។ សាលានេះបានរៀបចំអនាគតប្រជាពលរដ្ឋជាមួយពុទ្ធិតាមឋានានុក្រមឆ្លើយតបទៅនិងការប្រព្រឹត្តទៅនិងនយោបាយ សង្គម និងសេដ្ឋកិច្ចរបស់ពួកគេ។[15] ដំណើរជីវិតរបស់អារីស្តូតនៅជាមួយវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រនៅក្នុងទស្សនវិជ្ជាអប់រំរបស់គាត់ដែលជាផ្នែកធំមួយ នៃទស្សនវិជ្ជារបស់គាត់ដោយចាប់ ផ្តើមពីនិយមន័យពីមនុស្ស ថាមនុស្សជាសត្វមានវិចារណញាណ។ គាត់ជាអ្នកផ្តួចផ្តើមឱ្យមានវិទ្យាសាស្ត្រនៅសម្រាប់អឺរ៉ុប។ គាត់ជាអ្នកបែងចែកនូវប្រភេទនៃវត្ថុ និងអ្នកផ្តួចផ្តើមពីភាព ប្រាកដនិយមនៃធម្មជាតិ។ គាត់ត្រូវបានគេមើលឃើញថាជាអ្នកនាំ

[15] Barnes, J. (1982) *Aristotle*, Oxford: Oxford University Press. An lively and concise introduction to Aristotle's work.

មុខដល់សាស្ត្រា ចាប់នៅសាកលវិទ្យាល័យនៅសម័យទំនើប ដែលជឿជាក់លើការស្រាវជ្រាវ និងការបង្រៀន ដែលមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន។ អត្ថបទរបស់ គាត់មានជាច្រើនរួមមាន តក្កវិជ្ជា អស្តិរូបវិទ្យា ទស្សនវិជ្ជាគំនិត សីលវិជ្ជា ទ្រឹស្តីនយោបាយ សោភណ្ឌវិជ្ជា និងតារាវិជ្ជា ជាដើម។ ដូចប្លាតុងដែរ អារីស្តូតទទួលស្គាល់ពីភាពសំខាន់ចំពោះកុមារភាពដំបូងជាដំណាក់កាលផ្លូវការមួយ ចំពោះការអភិវឌ្ឍរបស់មនុស្ស។ គាត់បានបែងចែកដំណាក់កាលនៃការអប់រំជាបីដំណាក់កាលដូចជា ការអប់រំកម្រិតដំបូង ការអប់រំកម្រិតមធ្យម និងការអប់រំកម្រិតខ្ពស់។ នៅអាយុ៧ឆ្នាំ ដល់អាយុ១៤ឆ្នាំ កុមារគួរតែចូលរៀននៅអប់រំកម្រិត ដំបូង (បឋមសិក្សា) ហើយត្រូវទទួលបានការអប់រំពីកាយសម្ព័ន្ធ ការសរសេរ ការអាន តន្ត្រី និងការគូសរូប។ នៅអាយុ១៤ឆ្នាំ ដល់អាយុ២១ឆ្នាំ គួរចូលរៀននៅការអប់រំកម្រិតមធ្យម (អនុវិទ្យាល័យ) ដោយសិក្សាមុខវិជ្ជាបន្តពីបឋមសិក្សា ដោយបន្ថែមមុខវិជ្ជាមួយចំនួនដូចជា អក្សរសាស្ត្រ កំណាព្យ ល្ខោន ចំរៀង និង របាំជាដើម។ នៅក្នុងដំណាក់កាល៤ឆ្នាំចុងក្រោយត្រូវចំណាយពេលក្នុងលំហាត់សមយុទ្ធ បច្ចេកទេស និងយុទ្ធសាស្ត្រ។ ការអប់រំកម្រិតខ្ពស់ (វិទ្យាល័យ) គួរចាប់ផ្តើមនៅអាយុ២១ឆ្នាំ និងបន្តរហូតដល់សិស្សមានឆន្ទៈ និងលទ្ធភាពអាចធ្វើបាន។ ការអប់រំជាន់ខ្ពស់គឺ សម្រាប់តែសិស្សប្រុសតែប៉ុណ្ណោះ អារីស្តូតជឿជាក់ថាស្ត្រីមិនមានសមត្ថភាពទ្រាំនិងភាពលំបាកខ្លាំងក្នុងសិក្សាទេ។ **អារីស្តូត** ត្រូវបានគេជឿថា បានសរសេរស្នាដៃចំនួន១៥០ជាអភិប្រាយបែបទស្សនវិជ្ជា ដែលក្នុងនោះជាបញ្ហាទាក់ទងនិងទស្សនវិជ្ជា ជីវវិទ្យា រូបវិទ្យា សីលវិជ្ជា សោភណ្ឌវិជ្ជា នយោបាយ តារាវិជ្ជាជាដើម។ ឆ្លងតាមរយៈទស្សនវិទូអប់រំនានាបានផ្តល់គំនិតពីទ្រឹស្តីនៃការអប់រំបែបសីលធម៌ **អារីស្តូត** និង**រូស្សូ** បានបន្សល់ទុកស្នាដៃជាច្រើនដែលត្រូវបានគេទទួលស្គាល់នៅក្នុង វិស័យនេះ ទស្សនវិទូទាំងពីររូប បានសង្កត់ធ្ងន់ការអប់រំ បែបសីលធម៌ ដោយសារតែមាន ការវិវត្តនៃការអប់រំបែបសីលធម៌ជាធាតុសំខាន់នៅក្នុងបរិបទសង្គម និងប្រវត្តិសាស្ត្រ ក្នុងសហសម័យ។ ការអនុវត្តតាមគោលវិធីអប់រំរបស់ប្លាតុង អារីស្តូតបានបង្ហាញពីសីលធម៌ ដែលអាចអភិវឌ្ឍបានតាមរយៈការខ្វល់ខ្វាយ ចំពោះតម្រូវការ នៃដំណាក់កាលអភិវឌ្ឍនីមួយៗ ប៉ុន្តែផ្ទុយពីប្លាតុង អារីស្តូតបានបង្កើតទ្រឹស្តីការសិក្សាដែលពិចារណាទៅលើគោលបំណងចុងក្រោយនៃការសិក្សានិងដោយអនុវត្តតាមហេតុផលផ្សេងៗគ្នា។ ចំពោះរូស្សូបានប្រើប្រាស់គោលវិធីជាប្រព័ន្ធក្នុងការអប់រំបែបសីលធម៌ ដែលគេទទួលស្គាល់ថាជាដំណាក់ កាលនៃការអប់រំកុមារ ប៉ុន្តែមានតែទស្សនៈវិស័យតែមួយគត់ដែលជាមធ្យោបាយឱ្យកុមាររៀន គឺកើតចេញពីជំនឿខាងក្នុងខ្លួនដែលជាធម្មជាតិរបស់កុមារ និងធម្មជាតិនៃសីលធម៌។ ទស្សនវិទូទាំងពីរបានពិចារណាពីទ្រឹស្តី ក្នុងការអភិវឌ្ឍការអប់រំសីលធម៌ស្រដៀងគ្នា។ ការអប់រំគ្មានដែនកំណត់ទេ វានឹងបន្តរហូតឱ្យតែពួកគេមានលទ្ធភាពរៀន។ ការអប់រំបែបអវិជ្ជមានត្រូវបានគេការពារ មិនឱ្យមាន ពីព្រោះវាមានការឈឺចាប់ និងមិនមានប្រយោជន៍ជាដើម(Aristotle: Nicomachean Ethics Book II. Rousseau: La Nouvelle Heloise, 1761; Emile Book II, 1762)។ រូស្សូ បានពង្រីកបញ្ញត្តិនេះ ដោយបញ្ចូលវិធី បង្រៀនកុមារ គឺរៀនចេញពីអាកប្បកិរិយាមិនសមរម្យ ដែលគេទទួលស្គាល់ថាលទ្ធិវិបាកបែបធម្មជាតិ។ ទស្សនវិទូ ទាំងពីរជឿជាក់ថា នៅពេលដែលយើងបង្រៀនល្អ សិស្សនឹងក្លាយទៅជាល្អ ដូចនេះវាបានក្លាយទៅជាតម្លៃនិងគំរូនៃការអនុវត្តបែបវិជ្ជមាន និងជម្រុញការអភិវឌ្ឍទម្លាប់បែបវិជ្ជមាន។

គោលបំណងនៃការអប់រំ គឺអប់រំបែបសីលធម៌ដូចគ្នា។ គោលបំណងអប់រំសម្រាប់ **អារីស្តូត** គឺបណ្តុះបញ្ញា និងសីលគុណធម៌ពីមួយជំហានទៅមួយជំហាន ហើយត្រូវបានគេទទួលថា ការអភិវឌ្ឍបញ្ញាទាមទារបទពិសោធន៍និងពេលវេលា ការអភិវឌ្ឍសីលធម៌ ត្រូវតែទទួលបានការអប់រំតាមរយៈការតាំងចិត្ត និងការប្រតិបត្តិជាប្រចាំ។ គោលបំណងនៃការអប់រំបែបសីលធម៌ **អារីស្តូត** អះអាងថា គប្បីអភិវឌ្ឍទំលាប់វិជ្ជមានដើម្បីជម្រុញ អំពើជាកុសល និងបណ្តុះអភិសម្មាចារ្យ មកពីការស្គាល់ខុស ស្គាល់ត្រូវ និងសភាពនៃទម្លាប់(Nicomachean Ehics Book II)។ ចំពោះរូស្សូ មើលឃើញថា ឧត្តមភាពសីលធម៌ គឺជាគុណធម៌ និងជឿថាការអប់រំ គប្បីទទួលបានការបណ្តុះបណ្តាល ដូចគ្នានិងសីលធម៌ (Emile Book IV)។

ចំពោះ**អារីស្តូត** សុភមង្គល គឺជាគោលបំណងចុងក្រោយបំផុតនៃការអប់រំ និងជាមធ្យោបាយបង្កើតឱ្យមាន ផលិតភាពសង្គម (Emile Book IV) រូស្សូសង្កត់ធ្ងន់ទៅលើទៅការអភិវឌ្ឍកុសល ទាំងគុណភាពដែលមានទំនាក់ទំនងជាមួយការអភិវឌ្ឍគុណធម៌ ឬមានទំនាក់ទំនងអភិវឌ្ឍឥរិយាបថនឹងជឹង។ ទោះបីជាយ៉ាងនេះក្តី **អារីស្តូត** រំពឹងថា ការក្លាយទៅជាទស្សនវិទូ គឺជាការបន្តដំណើរការនៃវិចារណញ្ញាណបែបតក្កវិជ្ជា និងភាពហ្មត់ចត់ ខណៈពេលដែលរូស្សូរំពឹងខ្លាំងទៅលើលទ្ធផលនៃការប្រតិបត្តិ ដោយខ្វល់ខ្វាយគ្រប់កាលៈទេសៈទាំងអស់ យើងត្រូវបានគេសន្មត់ថា មានការបណ្តុះបណ្តាលសម្រាប់សង្គម ប៉ុន្តែត្រូវបានបង្រៀនក្នុងចំណោមពួកយើង ឱ្យមានជីវិតរស់នៅដោយសាមគ្គីភាពជាមួយគ្នា Emile Book IV)។ **អារីស្តូត** បានផ្តល់នូវការណែនាំជាច្រើន ក្នុងការអប់រំកុមារយ៉ាងយកចិត្តទុកដាក់ ទស្សនវិទូទាំងពីរ បានសង្កត់ធ្ងន់លើសារសំខាន់ការអភិវឌ្ឍសីលធម៌ផ្ទាល់ខ្លួន។ ការលើកឡើងតាមរយៈទស្សនវិទូទាំងពីរ គឺមានចំណង់យ៉ាងជ្រាលជ្រៅក្នុងការស្វែងយល់ពីខ្លួនឯង ឈានដល់អំពើសីលធម៌ដោយស្វ័យប្រវត្តិ។ នៅក្នុងក្របខណ្ឌរបស់រូស្សូ បុគ្គលម្នាក់ៗត្រូវតែមានសមត្ថភាពធ្វើសកម្មភាពដោយសេរី និងរក្សាយុត្តិធម៌ និងសង្គមដ៏ល្អ។

**អារីស្តូត** និង **រូស្សូ** មានលក្ខណៈស្រដៀងគ្នា ក្នុងការស្វែងយល់ពីជីវិតរបស់កុមារភាព ដូចជាក្រដាសស ដែលរងចាំនៅការគូសវាសតែប៉ុណ្ណោះ។ រាល់ការទទួលស្គាល់ ពីតួនាទីចាំបាច់ នៃបទពិសោធន៍ឥន្ទ្រីយារម្មណ៍ ដែលជាមូលដ្ឋានគ្រឹះនៃចំណេះដឹង (**អារីស្តូត**) ការអភិវឌ្ឍគំនិត (រូស្សូ) ។[16]

**២.៤.៤ ចន ដេវី**(John Dewey)

ចន ដេវី កើតនៅក្នុងឆ្នាំ១៨៥៩ នៅក្នុងស្រុកBurlington, ទីក្រុង Vermont (Gutek,2014)។ គាត់បានធំឡើងក្នុងគ្រួសារដែលមានភាពសកម្មនៅទំនាក់ទំនងសង្គមនៅទីក្រុង Vermont និងក្នុងចក្ខុវិស័យប្រជាធិបតេយ្យ ក្នុងសហគមន៍នយោបាយ ឥទ្ធិពលនេះបានធ្វើឱ្យគាត់ក្លាយជាអ្នកអប់រំនិងទស្សនវិទូ។ ដេវីជឿជាក់យ៉ាងមុតមាំទៅលើក្រុមមនុស្សធ្វើការជាមួយគ្នាក្នុងការដោះស្រាយបញ្ហានៅក្នុងមធ្យោបាយសន្តិភាពដោយឆ្លងកាត់ការពិភាក្សា សួរ ដេញដោល និងការសម្រេចចិត្ត។[17] ជំនឿរបស់ដេវីអំពីលទ្ធិប្រជាធិបតេយ្យសហគមន៍ និងការដោះស្រាយបញ្ហា នាំ ដល់ការអភិវឌ្ឍដល់សហគមន៍ និងទស្សនវិជ្ជានយោបាយរបស់គាត់។ ចន ដេវី ត្រូវបានគេទទួលស្គាល់ជាទស្សនវិទូ ដ៏មានឥទ្ធិពលក្នុងការអប់រំមកដល់បច្ចុប្បន្ននេះ។

---

[16] Jaeger, W. W. (1948) *Aristotle*, Oxford: Oxford University Press. Pretty much the standard work.
[17] Gutek,2014,p.78)

ចនដេវី គឺជាអ្នកប្រតិបត្តិនិយម អ្នកអភិវឌ្ឍនិយម អ្នកអប់រំ ទស្សនវិទូ និងអ្នកកំណែទម្រង់សង្គម។ គាត់ជឿ ជាក់យ៉ាងមុតមាំថា មនុស្សដែលមានទំនួលខុសត្រូវ បង្កើតបានពិភពលោកល្អប្រសើរក្នុងការរស់នៅ ឆ្លងកាត់ការបណ្តុះបណ្តាលនិងកំណែទម្រង់សង្គម។[18] បើតាម Schiro (2012) ដេវី ជឿជាក់លើការអប់រំ ការអប់រំគឺគ្រឿងផ្សំដ៏យក ចិត្តទុកដាក់បំផុតក្នុងការអភិវឌ្ឍសង្គម និងសីលធម៌។

ដេវីបានរៀបរាប់ពីការចម្រើនក្នុងការអប់រំដូចជា ផលិតផលដែលមិនពេញចិត្តជាមួយការអប់រំបែបប្រពៃណី ដែលដាក់បន្ទុកដល់សិស្ស មុខវិជ្ជាសិក្សា និងវិធីសាស្ត្រ។ លោកជឿជាក់ការអប់រំបែបប្រពៃណី គឺមានកម្រិតសម្រាប់ សិស្សវ័យក្មេង ការសិក្សាត្រូវផ្សារភ្ជាប់សង្គមជាមួយបទពិសោធន៍សិក្សាដែលមានការអភិវឌ្ឍសម្រាប់សិស្សក្មេងៗ។ ការអប់រំមានប្រសិទ្ធភាពដំបូងឡើយ ត្រូវមានអន្តរកម្មជាមួយសង្គមនិងការរៀបចំរបស់សាលារៀន ដោយពិចារណា ពីស្ថាប័នសង្គម។ ការអប់រំគឺជាដំណើរនៃការរស់នៅ មិនមែនជាការរៀបចំសម្រាប់ជីវិតអនាគតនោះទេ (Flinders &Thornton,2013.p.35;Gutek,2014)។ សាលារៀន និងថ្នាក់រៀនគប្បីជាតំណាងឱ្យស្ថានភាពជីវិតពិត អនុញ្ញាតិឱ្យសិស្សចូលរួមការរៀនតាមសកម្មភាពនានាដែលផ្លាស់ប្តូរទៅវិញទៅមក ភាពបត់បែន ផ្សេងៗគ្នានៅក្នុងសង្គម។ ការអប់រំបែបសិស្សមជ្ឈមណ្ឌលធ្វើឱ្យយើងជឿជាក់ថា ទ្រឹស្តីអប់រំរបស់ចន ដេវីបានគាំទ្រផ្នែកជាច្រើននៃរបៀបរៀនរបស់សិស្ស។ នៅក្នុងថ្នាក់រៀនសិស្សបែបមជ្ឈមណ្ឌល យើងនឹងឃើញពីរបៀបរៀនរបស់ចន ដេវីគឺទ្រឹស្តីអប់រំបែបសង្គម និងការអប់រំបែបសកម្មភាព។ គាត់បានបង្ហាញពីថ្នាក់រៀនដូចសង្គមទាំងមូលសម្រាប់សិស្សរៀន និងដោះស្រាយបញ្ហាជាមួយគ្នាដូចសហគមន៍មួយ។ នៅក្នុងថ្នាក់រៀនកុមារត្រូវមានគំនិតផ្ទាល់ខ្លួន សិស្សអាចមានការរវល់ច្រើនដើម្បីចេះដឹងដោយខ្លួនឯង ជាជាងដោយគ្រូបំផុស។ កុមារដែលបានរៀនដោយការធ្វើតាមរយៈថ្នាក់រៀនពួកគាត់ នឹងដោះស្រាយបញ្ហាតាមរយៈគោលវិធីវិធីនោះក្នុងសហគមន៍របស់គាត់។ នៅពេលគ្រូបង្រៀនរៀបចំផែនការសម្រាប់បង្រៀន ចំណាប់អារម្មណ៍របស់សិស្សនិងបញ្ចូលក្នុងការពិចារណា និងកម្មវិធីសិក្សាលម្អិតតាមមុខវិជ្ជារួមនឹង ការសិក្សាបែបគម្រោង (Project Learning) ។ បទពិសោធន៍អប់រំផ្តោតលើការលូតលាស់បញ្ញាសង្គម សព្វេតនា រូបសាស្ត្រ និងស្មារតីគ្រប់កុមារទាំងអស់ មិនត្រឹមតែលូតលាស់ផ្នែកការសិក្សាប៉ុណ្ណោះទេ (Schio,2013)។

នៅសហរដ្ឋអាមេរិកមានការលូតលាស់ចំនួនប្រជាសាស្ត្រជាទូទៅ និងមានការប្រែប្រួល ទាក់ទងនិងឥទ្ធិពល ថ្នាក់រៀន។ សាលារៀន និងគ្រូបង្រៀនសាធារណៈនៅក្នុងសហរដ្ឋអាមេរិកមានការប្រកួតប្រជែងដោយប្រឈមជាមួយបញ្ហាតម្រូវការទូទៅរបស់សិស្ស ដោយមានភាពខុសគ្នាទៅលើ យេនឌ័រ ជាតិពន្ធ សង្គម សេដ្ឋកិច្ច ប្រវត្តិរូប និងប្រភេទ តម្រូវការនៃការសិក្សារបស់ពួកគេ។ មូលហេតុទាំងនេះវាបានធ្វើឱ្យមានទំនាក់ទំនងយ៉ាងរឹងមាំរវាងវប្បធម៌ និងការសិក្សា អ្នកអប់រំគប្បីប្រើប្រាស់វិធីសាស្ត្របង្រៀនឆ្លើយតបនឹងវប្បធម៌ ដោយបញ្ចូលការរំពឹងទុកកម្រិតគ្រប់ សិស្សទាំងអស់ គោលវិធីនៃការរៀនខុសគ្នា និងជម្រុញឱ្យមានទំនាក់ទំនងគ្រួសារនិងសហគមន៍។ បច្ចុប្បន្ននេះការ អប់រំគឺជាបញ្ហាប្រឈមដ៏សំខាន់មួយ។ ជាមួយការបោះបង់ការ

[18] *-IBID-*

សិក្សាកម្រិតខ្ពស់ និងការលើកទឹកចិត្តកម្រិតទាប តាមសាលារៀននៅជនបទ ដូចនេះអ្នកអប់រំនៅតាមជនបទគួរមានគំនិតបើកចំហរក្នុងការបង្រៀនដោយប្រើប្រាស់គំនិតក្នុងថ្នាក់រៀនបានល្អ និងស៊ីជម្រៅ។

### ២.៤.៥ ម៉ុន តេស្សូរី

សាលា**ម៉ុនតេស្សូរី** គឺជាគំរូបន្ថែមដែលបង្ហាញពីកស្តុតាង ទ្រឹស្តីក្នុងថ្នាក់រៀននៅ សតវត្សទី២១របស់ ចន ដេវី។ វិធីសាស្រ្ត**ម៉ុនតេស្សូរី**ក្នុងការបង្រៀនមានជាប់ទាក់ទងជាមួយការរៀបចំកម្មវិធីសិក្សាបែបសិស្សមជ្ឈមណ្ឌល គ្រូត្រូវរៀបចំកម្មវិធីសិក្សាលម្អិតដោយយកចិត្តទុកដាក់បំផុតតាមរយៈការពិនិត្យសង្កេតលើសិស្សរបស់ពួកគេ។ កម្មវិធីសិក្សាលម្អិតគប្បីផ្អែកលើទេពកោសល្យ ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន និងតម្រូវការរូបសាស្រ្ត សង្គមរបស់សិស្ស។[19] ដេវីគឺជាធាតុសំខាន់នៃការសម្រេចចិត្តលើកម្មវិធីសិក្សាលម្អិត និងការរៀនបែបសកម្មភាពតាមតម្រូវការសង្គម និងចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្ស។

**ម៉ារៀ ម៉ុនតេស្សូរី** ( Maria Montessori ) ដូចនឹងចន ដេវីច្រើន ដោយនាងជឿជាក់ថាសាលាបែបប្រពៃណីគឺជាសាលាដែលមិនលូតលាស់ គឺមិនគាំទ្រដល់បរិស្ថានសិក្សា។ គាត់យល់ឃើញថា សាលារៀនបែបប្រពៃណីគឺជាសាលារៀនដែលមានការធុញទ្រាន់ និងតប់ ប្រមល់ ហើយវាមិនជម្រុញដល់គំនិតច្នៃប្រឌិតរបស់សិស្សទេ។ លើសពី នេះទៅទៀតគាត់បានធ្វើឱ្យសិស្សស្ថិតនៅក្នុងការរៀន គ្រូនៅក្នុងសាលារៀនបែបប្រពៃណីផ្តោតតែទៅលើការសរសើរ និងទណ្ឌកម្មក្នុងគោលបំណងបង្ខំសិស្សឱ្យផ្ចង់អារម្មណ៍ក្នុងការរៀនប៉ុណ្ណោះ។ គាត់ជឿជាក់ថាគោលវិធី ដែលផ្តោតទៅចំណាប់អារម្មណ៍របស់សិស្សនឹងនាំមកនូវជោគជ័យខ្លាំង។

យោងតាម Schiro (2013) គ្រូបង្រៀនបែបសិស្សមជ្ឈមណ្ឌលគាំទ្រដល់ចំណាប់អារម្មណ៍ និងតម្រូវការរបស់កុមារនៅមត្តេយ្យសិក្សា តែមិនមែនជាចំណាប់អារម្មណ៍របស់គ្រូ គណៈគ្រប់គ្រង ឬអ្នកនយោបាយទេ។ យោងតាម Peng & Md-Yunus (2014) គ្រូបង្រៀនបែបម៉ុនតេស្សូរី គឺត្រូវនៅជាមួយក្រុមសិស្សរយៈពេល៣ឆ្នាំ ដើម្បីធានា ថាគ្រូយល់ច្បាស់ពីតម្រូវការ ចំណាប់អារម្មណ៍ ការរីកចម្រើន និងការអភិវឌ្ឍរបស់សិស្ស ចំពោះថ្នាក់រៀនបែប **ម៉ុនតេស្សូរី** គឺមានបរិស្ថានដែលជម្រុញសកម្មភាពរាងកាយនិងសេរីភាពក្នុងការជ្រើសរើសសកម្មភាពសិក្សា អនុវត្តមានគោលវិធីសិស្សមជ្ឈមណ្ឌល ច្រើនជាងសាលារៀនបែបប្រពៃណីផ្តល់ជូន។

យោងតាម Lillard (2013) ការអប់រំបែបម៉ុនតេស្សូរី អនុញ្ញាតិឱ្យក្មេងៗភ្ជាប់ជាមួយការសិក្សាបែបលេងកំសាន្ត ដែលខុសគ្នាជាមួយសាលារៀនប្រពៃណីដែលបង្រៀនកុមារនៅពេលបច្ចុប្បន្ន។ ការរៀនបែបកំសាន្ត ត្រូវបានប្រើប្រាស់នៅក្នុងសាលារៀនម៉ុនតេស្សូរីពីព្រោះវាភ្ជាប់ទំនាក់ទំនងនិងការជម្រុញទឹកចិត្តខាងក្នុង។ ការប្រើប្រាស់ការលេង ជាផ្នែកមួយនៃកម្មវិធីសិក្សា គ្រូបង្រៀនម៉ុនតេស្សូរីគឺមិនប្រើប្រាស់រង្វាន់ក្នុងការជម្រុញទឹកចិត្តនោះទេ។ ការអប់រំបែបម៉ុនតេស្សូរី ក្មេងៗទទួលបានចំណេះដឹង សង្គម និងជំនាញជីវិតតាមរយៈបទពិសោធន៍នៃការលេងកំសាន្ត។

[19] Montessori,2013

### ២.៤.៦ គោលនយោបាយអប់រំ

ដើម្បីធានាបាននូវការអប់រំប្រកបដោយប្រសិទ្ធិភាព ភាពឆ្លើយតបទៅនឹងភាពមិនប្រាកដប្រជានៃការប្រែប្រួលទីផ្សារ និងសេដ្ឋកិច្ចក្នុងតំបន់សម័យឌីជីថលនៃសតវត្សទី២១នេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវនយោបាយអប់រំសំខាន់ៗចំនួនបី ដែល នយោបាយនេះអាចនាំមកនូវការសិក្សាពេញមួយជីវិត ការទទួលបានសេវាគាំទ្រនានា និងមានឱកាសទទួលបានការងារសមស្របមួយដើម្បីចិញ្ចឹមជីវិតនៅថ្ងៃអនាគត។ គោលនយោបាយនោះរួមមាន៖

**គោលនយោបាយទី ១ ៖** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ កុមារគ្រប់រូបនឹងទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សាទុតិយភូមិ និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធ ជម្រើសផ្សេងទៀតនឹងត្រូវផ្ដល់លទ្ធភាពឱ្យអ្នកទាំងនោះទទួលបានការអប់រំ។ ការបង្កើនចំនួនកុមារនិងយុវជន ឱ្យទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្ដោតលើសមធម៌ និងតំបន់និងក្រុមកុមារជួបការលំបាក។ ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់ទី១២ ឱ្យទទួលបាននូវចំណេះដឹងនិង ជំនាញក្នុងការគិតនិងហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សានៅក្នុងការបណ្ដុះបណ្ដាល បច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

**គោលនយោបាយទី ២ ៖** លើកកម្ពស់គុណភាពនិងភាពឆ្លើយតប កុមារនិងយុវជនគ្រប់រូបនឹងទទួលបានការអប់រំដែលមានភាពពាក់ព័ន្ធ និងប្រកបដោយគុណភាពដែលអាចឱ្យពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។ ការធានាថា ការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្ដល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយនឹងស្តង់ដារនៃផលសម្រេច ការពិនិត្យតាមដាន និងរបាយការណ៍។

**គោលនយោបាយទី ៣ ៖** ធានាភាពស័ក្ដិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ការផ្ដល់សេវាអប់រំប្រកបដោយគុណភាពនិងប្រសិទ្ធភាព។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងវិជ្ជាជីវៈនឹងផ្ដល់នូវតម្លៃដ៏ល្អបំផុត (ផ្ដោតលើលទ្ធផល) ទាន់ពេលវេលា និងពាក់ព័ន្ធនឹងការពិនិត្យតាមដាននិងរបាយការណ៍នៃលទ្ធផលទាំងនោះ ជាមួយនឹងយោបល់ត្រឡប់ ព្រមទាំងយន្តការសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី។ [20]

### ២.៤.៧ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមានចក្ខុវិស័យវែងឆ្ងាយ គឺកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់ កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកបដោយចីរភាពនិងសមធម៌ ការកែលម្អជីវភាពនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការការពារបរិស្ថាន ការលើកស្ទួយវប្បធម៌ និងអត្តសញ្ញាណជាតិ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោល

[20] www.google.com/ក្រសួងអប់រំយុវជន និងកីឡា វីគីភីឌា

ការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងគោលការណ៍គោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្សនិង មានកោសិការផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់និងវប្បធម៌ជ្រៅជ្រះ មានជីវភាព សមរម្យនិងមាន ការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងគ្រួសារ ព្រមទាំងមាន កិត្យានុភាពខ្ពស់ក្នុងឆាកអន្តរជាតិ។ ប្រទេសកម្ពុជាសង្ឃឹមថានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០។ នៅក្នុងនោះរដ្ឋាភិបាល កម្ពុជាបានកំណត់គោលដៅយុទ្ធសាស្រ្តចំនួន៤ គឺ ទី១ ធានាឱ្យមានកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំ ឆ្នាំប្រមាណ៧ភាគរយ ប្រកបដោយចីរភាព ទី២ បង្កើតការងារឱ្យបានកាន់តែច្រើនជូនដល់ប្រជាជន ពិសេស សម្រាប់ស្រទាប់យុវជន ទី៣ សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១ភាគរយ ក្នុងមួយឆ្នាំ និងទី៤ បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។ ក្នុងនោះរដ្ឋាភិបាលក៏បានផ្តោចិត្តទុកដាក់ខ្លាំងលើវិស័យអភិវឌ្ឍធនធានមនុស្ស ដែលនឹងធានាបាននៅ ការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ដែលកាន់តែបើកចំហរតាមរយៈ ទី១ ការបណ្តុះបណ្តាលពលករឱ្យ មានជំនាញនិងផលិតភាពខ្ពស់ តាមសេចក្តីត្រូវការនៃផ្សារ និងអាចបង្កើតតម្លៃបន្ថែមខ្ពស់ ទី២ រៀបចំក្របខណ្ឌ គតិយុត្តនិងកសាងឯកសារ ស្ថាប័នអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទី៣ លើកទឹកចិត្តវិស័យឯកជនឱ្យចូលរួម ក្នុងកិច្ចការនេះ និងទី៤ ការពង្រឹងគុណភាពនៃការអប់រំ លើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្រ្ត បច្ចេកវិទ្យា និង នវានុវត្តន៍។[21]

ដើម្បីឆ្លើយតបនឹងចក្ខុវិស័យជាតិ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ ២០១៤-២០១៨ នៅក្នុងវិស័យ អប់រំត្រូវមានការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព និងគុណធម៌ ជាកត្តាគន្លឹះសម្រាប់ ទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងការប្រកួតប្រជែងរបស់ប្រទេសចំពោះមុខ និងសម្រាប់អនាគត។ ក្នុងន័យនេះការ អភិវឌ្ឍធនធានមនុស្សគឺសំដៅទៅលើការកសាងសមត្ថភាពខាងចំណេះដឹង ចំណេះធ្វើ សហគ្រិនភាព ជំនាញ ការ ច្នៃប្រឌិត និងនវានុវត្តលើគ្រប់ផ្នែក គ្រប់វិស័យពិសេសវិស័យវិទ្យាសាស្រ្តនិងបច្ចេកវិជ្ជា ព្រមទាំងសមត្ថភាព ស្រាវជ្រាវនិងការអភិវឌ្ឍ។ ការលើកស្ទួយសុខភាព កាយសម្បទា សីលធម៌ ស្មារតីទទួលខុសត្រូវ និង មនសិការស្នេហាជាតិ និងវិជ្ជាជីវៈ ដោយគ្មានការរើសអើងខាង យេនឌ័រ រួមនឹងប្រព័ន្ធសុវត្ថិភាពសង្គមគត់មត់។[22]

យើងឃើញហើយថារយៈពេល៥ឆ្នាំ (២០១៤-២០១៨) រាជរដ្ឋាភិបាលកម្ពុជាបានខិតខំសម្រេច បាននូវសមិទ្ធផលសំខាន់ៗដែលជាគ្រឹះនៃការអភិវឌ្ឍជាតិទៅថ្ងៃមុខ ទោះបី យ៉ាងនេះក្តី ចំពោះធនធាន មនុស្សរបស់កម្ពុជានៅតែជាបញ្ហាប្រឈមដល់រដ្ឋាភិបាលត្រូវយកចិត្តទុកដាក់បន្តទៀត ដើម្បីឆ្លើយតបនឹង ការប្រកួតប្រជែងទីផ្សារនៅចំពោះមុខ និងទៅថ្ងៃអនាគត។ នៅក្នុងនោះកុមារតូច ត្រូវបានចុះឈ្មោះចូលរៀន

---

[21] ក្រសួងអប់រំ យុវជន និងកីឡា, *ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៤-២០១៨,*ខែមីនា ឆ្នាំ២០១៤, ទំព័រ១៣-១៤

[22] -ដដែល-ទំព័រ១៤

ច្រើនជាងមុន ពីព្រោះជាគ្រឹះ សំខាន់របស់មនុស្សសម័យថ្មីក្នុងការរស់នៅជាមួយគ្នា ការប្រាស័យទាក់ទង និងជំនាញទន់ ទាំងឡាយដែលទទួលបានពីសាលារៀន។

## ២.៤.៨ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាងនិងអភិវឌ្ឍធនធានមនុស្ស ប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។[23]

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនៅបេសកកម្មដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើដោយផ្តោតទៅការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា របស់ប្រទេសកម្ពុជាឱ្យឆ្លើយតបនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម វប្បធម៌របស់ កម្ពុជា និងការរីកចម្រើនផ្អែកលើនៅក្នុងតំបន់និងសកលលោក។

ទន្ទឹមនឹងគ្នានេះដែរក្រសួងមានវត្ថុបំណងរយៈពេលវែងគឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យនិងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋ របស់ខ្លួន។

រីឯវត្ថុបំណងចំពោះមុខរបស់ក្រសួងគឺធានាថាកុមារ និងយុវជនកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមរដ្ឋធម្មនុញ្ញនិងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺការមិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយ សម្បទា។[24]

ចក្ខុវិស័យរយៈពេលវែងរបស់ប្រទេសកម្ពុជា នឹងយកចិត្តទុកដាក់លើការផ្តល់សេវាអប់រំចាប់ពីអប់រំកុមារតូចគ្រប់រូបភាព ដែលជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការអប់រំនៅកម្រិតបន្តបន្ទាប់ទៀត និងយកចិត្តទុកដាក់ដល់សិស្សានុសិស្សនៅកម្រិតដំបូងនៃបឋមសិក្សាលើ បំនិនអាននិងលេខនព្វន្ត។ វិស័យអប់រំនឹងពង្រីកវិសាលភាពនៃការអប់រំសម្រាប់ទាំងអស់គ្នាពីបឋមសិក្សា៦ឆ្នាំទៅដល់អប់រំមូលដ្ឋាន៩ឆ្នាំ។ សិស្សានុសិស្សដែលបញ្ចប់ការសិក្សាអប់រំ មូលដ្ឋាននឹងត្រូវពិនិត្យមើលឧបនិស្ស័យក្នុងការជ្រើសរើសបន្តការសិក្សា នៅអប់រំមធ្យមសិក្សាចំណេះទូទៅ ឬជ្រើសរើសផ្នែកអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។ ការលើកកម្ពស់គុណភាពនៃការអប់រំ ក៏ត្រូវផ្តោតលើការលើកកម្ពស់គុណភាពរបស់ធាតុចូល ដំណើរការរៀន និង បង្រៀននិងលទ្ធផលសិក្សារបស់សិស្ស។ គុណភាពរបស់ធាតុចូលនឹងផ្តោតសំខាន់លើគុណវុឌ្ឍិគ្រូបង្រៀន ដែលនឹងត្រូវបង្កើនរូបមន្តពី ១២ បូក ២ ទៅដល់ ១២ បូក ៤នៅឆ្នាំ២០២០។ គុណភាពរបស់កម្មវិធីសិក្សានៅអប់រំចំណេះទូទៅនិងឧត្តមសិក្សាឱ្យស្របនឹងគុណភាពស្តង់ដារអាស៊ាន។

[23] -ដដែល-ទំព័រ១៤

[24] -ដដែល-ទំព័រ១៥

### ២.៤.៩ ផែនការអភិវឌ្ឍន៍ជាតិវិស័យអប់រំ ឆ្នាំ២០១៩-២០២៣

នៅក្នុងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ កុមារតូចត្រូវបានក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចរាជរដ្ឋាភិបាលយកចិត្តទុកដាក់ខ្លាំងនិងអទិភាពទី១ក្នុង ចំណោមសូចនាករសំខាន់ដទៃទៀត។ ភាគរយកុមារអាយុ៥ឆ្នាំ ទទួលបានការអប់រំ នៅឆ្នាំ២០១៧-២០១៨ ចំនួន៥៨,០ភាគរយ កើនដល់៥៩,៣ ភាគរយនៅឆ្នាំ២០១៨-២០១៩ កើន ឡើងដល់៦០,៦ភាគរយនៅឆ្នាំ២០១៩-២០២០ កើនឡើងដល់ ៦១,៩ភាគរយ ឆ្នាំ២០២០-២០២១ នឹងកើនដល់៦៣,២ភាគរយនៅឆ្នាំ២០២១-២២ និង៦៤,៥ភាគរយ នៅឆ្នាំ២០២២-២០២៣។[25]

យោងតាមសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣នេះ បង្ហាញឱ្យ ឃើញថាចំនួន កុមារតូចនៅអាយុ៥ឆ្នាំទទួលបានការអប់រំរហូត៦៤,៥ភាគរយនៅឆ្នាំ២០២៣ គឺជាចំនួនមួយច្រើន ដែលធ្វើឱ្យកុមារតូចជាច្រើននឹងទទួលបានការអប់រំដំបូងមុនឈានដល់បឋមសិក្សា។

### ២.៥ អំពីសាលាមត្តេយ្យសិក្សា៨មីនា

### ក. ប្រវត្តិសាលា

សាលាមត្តេយ្យ៨មីនាចាប់ផ្តើមរៀបចំនៅថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៨៥ ទទួលសិស្សឱ្យចូល រៀន នៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៨៥ មានបុគ្គលិកចំនួន០៥នាក់ នាយិកា០១នាក់ គ្រូឈរ ថ្នាក់០២នាក់ និងស្ត្រីថែទាំកុមារ០២នាក់។ សិស្សមានចំនួន១៤៣នាក់ ចែកជាកម្រិតខ្ពស់ ៥០នាក់ ស្រី២៥នាក់ កម្រិតមធ្យម៤០ នាក់ ស្រី២០នាក់ និងកម្រិតទាប៥៣នាក់ ស្រី២០ នាក់។ ពេលបច្ចុប្បន្ននេះ សាលាមត្តេយ្យ៨មីនា មានបុគ្គលិកសរុបចំនួន២០នាក់ ក្នុងនោះ មាននាយិកា០១នាក់ គ្រូប្រចាំថ្នាក់១៧នាក់ ស្រី១៧នាក់ បុគ្គលិកទីចាត់ការ០២នាក់ ស្រី០២នាក់។ ចំនួនសិស្សមាន៤៤៤នាក់ ក្នុងនោះស្រី១៩១នាក់។

### ខ.ចក្ខុវិស័យ បេសកកម្ម ផែនការសកម្មភាព

សម្រាប់ពេលបច្ចុប្បន្ននេះ សាលាមត្តេយ្យ៨មីនា បានដាក់ចេញនូវចក្ខុវិស័យច្បាស់ លាស់ដើម្បីដឹកនាំសាលាមួយនេះឈានទៅដល់សាលាកុមារមេត្រីនៅថ្ងៃអនាគត។ ចក្ខុវិស័យ របស់សាលាមាន៣ ចំណុចសំខាន់ៗដូចខាងក្រោម៖

ទី១ បំប៉នបន្ថែមជានិច្ចលើការអភិវឌ្ឍសមត្ថភាព ចំណេះដឹងរបស់គ្រូ រួមទាំងសមត្ថភាពការផ្ទេរចំណេះដឹងពីគ្រូទៅកុមារតូចៗ។

ទី២ លើកកម្ពស់គុណភាពការសិក្សារបស់កុមារឱ្យបានគ្រប់កំរិតថ្នាក់។

ទី៣ លើកកម្ពស់ការអប់រំកុមារ គ្រូ ផ្នែកវិន័យ សីលធម៌ សុជីវធម៌ក្នុងការរស់នៅ ក្នុង សង្គម គ្រួសារ សាលារៀន និងសហគមន៍។ ចំពោះបេសកកម្មដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ សាលាបានដាក់ចុះនៅបេសកកម្មចំនួន៣ដូចខាងក្រោម៖

---

[25] រាជរដ្ឋាភិបាលកម្ពុជា,*សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ២០១៩-២០២៣*, ១១កក្កដា ២០១៩ ទំព័រទីxii

ទី១ ប្រមូលកុមារដែលមានអាយុ៣ឆ្នាំដល់៥ឆ្នាំចូលរៀនឱ្យអស់លទ្ធភាព

ទី២ អប់រំបណ្តុះបណ្តាលគ្រូ កុមារ ឱ្យមានសីលធម៌ សុជីវធម៌ ការអភិវឌ្ឍ

ទី៣ អភិវឌ្ឍសាលារៀនទៅជាសាលាដែលស្តង់ដារពេញលេញនៅឆ្នាំ២០២០។

គ.គុណសម្បត្តិរបស់សាលាមត្តេយ្យ៨មីនា

សាលាមត្តេយ្យ៨មីនា គឺជាថ្នាលបណ្តុះបណ្តាលកុមារដែលមានអាយុ៣ឆ្នាំ ដល់៥ឆ្នាំ ចាប់ពីឆ្នាំ ១៩៨៥មក ដល់បច្ចុប្បន្ន គិតមកដល់ឆ្នាំ២០១៩មានរយៈពេល៣៤ឆ្នាំមក ហើយ។ សាលាបច្ចុប្បន្នមាន សិស្សសរុបទាំង៣កម្រិតសិក្សា មានចំនួន៤៤៥នាក់។ ចំពោះ ការសិក្សានៅសាលាមាន១វេន និង២វេន។ ឪពុកម្តាយ អាណាព្យាបាលអាចជ្រើសរើសវេន សិក្សាណាមួយដែលពួកគាត់ចង់បាន ជាពិសេសសាលាមាន គ្រូស្រីរហូតដល់១៧នាក់ ដែលគ្រូឈរថ្នាក់មានគរុកោសល្យច្បាស់លាស់ មានបទពិសោធន៍ក្នុងការបង្រៀន កុមារត្រឹមត្រូវ។ សាលាមត្តេយ្យ៨មីនា គឺជាសាលាមត្តេយ្យសិក្សារដ្ឋដែលបានអនុវត្តតាមកម្មសិក្សារដ្ឋត្រឹម ត្រូវច្បាស់លាស់ និងមានស្តង់ដារសាលាមត្តេយ្យល្អ កំពុងអនុវត្តជាប្រចាំ និងឈានដល់ការសម្រេចបានស្តង់ ដារពេញលេញនៅឆ្នាំ២០២០ខាងមុខ បើយោងតាមបេសកកម្មរបស់សាលាដែលបានដាក់ជូន។ សាលាមាន ទីធ្លាស្អាត ទូលាយ មានរបងឃាំង មិនឱ្យចេញមកក្រៅ មានសុវត្ថិភាពល្អ ទីតាំងសមស្របនៅក្នុង រាជធានីភ្នំពេញ។

## ២.៦ សាលាមត្តេយ្យសិក្សារដ្ឋល្អ

សាលាមត្តេយ្យសិក្សារដ្ឋល្អ គឺជាសាលាមត្តេយ្យសិក្សារដ្ឋដែលអនុវត្តស្តង់ដាអប្បបរមាសម្រាប់ថ្នាក់ មត្តេយ្យសិក្សារដ្ឋប្រកបដោយជោគជ័យ។ សាលាមត្តេយ្យ៨មីនា គឺជាសាលាមត្តេយ្យសិក្សារដ្ឋដែលបាន កំពុងអនុវត្តស្តង់ដាអប្បរមាសម្រាប់មត្តេយ្យសិក្សារដ្ឋដូចខាងក្រោម៖

**ផ្នែកទី១៖ ការធ្វើផែនការ និងការពិនិត្យតាមដាន**

ក. សូចនាករនិងលទ្ធសកម្មភាព

១. ថ្នាក់រៀនមានផែនការអភិវឌ្ឍ

- ថ្នាក់រៀនមានស្ថិតិទិន្នន័យកុមារអាយុ៣-៥ឆ្នាំត្រឹមត្រូវច្បាស់លាស់
- មានផែនការសកម្មភាពប្រចាំឆ្នាំតាមទម្រង់ណែនាំ (តម្រូវការសម្ភារឧទ្ទេស សម្ភារតុបតែងថ្នាក់ និងសម្ភារល្បែងក្នុងនិងក្រៅថ្នាក់រៀនត្រូវដាក់ចូលទៅក្នុងផែនការផងដែរ)
- តម្រូវការធនធានក្នុងការអនុវត្តតាមស្តង់ដាពេញមួយឆ្នាំ

២.នាយក នាយិកាបានសង្កេតថ្នាក់ច្រើនដង ឬមួយដងក្នុងមួយសប្តាហ៍

- មានអនុសាសន៍និងកំណត់ហេតុរបស់អ្នកសង្កេតក្នុងសៀវភៅអនុសាសន៍របស់គ្រូមត្តេយ្យសិក្សា(តិចជាងបីដងក្នុងមួយខែ ឬមិនបានធ្វើសោះ មិនបាន ទទួលមិនពិន្ទុទេ)

៣.នាយក នាយិកាបានផ្តល់ជំនួយដល់គ្រូបង្រៀនលើបច្ចេកទេស ការផលិតសម្ភារឧទ្ទេសបង្រៀន និងរៀន រដ្ឋបាលថ្នាក់ ជំនួយស្មារតី និងដោះស្រាយបញ្ហាសង្គម

- មានកំណត់ហេតុ និងអនុសាសន៍របស់អ្នកសង្កេតនៅក្នុងសៀវភៅប្រជុំ ទទួលសម្ភារឯកសារ និងអនុសាសន៍របស់គ្រូមត្តេយ្យសិក្សាដើម្បីតាមដាន នាយក/នាយិកា នាយករង/នាយិការង ឬ ប្រធានក្រុមបច្ចេកទេសដែលបាន ផ្តល់ជំនួយដល់គ្រូបង្រៀនលើផ្នែកបច្ចេកទេសបង្រៀន/ ផលិតសម្ភារបង្រៀន និងរៀន ការងាររដ្ឋបាលថ្នាក់ ជំនួយស្មារតី ដោះស្រាយបញ្ហាសង្គម អនាម័យ សុខភាពចំណីអាហារកុមារ និងផ្សេងៗ
- គ្រូមត្តេយ្យសិក្សាបានអនុវត្តតាមអនុសាសន៍ណែនាំបានត្រឹមត្រូវ

៤.មានការប្រជុំបច្ចេកទេសប្រចាំសប្តាហ៍

- មានកំណត់ហេតុប្រជុំបច្ចេកទេសប្រចាំសប្តាហ៍របស់គ្រូមត្តេយ្យសិក្សាដោយ ផ្អែកតាមផែនការរបស់សាលា

៥.ការប្រជុំមានភាពទៀងទាត់តាមការឯកភាព

- មានកំណត់ហេតុក្នុងសៀវភៅប្រជុំទូទៅ និងប្រជុំបច្ចេកទេសប្រចាំសប្តាហ៍ របស់គ្រូមត្តេយ្យសិក្សាដោយផ្អែកតាមផែនការរបស់សាលា (បើមិនទៀងទាត់មិនបានពិន្ទុទេ)

៦.ការប្រជុំភាគច្រើនផ្តោតលើការអនុវត្តបទបញ្ជា បច្ចេកទេសបង្រៀន ការងាររដ្ឋបាល ការផលិត និងប្រើប្រាស់សម្ភារឧបទ្ទេសបង្រៀននិងរៀន

- មានកំណត់ហេតុក្នុងសៀវភៅប្រជុំទូទៅ និងប្រជុំបច្ចេកទេសរបស់គ្រូបត្តេយ្យស្តីពីការប្រជុំលើការអនុវត្តខ្លឹមសារបទបញ្ជា បច្ចេកទេសបង្រៀនការងាររដ្ឋបាល ការផលិតសម្ភារឧទ្ទេសបង្រៀននិងរៀន(បើផ្តោតលើបញ្ហាទូទៅមិន បានពិន្ទុទេ)

## ផ្នែកទី២៖ គ្រូបង្រៀន ការបង្រៀន និងរៀន

ខ.សូចនាករ និងលទ្ធសកម្មភាព

៧. មានកិច្ចតែងការបង្រៀនតាមការណែនាំ

- មានកិច្ចតែងការបង្រៀនគ្រប់មុខវិជ្ជាទៅតាមកម្មសិក្សាប្រចាំខែ ថ្ងៃ (កិច្ចតែងការបង្រៀនត្រូវចុះហត្ថលេខាពីនាយក នាយិកាសាលា)។

៨. ការបង្រៀន ប្រើកិច្ចតែងការជាប់លាប់គ្រប់មុខវិជ្ជា

- ការបង្រៀនត្រឹមត្រូវតាមកម្មវិធីសិក្សាគ្រប់មុខវិជ្ជា

៩. ការបង្រៀនគោរពបានតាមកាលវិភាគ និងកម្មវិធីសិក្សាបានទៀងទាត់

- ការបង្រៀនអនុវត្តតាមកាលវិភាគ និងកម្មវិធីសិក្សាដែលសាលាបានឯកភាព និងអនុញ្ញាតឱ្យគ្រូប្រចាំថ្នាក់អនុវត្តជារៀងរាលថ្ងៃ ខែ និងឆ្នាំ

១០. ការបង្រៀនមានប្រើសម្ភារឧបទេសបង្រៀនិងរៀន

- មានសម្ភារបង្រៀននិងរៀនគ្រប់តាមមុខវិជ្ជាបង្រៀនប្រចាំថ្ងៃរួចដាក់សម្ភារ ទាំងនោះតាមជ្រុងថ្នាក់រៀននីមួយៗ

- មានសម្ភារសម្រាប់កុមារអនុវត្តជាក្រុម ជាបុគ្គល

១១. ការរៀបចំថ្នាក់រៀនតាមស្តង់ដា

- គ្រូបង្រៀនត្រូវរៀបចំតាមឧបសម្ព័ន្ធដែលមានភ្ជាប់ជូនដូចខាងក្រោម៖

    ក. ការរៀបចំតាមជញ្ជាំងខាងមុខ

    ខ. ការរៀបចំតាមជញ្ជាំងសងខាងនិងខាងក្រោយ

    គ.ការរៀបចំផ្ទៃលំហខាងលើ

    ឃ.ការរៀបចំផ្ទៃខាងក្រោម

    ង.ការរៀបចំថ្នាក់រៀនមាន៥ជ្រុង មានដូចជាជ្រុងវិទ្យាសាស្ត្រ ជ្រុងអនាម័យ ជ្រុងសិល្បៈ ជ្រុងល្បែង និងជ្រុងសិក្សា

១២.ថ្នាក់រៀនរៀបចំសៀវភៅនិងបញ្ជីផ្សេងៗតាមការណែនាំ

- គ្រូរៀបចំឱ្យមានសៀវភៅរដ្ឋបាលចំនួន៨មុខ និងបញ្ជីចំនួន៣

១៣. ការធ្វើតេស្តទៀងទាត់ ចំនួន០៣ដងក្នុងមួយឆ្នាំ(កុមារអាយុ៥ឆ្នាំ)

- បានធ្វើតេស្តទៀងទាត់ក្នុងទម្រង់១៩ក និង១៩ខ ត្រូវអនុវត្ត៣ដងក្នុង១ឆ្នាំ ចំពោះកុមារអាយុ៥ឆ្នាំ មាន១៨សូចនាករ
    - លើកទី១ (សប្តាហ៍ទី២ខែវិច្ឆិកា)
    - លើកទី២(សប្តាហ៍ទី២ខែកុម្ភៈ)
    - លើកទី៣(សប្តាហ៍ទី៣ខែកក្កដា)
- បានសង្កេតសមត្ថភាពរបស់កុមារម្នាក់ៗតាមរយៈការធ្វើតេស្ត
- បានយកលទ្ធផលតេស្តទៅរៀបចំផែនការសម្រាប់ខែ ឬត្រីមាសបន្ទាប់

១៤.គ្រូបង្រៀនបានបំប៉នដំបូង

- គ្រូបង្រៀនទទួលបានការបំប៉នដំបូងរយៈពេល៣០ថ្ងៃស្តីពីចំណេះដឹងទូទៅ ចំណេះដឹងរដ្ឋបាល ការងារបច្ចេកទេស និងការផលិតសម្ភារឧទ្ទេសសម្រាប់ មត្តេយ្យសិក្សា

១៥.គ្រូបង្រៀនបានបំប៉នវិញតាមកម្មវិធីសិក្សាថ្មី

- បានបំប៉នឡើងវិញតាមកម្មវិធីសិក្សាថ្មីរយៈពេល១៥ថ្ងៃ រឺងខ្លឹមសារបំប៉នទៅតាមកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មីៗ

១៨. មាតាបិតាបានចូលរួមការអប់រំមាតាបិតា

- បានរៀបចំចងក្រងក្រុមមាតាបិតាកុមារតាមថ្នាក់រៀន
- មាតាបិតារបស់កុមារបានចូលរួមការអប់រំមាតាបិតាតាមការរៀបចំរបស់សាលារៀន
- មានកត់ត្រាក្នុងកំណត់ហេតុ សៀវភៅរបស់សាលាស្តីពីការងារចូលរួមអប់រំមាតាបិតា

## ផ្នែកទី៣ ការគ្រប់គ្រងទូទៅ

១៩. នាយក នាយិកាបានចុះពិនិត្យការបង្រៀនឆ្នាំមុនយ៉ាងតិចចំនួន៧ដង

- មានកំណត់ហេតុអំពីពេលវេលានិងខ្លឹមសារពិនិត្យការបង្រៀននិងឧបករណ៍សង្កេតថ្នាក់ឆ្នាំមុន

២១.គណកម្មការទ្រទ្រង់សាលារៀនមានដំណើរការ មានការប្រជុំទៀងទាត់ និងជួយ គាំទ្រដោះស្រាយបញ្ហាដែលបានឯកភាពគ្នា

- មានកំណត់ហេតុ សៀវភៅប្រជុំរបស់គ្រូស្តីពីការប្រជុំតាមដានផែនការរបស់ គណៈកម្មការទ្រទ្រង់សាលារៀនដែលគាំទ្រនិងដោះស្រាយបញ្ហាផ្សេងៗដែលមាននៅក្នុងសាលាឬថ្នាក់រៀនក្នុងនោះក៏មានផ្តល់ជំនួយគាំទ្រសម្រាប់ លើកកម្ពស់ដល់សុខភាព អនាម័យ ចំណីអាហាររបស់កុមារនិងកម្មវិធីលើក កម្ពស់សុខភាពជាដើម។

២២.ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌបានចុះពិនិត្យតាមដាននៅឆ្នាំមុនយ៉ាងតិច ៣ ទៅ៥ដង។

- មានកំណត់ត្រាក្នុងកំណត់ហេតុ សៀវភៅអនុសាសន៍របស់ថ្នាក់ការិយាល័យ អប់រំ ក្រុង ស្រុក ខណ្ឌធ្លាប់បានចុះពិនិត្យតាមដាននៅឆ្នាំមុន ទុកនៅក្នុងថ្នាក់ របស់គ្រូមត្តេយ្យ។

## ផ្នែកទី៤៖ ការរាយការណ៍និងព័ត៌មានត្រឡប់

២៤.គ្រូបន្ទុកថ្នាក់បានរៀបចំរបាយការណ៍ឆមាសតាមគំរូពេញលេញ ហើយផ្ញើទៅកាន់នាយិកាទាន់ពេលវេលា

- បានបំពេញរបាយការណ៍តាមគំរូ រួចបញ្ជូនតាមកាលកំណត់ទៅនាយិកាសាលា១ឆ្នាំ៣ដង
- មានសំណៅរបាយការណ៍ត្រឹមត្រូវមុនៗសម្រាប់តាមដាន

២៥.របាយការណ៍មានទិន្នន័យត្រឹមត្រូវតាមតម្រូវការនិងមានបច្ចុប្បន្នភាព

- បានបញ្ចូលទិន្នន័យត្រឹមត្រូវពិតប្រាកដនិងទាន់ពេលវេលាតាមតម្រូវការ ហើយប្រែប្រួលទៅតាមពេលវេលានិងស្ថានភាពជាក់ស្តែង

២៦.នាយិកាយល់ឃើញថាត្រូវធ្វើអ្វីដើម្បីឱ្យកុមារមានការអភិវឌ្ឍគ្រប់ផ្នែកនិងលទ្ធផលសិក្សារបស់កុមារកើនឡើង

- មានកំណត់ហេតុ ឬសៀវភៅអនុសាសន៍ដែលនាយិកាផ្តល់ចាប់ពី២ចំណុច ឡើងស្តីពីនីតិវិធីជួយឱ្យកុមារអភិវឌ្ឍគ្រប់ផ្នែកដោយបញ្ចូលផ្នែកសុខភាព អនាម័យ ចំណីអាហារ និងលទ្ធផលសិក្សា
- បានយកយោបល់របស់នាយក នាយិកាទៅដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍ ថ្នាក់រៀន

## ផ្នែកទី៥ ទីធ្លា និងសម្ភារលេងក្រៅថ្នាក់រៀន

២៨. ទីធ្លាសម្រាប់កុមារលេងមានលក្ខណៈងាយស្រួល សមស្របទូលាយមាន អនាម័យ

- ទីធ្លាខាងក្រៅទូលាយ មានរបង ខ្លោងទ្វារមានដាក់ស្លាកឈ្មោះត្រឹមត្រូវ ដងទង់ជាតិ ដើមឈើជាម្លប់សម្រាប់កុមារលេង សួនផ្កា ធុងសំរាមមានអនាម័យ ស្អាត គ្មានវត្ថុគ្រោះថ្នាក់ដល់កុមារ

៣០.មានទឹកស្អាតសម្រាប់កុមារញ៉ាំ និងប្រើប្រាស់

- មានទឹកស្អាតបរិភោគ និងលាងដៃ
- មានធុងចម្រោះទឹកស្អាតតាមថ្នាក់ និងពែងទឹកគ្រប់ចំនួនដោយមានសញ្ញាសម្គាល់

៣១.មានបង្គន់អនាម័យកុមារអាចប្រើប្រាស់ជាប្រចាំ

- មានបង្គន់នៅជិតកុមារអាចប្រើប្រាស់បានរាល់ថ្ងៃនិងស្អាតជាប្រចាំ មានជម្រាលសម្រាប់កុមារពិការ និងបែងចែកកុមារា កុមារីដោយដាច់ដោយឡែកពីគ្នា
- មានទឹកប្រើប្រាស់គ្រប់គ្រាន់ មានកន្លែងសម្រាប់លាងដៃនិងសាប៊ូ

**ផ្នែកទី៦៖ ហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈ**

៣២.ថ្នាក់រៀនមានលក្ខណៈសមស្រប និងមាំទាំល្អ

- បន្ទប់រៀនមានទំហំ៧ម៉ែត្រគុណនឹង៧ម៉ែត្រ និងដំបូលមិនធ្លុះធ្លាយ
- បង្អួចធំៗដាក់ដំរឹងដែករឹងមាំ មានពន្លឺនិងខ្យល់អាកាសចេញចូលគ្រប់គ្រាន់
- ផ្ទៃខាងក្រោយមានចាក់សាបរាបស្មើដោយក្រាលកៅស៊ូផ្កា
- បន្ទប់មានអនាម័យស្អាតជាប្រចាំ[26]

[26] នាយកដ្ឋានកុមារតូច, ស្តង់ដារសាលាមត្តេយ្យសិក្សារដ្ឋ, ទំព័រ៨ ដល់ទំព័រ១៣

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ វិធីសាស្ត្រស្រាវជ្រាវ

ឆ្លងតាមការសិក្សាស្រាវជ្រាវនេះ សម្រេចបានតាមវត្ថុបំណងដែលបានរៀបរាប់ខាងលើ នាងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវគឺ៖

នាងខ្ញុំបានប្រើប្រាស់កម្រងសំណួរ[27] ក្នុងការចុះស្រាវជ្រាវដល់អាណាព្យាបាលសិស្សចំនួន១០១នាក់ ដោយសួរសំណួរដែលបានរៀបចំទុកជាស្រេច។ ការប្រើប្រាស់ទិន្នន័យទី២ (Secondary Data) ទទួលបានមកពីសំណៅឯកសារដែលមាននៅក្នុងបណ្ណាល័យ ប្រព័ន្ធអ៊ិនធើណែត។ ក្រៅពីនោះ ទិន្នន័យទី១ (Primary Data) ដែលបានមកពីកម្រងសំណួរគឺជាទិន្នន័យសំខាន់ក្នុងការវិភាគ ស្វែងយល់ពីមូលហេតុដែលឪពុកម្តាយបញ្ជូនកូនទៅសាលាមត្តេយ្យសិក្សារដ្ឋ៨មីនា។ ទិន្នន័យនេះនឹងត្រូវប្រើប្រាស់សម្រាប់ប្រៀបធៀបរកមើលពីអថេរខ្ពស់បំផុតដើម្បីរកឃើញពីមូលហេតុច្បាស់លាស់មួយ។ នាងខ្ញុំបានធ្វើការស្រាវជ្រាវដោយការជ្រើសរើសដោយចៃដន្យ (Sampling random)។ ការជ្រើសរើសដោយចៃដន្យ គឺនាងខ្ញុំបានធ្វើការសម្ភាសន៍ដោយចៃដន្យចំពោះមាតាបិតាសិស្ស ដែលនាំកូនមករៀននៅសាលា មត្តេយ្យ៨មីនា ដោយមិនបានកំណត់មុនចំពោះឈ្មោះ ភេទ ឬមុខរបរឡើយ មានន័យថាជួបម្នាក់ សុំសម្ភាសន៍ម្នាក់ រហូតដល់គ្រប់ចំនួនសំណាកដែលបានត្រៀមទុក។

កម្មវិធី Microsoft Excel ជាកម្មវិធីជំនួយក្នុងការបញ្ចូលទិន្នន័យ និងវិភាគទិន្នន័យតាមបែបក្រាប (Bar Chart)។ នាងខ្ញុំស្រង់ទិន្នន័យចេញពីកម្រងសំនួរ វាយបញ្ចូលក្នុងកម្មវិធីMicrosoft Excel រួចវិភាគចេញជាក្រាបសរសរ (Bar Chart)។

## ៣.២ ទីតាំងនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានធ្វើឡើងនៅសាលាមត្តេយ្យ៨មីនាដែលស្ថិតនៅក្នុងសង្កាត់ចតុមុខខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ការស្រាវជ្រាវនេះធ្វើរយៈពេលចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៩ ដោយចែកជាផ្នែកៗដូចខាងក្រោម៖

ក.គម្រោងស្រាវជ្រាវ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៩ ដល់ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩

ខ. បង្កើតឧបករណ៍ស្រាវជ្រាវ ថ្ងៃទី០៨ ដល់ថ្ងៃទី០៩ មិថុនា ឆ្នាំ២០១៩

គ. ប្រមូលទិន្នន័យ ថ្ងៃទី១០មិថុនា ដល់ ៣១ កក្កដា ឆ្នាំ២០១៩

ឃ. សេចក្តីផ្តើម ថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៩

ង. រំលឹកទ្រឹស្តី ថ្ងៃទី១១ ខែសីហា ដល់ ៣១ ខែសីហា ឆ្នាំ២០១៩

ច. វិធីស្រាវជ្រាវ ថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៩

---

[27] ភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ

ធ. លទ្ធផលស្រាវជ្រាវ និងពិភាក្សា ថ្ងៃទី១៥ ខែកញ្ញា ដល់ ថ្ងៃទី០៥ ខែតុលា ២០១៩

**៣.៣ ឧបករណ៍ស្រាវជ្រាវក្នុងការប្រមូលទិន្នន័យ**

- កម្រងសំណួរ
- ឯកសារនៅបណ្ណាល័យ តាមប្រព័ន្ធអ៊ីនធើណែត

**៣.៤ ការកំណត់គោលសំណាកក្នុងការប្រមូលទិន្នន័យ**

-ជ្រើសរើសអាណាព្យាបាលសិស្សដែលបញ្ជូនកូនមកសិក្សានៅសាលាមត្តេយ្យ៨មីនា ចំនួន១០១នាក់ នៅក្នុងចំណោមសិស្ស៤៤៤នាក់។ ភាគសំណាកនេះមាន២៣ភាគរយនៃចំនួនសិស្សដែលរៀននៅសាលាមត្តេយ្យ៨មីនា ឆ្នាំសិក្សា២០១៨-២០១៩។

**៣.៥ វិធីសាស្ត្រវិភាគទិន្នន័យ**

យកឧបករណ៍ពីការស្រាវជ្រាវដែលកើតចេញពីទិន្នន័យទី២ និងទិន្នន័យទី១។ ទិន្ន ន័យទី២ ដែលជាឯកសារមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺយកចេញពីបណ្ណាល័យហ៊ុនសែន ឯកសារនាយកដ្ឋានអប់រំកុមារតូច បណ្ណាល័យជាតិ និងឯកសារពីអ៊ីនធើណែត ដែលជាប់ទាក់ទងនិងប្រធានបទរបស់នាងខ្ញុំ។ ចំពោះទិន្នន័យទី១ នាងខ្ញុំបានប្រើប្រាស់កម្រងសំណួរ ដើម្បីធ្វើការសម្ភាសន៍ដោយផ្ទាល់ចំពោះអាណាព្យាបាលដែលបានបញ្ជូនកូនឱ្យបន្តការសិក្សានៅសាលាមត្តេយ្យ៨មីនា។ នៅក្នុងកម្រងសំណួរ នាងខ្ញុំបែងចែក២ផ្នែកៗធំ គឺផ្នែកទី១ ព័ត៌មានទូទៅ មាន៤ចំណុចគឺ ទី១ ភេទ ទី២ អាយុ ទី៣ មុខរបរ ទី៤ កម្រិតវប្បធម៌។ ផ្នែកទី២ កម្រងសំណួរដែលបែងចែកជា៤លក្ខណៈវិនិច្ឆ័យគឺ ទី១ តួនាទីភារកិច្ចរបស់ឪពុកម្ដាយ ទី២ ទទួលបានចំណេះដឹង ទី៣ សុវត្ថិភាព ទី៤ ពេលទំនេរ។

**៣.៦ ព័ត៌មានទូទៅ**




**ក្រាហ្វទី១. ភេទរបស់អ្នកតបសម្ភាសន៍**

តាមក្រាហ្វទី១បង្ហាញថាអ្នកចូលរួមផ្ដល់សម្ភាសន៍មានចំនួន N=១០១នាក់ ក្នុងនោះមានស្រីចំនួន៦៩នាក់ ស្មើនឹង ៦៨.៣១ និងប្រុសចំនួន៣២នាក់ ស្មើនឹង ៣១.៦៨%។



### ក្រាហ្វទី២ អាយុរបស់របស់អ្នកតបសម្ភាសន៍

ក្រាហ្វទី២ បង្ហាញពីអាយុរបស់អ្នកតបសម្ភាសន៍ N=១០១នាក់ គឺ អាយុចន្លោះពី២០ឆ្នាំដល់៣០ឆ្នាំ មានចំនួន២៨នាក់ ស្មើនឹង២៧.៧២% អាយុចន្លោះ៣១ឆ្នាំ ដល់៤០ឆ្នាំ មានចំនួន៦០នាក់ ស្មើនឹង៥៩.៤% អាយុលើសពី៤១ឆ្នាំមានចំនួន១២នាក់ ស្មើនឹង ១១.៨៨%។ អាយុស្ថិតនៅក្នុងភាពផ្សេងៗគឺមាន ០១នាក់ ស្មើនឹង០.៩៩% មានន័យថា អ្នកតបសម្ភាសន៍នោះមានអាយុក្រោម២០ឆ្នាំ។




### ក្រាហ្វទី៣ មុខរបររបស់អ្នកតបសម្ភាសន៍

តាមក្រាហ្វទី៣ បង្ហាញថាអ្នកតបសម្ភាសន៍ N=១០១នាក់ ដែលក្នុងមានមុខរបរជាមេផ្ទះចំនួន៣១នាក់ស្មើនឹង៣០.៦៩% ចំណែកឯគ្រូបង្រៀនមានចំនួន០៦នាក់ ស្មើនឹង៥.៩៤% ប៉ូលីសមានចំនួន១០នាក់ ស្មើនឹង ៩.៩០% និងផ្សេងពីនេះ៥៤នាក់ស្មើនឹង៥៣.៤៦% ដែលក្នុងចំណោមនោះសន្តិសុខ១២នាក់ ទាហាន០៧នាក់ អ្នករកស៊ី២៧នាក់ អ្នករត់ម៉ូតូឌុប០៨នាក់។



**ក្រាហ្វទី៤ កម្រិតវប្បធម៌របស់អ្នកតបសម្ភាសន៍**

តាមក្រាហ្វទី៤ បង្ហាញថាក្នុងចំណោមអ្នកតបសម្ភាសន៍ N=១០១នាក់ មានកម្រិតវប្បធម៌ ផ្សេងៗពីគ្នាដូចជា ៖ អ្នកតបសម្ភាសន៍មានកម្រិតវប្បធម៌បឋមសិក្សាចំនួន១២នាក់ ស្មើនឹង ១១.៨៨% អ្នកមានកម្រិតវប្បធម៌មធ្យមសិក្សាបឋមភូមិចំនួន១៩នាក់ ស្មើនឹង ១៨.៨១% អ្នកដែលមានកម្រិតវប្បធម៌មធ្យមសិក្សាទុតិយភូមិចំនួន៣៤នាក់ ស្មើនឹង៣៤.៣៤% និងកម្រិតវប្បធម៌ផ្សេងៗចំនួន៣៦នាក់ ស្មើនឹង ៣៦.៣៦%។ ក្នុងចំណោមចំនួន៣៦នាក់នោះមានកម្រិតវប្បធម៌បរិញ្ញាបត្រចំនួន២៨នាក់ និងបរិញ្ញាបត្រជាន់ ខ្ពស់ចំនួន០៨នាក់។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

## ៤.១ លទ្ធផលស្រាវជ្រាវ

### ៤.១.១ តួនាទី ភារកិច្ចរបស់ឪពុកម្តាយ

នៅក្នុងលក្ខណវិនិច្ឆ័យស្តីពីតួនាទីភារកិច្ចរបស់ឪពុកម្តាយ ក្នុងចំណោមN=១០១នាក់ ចែកចេញជា៤ ចំណុច មានដូចខាងក្រោម៖




**ក្រាហ្វទី៥ តួនាទីភារកិច្ចរបស់ឪពុកម្តាយដែលបានតបសម្ភាសន៍**

យោងតាមក្រាហ្វទី៥ បង្ហាញថាអ្នកសម្ភាសន៍បានឆ្លើយតបឯកភាពទាំងចំនួន១០១នាក់គឺ៖

- ការបញ្ជូនកូនចូលរៀនជាតួនាទីរបស់ឪពុកម្តាយ មានអ្នកឆ្លើយឯកភាពចំនួន ១០១នាក់ ស្មើ១០០% មានន័យថាឪពុកម្តាយបានយកចិត្តទុកដាក់ដល់ការសិក្សារបស់កូនខ្លាំងទោះបីកូនមានអាយុទើបតែចាប់ផ្តើមទទួលការសិក្សាដំបូងក្នុងអាយុជីវិតរបស់គេក៏ដោយ។ តួលេខបញ្ជាក់ថា ក្នុងនាមជាឪពុកម្តាយគឺមានការយល់ដឹងច្រើន ពីតួនាទីរបស់ខ្លួន ហើយមានការយកចិត្តទុកដាក់តាមដានពីការចុះឈ្មោះចូលរៀន និងអាយុចូលរៀនរបស់កូនយ៉ាងហ្មត់ចត់។ ក្នុងចំណោមអាណាព្យាបាល១០១នាក់ ដែលបានឆ្លើយតបតាមរយៈកម្រងសំណួរ គឺបានឯកភាពថា ការនាំកូនទៅចុះឈ្មោះ ចូលរៀនគឺជាតួនាទីរបស់គាត់ប្រាកដមែន។
- ឪពុកម្តាយត្រូវយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន មានអ្នកឆ្លើយឯកភាពចំនួន ១០១នាក់ ស្មើនឹង១០០% ។ មិនត្រឹមតែការនាំកូនទៅចុះឈ្មោះនៅសាលារួចហើយ អាណាព្យាបាលមិនបានតាមដានកូនការសិក្សារបស់កូនទេ តាមចម្លើយរបស់ផ្តល់មតិតាមកម្រងសំណួរបញ្ជាក់ថាក្នុងចំណោម ១០១នាក់ គឺឯកភាពចំពោះការយកចិត្ត ទុកដាក់ការសិក្សារបស់កូននៅតាមសាលារៀន ឬពេលត្រឡប់មកផ្ទះពួកគាត់យកចិត្តទុកដាក់តាមដានការសិក្សារបស់កូនជាប្រចាំផងដែរ។ លទ្ធផលនេះបញ្ជាក់ថា ការយកចិត្តទុកដាក់ដល់ការសិក្សារបស់កូន គឺជាកត្តាមួយសំខាន់នៅក្នុងសង្គមគ្រួសារនានាពេលបច្ចុប្បន្ន គឺពួកគាត់ចង់ឱ្យកូនទទួលបានការអប់រំមួយដែលល្អប្រសើរ។ ទន្ទឹមនឹងនេះ

សាលារៀនគប្បីយកចិត្តទុកដាក់ចំពោះការផ្តល់សេវាអប់រំដល់សិស្សានុសិស្សប្រកបដោយគុណភាព ស្របតាមការចង់បានរបស់អាណាព្យាបាលរបស់ពួកគាត់។

- ការបញ្ជូនកូនចូលរៀនគឺធ្វើឱ្យកូនមានទីពំនឹងសម្រាប់អនាគត មានអ្នកឆ្លើយឯកភាព ចំនួន ១០១ នាក់ ស្មើនឹង ១០០%។ គោលបំណងរបស់អាណាព្យាបាលដែលចង់ឱ្យ កូនទទួលបានការអប់រំ គឺពួកគាត់រំពឹងថាថ្ងៃអនាគតកូនរបស់គាត់នឹងអាចពឹងពាក់ខ្លួនឯងជាមួយចំណេះដឹងដែលកូនពួកគាត់ទទួលបានពីសាលា ដើម្បីទ្រទ្រង់ជីវភាព ខ្លួនឯង គ្រួសារ និងសង្គមជាតិនាពេលថ្ងៃអនាគត។ ពួកគាត់ដឹងថា ការចូលរៀនថ្ងៃ នេះវានឹងធ្វើឱ្យមានការល្អប្រសើរនៅថ្ងៃអនាគតផងដែរ។ ក្នុងនាមជាអាណាព្យាបាលគឺមានការគិតគូរបានវែងឆ្ងាយ និងខ្វល់ខ្វាយពីអនាគតរបស់កូនជាប់ប្រចាំ។ លទ្ធផលទាំងនេះឆ្លុះបញ្ចាំងដល់ការខិតខំរបស់សាលារៀន ជាពិសេសសាលាមត្តេយ្យ៨មីនាដែលបានខិតខំបណ្តុះបណ្តាលទំពាំងស្នងឫស្សីរបស់យើងដោយយកចិត្តទុកដាក់ ដើម្បីឱ្យពួកគាត់ក្លាយជាធនធានមនុស្សល្អសម្រាប់ថ្ងៃ អនាគត។
- ឪពុកម្តាយត្រូវតែចាត់ទុកការសិក្សារបស់កូនជាភាពសំខាន់ មានអ្នកឆ្លើយតបចំនួន ១០១នាក់ ស្មើនឹង ១០០%។ លទ្ធផលសិក្សារបស់កូន គឺមានការគួបផ្សំពីការយកចិត្ត តាមដានពីអាណាព្យាបាលពេលពួកគាត់នៅសាលារៀនក្តី នៅផ្ទះក្តី។ ការយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូនបញ្ជាក់ឱ្យឃើញថា បច្ចុប្បន្ននេះឪពុកម្តាយគឺខ្វល់ ខ្វាយខ្លាំងពីលទ្ធផលសិក្សារបស់កូនៗ ពីគុណភាពនៃការអប់រំ និងបរិយាកាសអប់រំ តាមសាលារៀននីមួយៗផងដែរ។ ដូចនេះលទ្ធផលសិក្សារបស់សិស្សគឺជាអ្វីដែល អ្នកអប់រំត្រូវយកចិត្តទុកដាក់ខ្លាំង ពីព្រោះវាឆ្លុះពីលទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាល ការគ្រប់គ្រង ការបង្រៀននិងរៀន។ ការយកចិត្តទុកដាក់ចំពោះសិក្សារបស់កូនពីសំណាក់អាណាព្យាបាលគឺជាសញ្ញាវិជ្ជមាន ក្នុងវិស័យអប់រំរបស់យើងសម្រាប់ថ្ងៃអនាគតយ៉ាងខ្លីខាងមុខ ដោយសារការវិនិយោគក្នុងការអប់រំដល់កូនៗរបស់ពួកគាត់ នឹងនាំមកនូវការរីកចម្រើនជាក់ជាមិនខាន។

### ៤.១.២ ទទួលបានចំណេះដឹង

នៅក្នុងលក្ខណវិនិច្ឆ័យស្តីពីទទួលបានចំណេះដឹងក្នុងចំណោមN=១០១នាក់ចែកចេញជា០៥ ចំណុច មានដូចខាងក្រោម៖



## ក្រាហ្វទី៦ ស្តីពីការទទួលបានចំណេះដឹងរបស់អ្នកតបសម្ភាសន៍

យោងតាមក្រាហ្វទី៦ បានបង្ហាញពីអ្នកតបសម្ភាសន៍ N= ១០១នាក់ ស្តីការទទួលបានចំណេះដឹងរបស់កូនពួកគាត់ដូចខាងក្រោម៖

- ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះអាន ចេះសរសេរ មានអ្នកឆ្លើយតបឯកភាពចំនួន ១០១នាក់ ស្មើនឹង ១០០%។ ការចេះអាន ចេះសរសេរគឺជារឿងមួយដែលអាណាព្យាបាលគ្រប់រូបប្រាថ្នាចង់បានសម្រាប់កូនរបស់គាត់ក្នុងវ័យដំបូងដើម្បីឈានចាប់ជំនាញផ្សេងៗ។ ចំពោះលទ្ធផលនេះបញ្ជាក់ឱ្យឃើញថាអាណាព្យាបាលបានគិតឃើញពីចំណុចនេះយ៉ាងច្បាស់លាស់ វាគឺជាការចូលរួមក្នុងការលើកកម្ពស់ធនធាន មនុស្សរបស់ប្រទេសតាមរយៈការបញ្ជូនកូនទៅសាលារៀន ដើម្បីឱ្យកូនបន្តអាជីព បន្តទៅមុខទៀតបានតាមរយៈការអាន និងសរសេរជាមុនសិន។ ថ្ងៃអនាគតកូនរបស់ពួកគាត់នឹងមានចំណេះដឹងគ្រប់គ្រាន់ ទន្ទឹមនឹងនេះសាលារៀនក៏បានខិតខំ ប្រឹងប្រែងដើម្បីផ្តល់ចំណេះដឹងដល់កូនៗប្រកបដោយការយកចិត្តទុកដាក់ ស្វែងរក វិធីសាស្ត្របង្រៀនល្អដើម្បីធ្វើឱ្យកុមារចាប់ចេះអាន និងសរសេរបានត្រឹមត្រូវទាំងភាសាជាតិ និងអន្តរជាតិ ធ្វើជាយាន្តឈានចាប់យកការសិក្សាថ្នាក់ខ្ពស់បន្តទៀតនៅ ពេលអនាគត ហើយដើម្បីជាប្រភពធនធានមនុស្សកសាងប្រទេសជាតិដែលមិនអាចខ្វះបាន។
- ការបញ្ជូនកូនទៅសាលាឱ្យចេះសីលធម៌ក្នុងការរស់នៅ មានអ្នកឆ្លើយតបឯកភាពចំនួន ១០១នាក់ ស្មើនឹង ១០០%។ មិនត្រឹមតែដើម្បីចេះអាន និងចេះសរសេរប៉ុណ្ណោះទេ អាណាព្យាបាលបានគិតគូរបានស៊ីជម្រៅរហូតដល់គិតថា ពេលកូនៗ រៀនទៅសាលាគឺមានក្តីសង្ឃឹមថាកូនរបស់ពួកគាត់នឹងមានសីលធម៌ល្អក្នុងការរស់នៅល្អប្រសើរសមស្របតាមសីលធម៌ខ្មែរដែលល្អ ដែលជាហេតុនាំឱ្យពួកគេនឹងក្លាយទៅពលរដ្ឋល្អសម្រាប់ប្រទេសជាតិ និងក្លាយជាពលរដ្ឋសាកលសម្រាប់ថ្ងៃអនាគត។ លទ្ធផលនេះបង្ហាញថា ការអប់រំ និងសីលធម៌ល្អគឺដើរទន្ទឹមគ្នាដែលអាណា ព្យាបាលម្នាក់ៗប្រាថ្នាចង់បាន ហើយប្រទេសជាតិក៏ប្រាថ្នាចង់បានដែរ។ ដូចនេះ ថ្នាក់ដឹកនាំសាលារៀននីមួយៗ ដែលបានខិតខំបង្រៀន និងអប់រំដល់កូនៗគឺកំពុងបានយកចិត្តទុកដាក់ទាំងចំណេះដឹង និងសីលធម៌ ដើម្បីសម្រេចតាមបំណងរបស់ អាណាព្យាបាល និងប្រទេសជាតិនាថ្ងៃអនាគត។
- ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះអត់ឱន និងអធ្យាស្រ័យគ្នា មានអ្នកឆ្លើយតបឯក ភាពចំនួន៩៨នាក់ ស្មើនឹង ៩៧.០២% និង មិនឯកភាព ០៣នាក់ ស្មើនឹង២.៩៧%។ អ្វីដែលបានសង្កត់ធ្ងន់នៅក្នុងសីលធម៌ដែលអាណាព្យាបាលបានទទួលឯកភាពភាគច្រើនរហូតដល់៩៨នាក់ក្នុងចំណោម ១០១នាក់ គឺចង់ឱ្យកូនរបស់ពួកគាត់ចេះអត់ឱន និងអធ្យាស្រ័យគ្នា ដែលជាចំណុចល្អនៅការរស់នៅក្នុងសម័យបច្ចុប្បន្ន ហើយវាក៏ជាចំណុចវិជ្ជមានក្នុងការគិតពិចារណារបស់អាណាព្យាបាល ហើយវាក៏ជាលទ្ធផល មួយសម្រាប់ចង្អុលបង្ហាញដល់សាលារៀននីមួយៗដែលកំពុងបានបង្រៀន និងអប់រំ សិស្សដោយយកចិត្តទុដាក់បំផុតនោះ គឺបានទទួលដឹងពីចំណុចដែលអាណាព្យាបាល

ប្រាថ្នាចង់បាន និងជាចំណុចល្អដែលនាំឱ្យក្មេងៗក្លាយទៅជាមនុស្ស ឬធន ធានដែលប្រកបដោយគុណធម៌ និងចំណេះដឹងសម្រាប់ចូលរួមអភិវឌ្ឍប្រទេសជាតិ យើងនាថ្ងៃអនាគត។ ចំពោះអ្នកដែលមិនឯកភាពចំនួន០៣នាក់ ក្នុងចំណោម១០១ នាក់មិនឯកភាពចំណុចខាងលើគឺគាត់បង្ហាញពីហេតុផលលើសពីនេះ គឺចង់ឱ្យពួក គាត់មានភាពក្លាហាន និងតស៊ូក្នុងជីវិតទើបល្អប្រសើរ។ ចំណុចដែលពួកគាត់ឯក ភាព និងបញ្ចេញយោបល់បន្ថែមផ្ទុយពីកម្រងសំណួរនោះគឺសុទ្ធតែជាចំណុចល្អប្រសើរដល់ការអប់រំសម្រាប់ក្មេងៗ និងជាប្រយោជន៍ដល់សាលារៀន និងប្រព័ន្ធអប់រំទាំងមូលផងដែរ។

- ការបញ្ជូនកូនទៅសាលារៀនដើម្បីឱ្យគាត់ចេះទំនាក់ទំនង មានអ្នកឆ្លើយតបឯកភាពចំនួន៩៣នាក់ ស្មើនឹង ៩២.០៧% និងឆ្លើយតបមិនឯកភាពចំនួន៨នាក់ ស្មើនឹង៧.៩២% ។ ការចង់ឱ្យកូនមានទំនាក់ទំនងគឺពួកគាត់ឯកភាពចំពោះចំនុចនេះ រហូតដល់៩៣នាក់ ក្នុងចំណោម១០១នាក់ គឺលទ្ធផលនេះបង្ហាញឱ្យឃើញថាអាណា ព្យាបាលមានការខ្វល់ខ្វាយ និងយកចិត្តទុកដាក់ចង់ឱ្យកូនចេះទំនាក់ទំនងមានមិត្តភក្តិនៅក្នុងសាលារៀន និងក្នុងសង្គម វាជាចំណុចល្អណាស់ដែលវាជំនាញថ្មីមួយ ក្នុងចំណោមជំនាញដទៃទៀតនៅក្នុងសតវត្សទី២១នេះ ដែលពិភពលោកប្រាថ្នាចង់ បានធនធានមនុស្សដែលពូកែទំនាក់ទំនង។ លទ្ធផលនេះគឺជម្រុញឱ្យសាលារៀន មានកម្មវិធីសិក្សា ឬការអប់រំឱ្យសិស្សមានទំនាក់ទំនងល្អក្នុងសាលារៀន សហគមន៍ និង សង្គមជាដើម។ ចំពោះអ្នកផ្តល់មតិចំនួន៨នាក់ក្នុងចំណោម១០១នាក់ មិនឯកភាពចំពោះចំណុចឱ្យសិស្សចេះទំនាក់ទំនង គឺពួកគាត់ថាមិនត្រឹមតែចេះទំនាក់ទំនងទេ គឺត្រូវដឹងថាទំនាក់ទំនងណាល្អ និងទំនាក់ទំនងមិនល្អផង។
- ការបញ្ជូនកូនទៅសាលារៀនឱ្យគាត់ចេះលេងកំសាន្ត ឆ្លើយតបឯកភាពចំនួន៩០នាក់ ស្មើនឹង ៨៩.១០% មិនឯកភាពចំនួន ១០នាក់ ស្មើនឹង ៩.៩០% និងមតិផ្សេងៗចំនួន ០១នាក់ ស្មើ ០.៩៩%។ ការលេងកំសាន្តគឺទាក់ទងនឹងការសិក្សារៀនសូត្ររបស់កុមារផងដែរ តាមទ្រឹស្តីរបស់ចន ដេវី និងម៉ុនតេសូរី ស្តីពីការរៀនគឺការលេងកំសាន្ត ដើម្បីបង្ហាញពីចំណង់ចំណូលចិត្តរបស់ក្មេង។ ការលេងកំសាន្តរបស់កុមារគឺបង្ហាញពីទំនាក់ទំនងជាមួយក្មេងដទៃទៀត បង្ហាញពីទំនាក់ទំនងពិតប្រាកដនៅក្នុងសង្គម និងជីវភាពរស់នៅពិតប្រាកដ។ សាលារៀនគប្បីស្វែងយល់ពីចំណុចនេះផងដែរដើម្បីរៀបចំការលេងកំសាន្ត ឱ្យមានសម្ភារគ្រប់គ្រាន់ កន្លែងលេងកំសាន្ត ទីធ្លាទូលាយ និងមានការតាមដានសកម្មភាពលេងរបស់កុមារ។ ការរៀនដោយការធ្វើសកម្មភាព គឺកុមាររៀនដោយការលេងកំសាន្ត ការសំដែងតួ គឺមានប្រសិទ្ធិភាពនិងការចូលរួមរបស់កុមារយ៉ាងសប្បាយរីករាយ។ អាណាព្យាបាលនៅក្នុងពេលបច្ចុប្បន្ន នេះបានគិតទៅដល់ការលេងកំសាន្តរបស់កូនៗ គឺជាសកម្មភាពមួយដែលជម្រុញឱ្យ សាលារៀននីមួយៗធ្វើការរៀបចំកន្លែងសមស្របទាន់សម័យដើម្បីកុមារបានលេង កំសាន្តគ្រប់គ្រាន់។

### ៤.១.៣ សុវត្ថិភាព

នៅក្នុងលក្ខណវិនិច្ឆ័យស្តីពីសុវត្ថិភាពក្នុងចំណោម N=១០១នាក់ ចែកចេញជា០៣ ចំណុច មានដូចខាងក្រោម៖




**ក្រាហ្វទី៧ ស្តីពីសុវត្ថិភាពក្នុងការបញ្ជូនទៅរៀននៅសាលា៨មីនា**

យោងតាមក្រាហ្វទី៧ បង្ហាញឱ្យឃើញថាអ្នកឆ្លើយតបសម្ភាសន៍ N=១០១នាក់ ស្តីពី សុវត្ថិភាពក្នុងការបញ្ជូនកូនទៅរៀន នៅសាលាមត្តេយ្យ៨មីនា បង្ហាញលទ្ធផលដូចខាងក្រោម៖

- ការរៀននៅសាលាមត្តេយ្យ៨មីនា គឺមានសុវត្ថិភាពដល់កូន មានអ្នកឆ្លើយតបឯកភាព ចំនួន១០១នាក់ ស្មើនឹង១០០% ។ សុវត្ថិភាពគឺជាចំណុចសំខាន់ក្នុងចំណោមចំណុច សំខាន់ៗដទៃទៀតដែលអាណាព្យាបាលបានយកចិត្តទុកដាក់ខ្លាំងដល់កូនៗរបស់គាត់។ ដូចករណីនៅសាលាមត្តេយ្យ៨មីនា គាត់មានការទុកចិត្តដល់សុវត្ថិភាពកូនៗរបស់គាត់ដោយសារ សាលាមានរបង និងមានការគ្រប់គ្រងសុវត្ថិភាពបានគ្រប់ជ្រុងជ្រោយ។ ដូចនេះសាលារៀន ផ្សេងៗទៀតត្រូវពិចារណាចំណុចនេះដើម្បីអភិវឌ្ឍសាលារៀនរបស់ខ្លួន ដើម្បីឆ្លើយតបនឹង តម្រូវការរបស់មាតាបិតា អាណាព្យាបាលក្នុងពេលបច្ចុប្បន្ន នឹងជួយឱ្យកុមារទទួលបានសេវាអប់រំដ៏ល្អប្រសើរ។
- មានភាពកក់ក្តៅមិនសូវបារម្ភ មានអ្នកឆ្លើយតបឯកភាពចំនួន១០១នាក់ ស្មើនឹង ១០០%។ អាណាព្យាបាលតែងតែបារម្ភពីសុវត្ថិភាពរបស់កូន ការបារម្ភមានច្រើនចំណុចដូចជាសុវត្ថិ ភាពក្នុងការសិក្សា និងចំណីអាហារ និងចំណុចផ្សេងៗទៀត។ ការបារម្ភនេះបានកាត់បន្ថយ ដោយសារសាលាមត្តេយ្យ៨មីនាបានរៀបចំសុវត្ថិភាពរាងកាយ និងសុវត្ថិភាពផ្សេងៗជូនដល់កូនៗ របស់ពួកគាត់បានល្អប្រសើរ។ សាលារៀនផ្សេងៗទៀតអាចយកគំរូសាលាមត្តេយ្យ៨មីនាយកទៅ គិតពិចារណាក្នុងការអភិវឌ្ឍសាលារបស់ខ្លួនដើម្បីឱ្យកុមាររៀនបានល្អប្រសើរ និងអាណា ព្យាបាលមានការស្ងប់អារម្មណ៍ មានការជឿជាក់ដល់សុវត្ថិភាពរបស់គាត់។
- សាលាមានការយកចិត្តទុកដាក់ដល់សុវត្ថិភាពសិស្សបានល្អ មានអ្នកឆ្លើយតបឯកភាពចំនួន ១០០នាក់ ស្មើនឹង ៩៩.០១% ។ លទ្ធផលនេះបានបញ្ជាក់ពីលទ្ធផលសុវត្ថិភាពយ៉ាងមុតមាំ ថា សាលាម

ត្តេយ្យ៨មីនា ពិតជាបង្ករឱ្យមានភាពទុកចិត្ត កក់ក្តៅពីសំណាក់មាតាបិតាដែលមាន កូន ចៅ រៀន នៅទីនេះប្រាកដមែន។

### ៤.១.៤ ពេលទំនេរ

នៅក្នុងលក្ខណវិនិច្ឆ័យស្តីពីពេលទំនេរក្នុងចំណោម N=១០១នាក់ ចែកចេញជា០៣ ចំណុច មានដូចខាងក្រោម៖




**ក្រាហ្វទី៨ ស្តីពីមានពេលទំនេរនៅពេលបញ្ជូនទៅសាលាមត្តេយ្យ**

តាមរយៈក្រាហ្វទី៨ បង្ហាញឱ្យឃើញថា នៅក្នុងចំណោមអ្នកតបសម្ភាសន៍ចំនួន N=១០១នាក់ ទៅតាមសំនួរមួយៗមានការចំនួនខុសគ្នា ដូចខាងក្រោម៖

- មានពេលវេលាប្រកបរបររកស៊ី អ្នកឆ្លើយតបឯកភាពចំនួន៦២នាក់ ស្មើនឹង ៦១.៣៨% ឆ្លើយមិនឯកភាព ៣២នាក់ ស្មើនឹង ៣១.៦៨% និងមតិផ្សេងៗ ចំនួន៧នាក់ ស្មើនឹង ៦.៩៣%។ មានពេលទំនេរសម្រាប់រកស៊ី មានអ្នកចូលរួមផ្តល់មតិរហូត ៦២នាក់ ដែលជាចំនួនច្រើនជាងគេដែលបញ្ជាក់ថាការបញ្ជូនកូនមករៀននៅសាលា មត្តេយ្យ៨មីនានេះ ។ ចំណុចនេះក៏បង្ហាញថា អាណាព្យាបាលក៏បានគិតពីការធូរស្រាលក្នុង ការប្រកបរបររកស៊ី ហើយកូនចៅតូចៗអាចជាបញ្ហាក្នុងការរំខានដល់ការរកស៊ីរបស់ ពួកគាត់ផងៗ បន្ថែមពីនេះទៅទៀត មានអ្នកឆ្លើយតបចំនួន៣២នាក់បានបដិសេធចំពោះមតិថាការបញ្ជូនកូនដើម្បីមានទំនេរក្នុងការរស៊ី គឺពួកគាត់បញ្ជូនកូនមកនេះ ក្នុងគោលបំណងទទួលបានចំណេះដឹង និងមានសីលធម៌។ ទោះបីយ៉ាងក៏ដោយ ទោះបីពេលទំនេរក្តី ក៏នៅក្នុងបំណងមួយពេលពួកគាត់បានបញ្ជាក់ខាងលើរួមហើយ ថាចំណេះដឹង សីលធម៌ និងទំនាក់ទំនងគឺជាចំណុចពួកគាត់ឯកភាព ហើយពេលវេលាទំនេរក្នុងការរកស៊ីក៏ជាចំណុចសំខាន់មួយក្នុងចំណោមចំណុចសំខាន់ដែលពួក គាត់ជាអាណាព្យាបាលយកចិត្តទុកដាក់ខ្លាំងណាស់ដែរ។

- មានពេលគ្រប់គ្រាន់ក្នុងការបន្តការសិក្សា មានអ្នកឆ្លើយតបឯកភាពចំនួន២៣នាក់ ស្មើនឹង ២២.៧៧% ឆ្លើយមិនឯកភាពចំនួន៧៥នាក់ ស្មើនឹង ៧៤.២៥% និងមតិ ផ្សេងៗចំនួន០៣នាក់ ស្មើនឹង២.៩៧% ។ ចំពោះអាណាព្យាបាលក្មេងៗយកពេល ពេលវេលាទៅបន្តការសិក្សាចំនួន២២ នាក់ មានន័យថា គាត់មានពេលទំនេរក្នុងការ សិក្សារបស់គាត់បន្ទាប់ពីបានបញ្ជូនកូនទៅសាលាមត្តេយ្យ៨មីនានេះ។ ចំពោះ៧៥នាក់ផ្សេង ទៀតបានបដិសេធ ដោយសារគាត់មានមុខរបរផ្សេងដូចជាអ្នករកស៊ី និងមន្ត្រីរាជការដែលមិនបានបន្តការសិក្សានោះ ដែលកំពុងបម្រើការតាមអង្គភាពនានា និងការប្រកបរបរលក់ដូរ ដូចនេះគាត់បានបដិសេធ។ ចំពោះមតិផ្សេងៗទៀតពួកគាត់បានបំពេញកិច្ចការផង និងបន្តការសិក្សាផង។
- មានពេលគ្រប់គ្រាន់ក្នុងការបំពេញការងារ មានអ្នកឆ្លើយតបឯកភាពចំនួន៧៦នាក់ ស្មើនឹង ៧៥.២៥% មិនឯកភាព ចំនួន២២នាក់ ស្មើនឹង២១.៧៨% និងមតិផ្សេងៗចំនួន០៣នាក់ ស្មើនឹង ២.៩៧%។ លទ្ធផលនេះបង្ហាញថា អ្នកចូលរួមមតិយោបល់ ដែលជាមន្ត្រីរាជការមានចំនួនតិចជាងអ្នកដែលមានមុខរបររកស៊ីលក់ដូរ ដូចនេះ ហើយទើបចំនួន៧៦នាក់ ក្នុងចំណោមអ្នកផ្តល់មតិ១០១ នាក់ បានឆ្លើយបដិសេធ ហើយចំនួនផ្សេងទៀតបានឆ្លើយថាពួកគាត់មានពេលក្នុងការបំពេញការងារជាមន្ត្រី រាជការ នៅតាមស្ថាប័ន និងអង្គភាពផ្សេងៗ។

## ៤.២ ពិភាក្សា

ឆ្លងតាមលទ្ធផលដែលបានបង្ហាញខាងលើ យើងឃើញថា ទស្សនៈយល់ឃើញរបស់ មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅមត្តេយ្យសិក្សាអាយុ៣ឆ្នាំ អាយុ៤ឆ្នាំ និងអាយុ៥ឆ្នាំ នឹងត្រូវបង្ហាញថា ទស្សនៈណាមួយក្នុងចំណោមលក្ខខណៈវិនិច្ឆ័យចំនួន៤ខាងលើ ណាមួយជាលក្ខណៈវិនិច្ឆ័យដែលទទួលបានការឯកភាពចំនួនច្រើនជាងគេ ដែលបង្ហាញដូចខាងក្រោម៖

### ១- រកមធ្យមភាគតាមលក្ខណវិនិច្ឆ័យនីមួយៗ

ក. ប្រៀបធៀបមធ្យមភាគឯកភាពក្នុងលក្ខខណៈវិនិច្ឆ័យស្តីពី តួនាទីភារកិច្ចរបស់ឪពុកម្តាយ ដែលមានសំណួរតេស្តចំនួន០៤ចំណុចដូចខាងក្រោម៖

| តួនាទីភារកិច្ចរបស់ឪពុកម្តាយ | ឯកភាព | មិនឯកភាព | ផ្សេងៗ |
|---|---|---|---|
| ការបញ្ជូនកូនទៅរៀនជាតួនាទីភារកិច្ចរបស់ឪពុកម្តាយ | 101 | 0 | 0 |
| ឪពុកម្តាយត្រូវយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន | 101 | 0 | 0 |
| ការបញ្ជូនកូនចូលរៀនធ្វើឱ្យមានពំនឹងសម្រាប់អនាគត | 101 | 0 | 0 |
| ឪពុកម្តាយត្រូវតែចាត់ទុកការសិក្សារបស់កូនជាភាពសំខាន់ | 101 | 0 | 0 |
| **មធ្យមភាគ** | 101 | 0 | 0 |

**តារាងទី១ ស្តីពីមធ្យមភាគរបស់តួនាទីភារកិច្ចរបស់ឪពុកម្តាយ**

យោងតាមតារាងទី១ បង្ហាញឱ្យឃើញថាមធ្យមភាគស្តីពីតួនាទីភារកិច្ចរបស់ឪពុក ម្តាយក្នុងការបញ្ជូនកូនទៅសាលារៀនមត្តេយ្យសិក្សាគឺ១០១ (N=101) ស្មើ១០០%។

ខ. ប្រៀបធៀបមធ្យមភាគឯកភាពក្នុងលក្ខណៈវិនិច្ឆ័យស្តីពី ការទទួលបានចំណេះដឹងដែលមានសំណួរតេស្តចំនួន០៥ចំណុចដូចខាងក្រោម៖

| ទទួលបានចំណេះដឹង | ឯកភាព | មិនឯកភាព | ផ្សេងៗ |
|---|---|---|---|
| ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះអាន ចេះសរសេរ | 101 | 0 | 0 |
| ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះសីលធម៌ក្នុងការរស់នៅ | 101 | 0 | 0 |
| ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះអត់ឱនអធ្យាស្រ័យ | 98 | 3 | 0 |
| ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះទំនាក់ទំនង | 93 | 8 | 0 |
| ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះលេងកំសាន្ត | 90 | 10 | 1 |
| មធ្យមភាគ | 96.6 | 4.2 | 0.2 |

**តារាងទី២ ស្តីពីការទទួលចំណេះដឹងក្នុងការបញ្ជូនកូនទៅសាលាមត្តេយ្យ**

យោងតាមតារាងទី២ បង្ហាញឱ្យឃើញថាមធ្យមភាគស្តីពីការទទួលចំណេះដឹងក្នុងការ បញ្ជូនកូនទៅសាលាមត្តេយ្យ ដែលមានអ្នកឆ្លើយតបឯកភាពលើលក្ខណៈវិនិច្ឆ័យនេះគឺមានចំនួន ៩៦.៦ (N=101) ដែលស្មើនឹង ៩៥.៦៤% និងមធ្យមភាគមិនឯកភាពចំនួន ៤.២ ស្មើនឹង ៤.១៣% និង មធ្យមភាគមតិផ្សេងៗចំនួន ០.២ ស្មើនឹង ០.១៩%។

គ.ប្រៀបធៀបមធ្យមភាគឯកភាពក្នុងលក្ខណៈវិនិច្ឆ័យស្តីពី សុវត្ថិភាព ដែលមានសំណួរតេស្តចំនួន ០៣ ចំណុចដូចខាងក្រោម៖

| សុវត្ថិភាព | ឯកភាព | មិនឯកភាព | ផ្សេងៗ |
|---|---|---|---|
| ការបញ្ជូនកូនទៅរៀនសាលាមត្តេយ្យ៨មីនាមានសុវត្ថិភាព | 101 | 0 | 0 |
| ការបញ្ជូនកូនទៅរៀនសាលាមត្តេយ្យ៨មីនាមានភាពកក់ក្តៅមិនសូវព្រួយបារម្ភ | 101 | 0 | 0 |
| សាលាយកចិត្តទុកដាក់ដល់សុវត្ថិភាពកុមារ | 100 | 1 | 0 |
| **មធ្យមភាគ** | 100.66 | 0.33 | 0 |

**តារាងទី៣ ស្តីពីសុវត្ថិភាពនៅសាលាមត្តេយ្យ៨មីនា**

យោងតាមតារាងទី៣ បង្ហាញឱ្យឃើញពីមធ្យមភាគស្តីពីសុវត្ថិភាពនៅសាលាមត្តេយ្យ៨មីនា ដែលមានមធ្យមភាគអ្នកឆ្លើយតបឯកភាពចំនួន១០០.៦៦ (N=101) ត្រូវនឹង ៩៩.៦៦% មធ្យមភាគឆ្លើយមិនឯកភាពចំនួន ០.៣៣ ស្មើនឹង ០.៣២៦%។

ឃ. ប្រៀបធៀបមធ្យមភាគឯកភាពក្នុងលក្ខខណ:វិនិច្ឆ័យស្តីពី មានពេលទំនេរ ដែលមានសំណួរតេស្ត ចំនួន០៣ ចំណុចដូចខាងក្រោម៖

| ពេលទំនេរ | ឯកភាព | មិនឯកភាព | មតិផ្សេងៗ |
|---|---|---|---|
| មានពេលសម្រាប់រកស៊ី | 62 | 32 | 7 |
| មានពេលទំនេរសម្រាប់បន្តការសិក្សា | 23 | 75 | 3 |
| មានពេលទំនេរសម្រាប់ធ្វើការ | 76 | 22 | 3 |
| **មធ្យមភាគ** | 53.67 | 43.00 | 4.33 |

**តារាងទី៤ ស្តីពីមានពេលទំនេរបន្ទាប់ពីបញ្ជូនកូនទៅរៀននៅមត្តេយ្យសិក្សា**

យោងតាមតារាងទី៤ បង្ហាញពីមានពេលទំនេរ បន្ទាប់ពីការបញ្ជូនកូនទៅរៀននៅ សាលាមត្តេយ្យ ដែលមធ្យមភាគអ្នកឆ្លើយតបឯកភាពមានចំនួន ៥៣.៦៧ (N=101) ស្មើនឹង ៥៣.១៤% មធ្យមភាគអ្នកឆ្លើយតបមិនឯកភាពមានចំនួន ៤៣.០០ ស្មើនឹង៤២.៥៧% និងមធ្យមភាគអ្នកឆ្លើយតបដោយមតិផ្សេងៗ ចំនួន ៤.៣៣ ស្មើនឹង ៤.២៩%។

## ២-ប្រៀបធៀបមធ្យមភាគលក្ខណវិនិច្ឆ័យនីមួយៗ

ការប្រៀបធៀបលក្ខណវិនិច្ឆ័យនីមួយៗក្នុងគោលបំណងស្វែងរកមធ្យមខ្ពស់បំផុតមួយ ដើម្បីរកឱ្យឃើញពីទស្សនៈរបស់មាតាបិតាក្នុងការបញ្ជូនកូនអាយុ៣ឆ្នាំ អាយុ៤ឆ្នាំ អាយុ៥ឆ្នាំទៅសិក្សានៅមត្តេយ្យសិក្សា (ករណីសិក្សានៅរាជធានីភ្នំពេញ) ដែលការសិក្សានេះធ្វើឡើងនៅសាលាមត្តេយ្យ៨មីនា ដោយធ្វើការសម្ភាសន៍មាតាបិតាសិស្សចំនួន១០១ នាក់។ មធ្យមភាគ

បង្ហាញដូចខាងក្រោម៖




យោងតាមក្រាហ្វ បង្ហាញឱ្យឃើញថា មធ្យមភាគធៀបរវាងលក្ខណ:វិនិច្ឆ័យ នីមួយៗគឺបានបង្ហាញលទ្ធផលដូចខាងក្រោម៖

- តួនាទីរបស់ឪពុកម្តាយ ទទួលបានមធ្យមភាគ ១០១ មធ្យមភាគមិនឯកភាព០ និងមធ្យមភាគមតិផ្សេង១០

- ទទួលបានចំណេះដឹង ទទួលបានមធ្យមភាគ ៩៦.៦ មធ្យមភាគមិនឯកភាព ៤.២ និង មធ្យមភាគមតិផ្សេងៗ ០
- សុវត្ថិភាព ទទួលបានមធ្យមភាគ ១០០.៦៧ មធ្យមភាគមិនឯកភាព ០.៣៣ និងមធ្យម ភាគមតិផ្សេងៗ០
- ពេលទំនេរទទួលបានមធ្យមភាគ ៥៣.៦៧ មធ្យមភាគមិនឯកភាព ៤៣.០០ និងមធ្យម ភាគមតិផ្សេងៗ៤.៣៣

ដូចនេះឃើញថា តាមមធ្យមភាគជៀបនេះ គឺបង្ហាញឱ្យកម្រិតខ្ពស់បំផុត បានទៅលើ ភារកិច្ចតួនាទីរបស់ឪពុកម្ដាយក្នុងការបញ្ជូនកូនទៅរៀននៅមត្តេយ្យ៨មីនា។ មធ្យមភាគខ្ពស់បន្ទាប់បានទៅលើសុវត្ថិភាពរបស់កូនៗ ពេលពួកគាត់បញ្ជូនទៅរៀននៅសាលា មត្តេយ្យ៨មីនា មានន័យថា សាលាមត្តេយ្យ៨មីនា គឺជាសាលារៀនដែលមានទំនុកចិត្តលើសុវត្ថិភាព។

## ៤.៣ មតិយោបល់ទូទៅរបស់អាណាព្យាបាលដែលបានបញ្ជូនកូនមករៀននៅសាលាមត្តេយ្យ៨មីនា

### ក.មេផ្ទះ

មុខរបរមេផ្ទះ ដែលលបានចូលរួមផ្ដល់សម្ភាសន៍មានចំនួន៣១នាក់ក្នុងចំណោមអ្នកផ្ដល់សម្ភាសន៍សរុប១០១ ត្រូវនឹង៣០.៦៩%។ ការបញ្ចេញមតិយោបល់របស់ពួកគាត់ ត្រូវ បានស្រង់ចេញពីកម្រងសំនួរមានដូចខាងក្រោម៖

- សាលារៀនគឺល្អសម្រាប់កូនតូចដោយសារមានកន្លែងពេញមួយថ្ងៃសម្រាប់គេង និង និងសិក្សា ត្រង់ចំណុចនេះគឺមតិយោបល់ដែលដូចគ្នា ឬមានន័យដូចជាមានចំនួន១២នាក់ ក្នុងចំណោម៣១នាក់ ត្រូវជា៣៨.៧១ភាគរយក្នុងចំនួនអ្នកដែលមានមុខរបរជាស្ត្រីមេផ្ទះ។

- សាលារៀនមានរបងបង្ខាំងមិនឱ្យក្មេងចេញក្រៅពីសាលាបាន មានចំនួន០២នាក់ ដែលមានមតិយោបល់លើចំណុចនេះ គិតជាភាគរយគឺមានចំនួន ៦.៤៥ភាគរយ។

- សាលាមានគ្រូស្រីពូកែបង្រៀន ត្រង់ចំណុចនេះពួកគាត់ជាស្ត្រីមេផ្ទះមានចំនួន២០នាក់បានផ្ដល់មតិដូចគ្នាឬស្រដៀងគ្នាទាំងស្រុង បើគិតជាភាគរយគឺ៦៤.៥២ភាគរយ។

- សាលារៀនយកចិត្តទុកដាក់ចំពោះសុវត្ថិភាពក្មេង ចំណុចមានអ្នកមតិចំនួន១៩នាក់ក្នុងចំណោម៣១នាក់ ថាសាលារៀនមានការយកចិត្តទុកដាក់លើស្ថានភាពសុវត្ថិភាពរបស់សិស្សគិតជាភាគរយគឺ៦១.៣០ភាគរយ។

- សាលារៀនជាសាលារដ្ឋ មានគ្រូបង្រៀនល្អ មានអ្នកមតិចំនួន១២នាក់ ក្នុងចំណោម៣១នាក់ ត្រូវជា៣៨.៧១ភាគរយ។

- គេចូលចិត្តសាលារៀនដោយសារមានឈ្មោះល្អនៅភ្នំពេញអ្នកផ្ដល់មតិចំនួន០៤នាក់ ក្នុងចំណោម៣១នាក់ ត្រូវជា ១២.៩០ភាគរយ។

- កូនចូលចិត្តលេងកំសាន្តជាមួយមិត្តភក្តិរបស់គេនៅទីនេះ អ្នកផ្តល់មតិចំនួន០៨នាក់ ក្នុងចំណោម៣១នាក់ ត្រូវជា២៥.៨០ភាគរយ។

- សាលារៀនបង្រៀនក្មេងមានសីលធម៌ល្អ នេះអ្នកផ្តល់មតិចំនួន១៦នាក់ ក្នុងចំណោម៣១នាក់ ត្រូវជា៥១.៦១ភាគរយ។

- សាលារៀនមានវិន័យនិងសណ្តាប់ធ្នាប់ល្អនេះ អ្នកផ្តល់មតិចំនួន១១នាក់ក្នុងចំណោម ៣១នាក់ ត្រូវជា៣២.២៦ភាគរយ។

**ខ.ប៉ូលីស**

អ្នកផ្តល់សម្ភាសន៍មុខរបរជានគរបាល(ប៉ូលីស) មានចំនួន១០នាក់ក្នុងចំណោម១០១នាក់បើគិតជាភាគរយមានចំនួន ៩.៩០ភាគរយក្នុងចំនោមអ្នកផ្តល់សម្ភាសន៍ចំនួន១០១នាក់ តាមមតិយោបល់របស់គាត់ឆ្លើយនឹងសំណួរថាតើមូលហេតុអ្វីខ្លះ ដែលអ្នកយកកូនមករៀននៅសាលាមត្តេយ្យ៨មីនា? ពួកគាត់បានផ្តល់មតិយោបល់ជាច្រើនដូចខាងក្រោម៖

- សាលារៀនមានវិន័យនិងសណ្តាប់ធ្នាប់ល្អនេះ អ្នកផ្តល់មតិចំនួន០៤នាក់ ក្នុងចំណោម១០នាក់ ត្រូវជា៤០ភាគរយ។

- សាលារៀនស្តង់ដាររបស់រដ្ឋ នៅតាមឯកជនក៏រៀនតាមកម្មវិធីរបស់រដ្ឋយើងដែរ ហើយនៅទីនេះគ្រូសុទ្ធតែបានឆ្លងកាត់គរុកោសល្យត្រឹមត្រូវនេះ អ្នកផ្តល់មតិចំនួន០៦នាក់ ក្នុងចំណោម១០នាក់ ត្រូវជា៦០ភាគរយ។

- កូនអាចស្នាក់នៅទីនេះពេញមួយថ្ងៃ ចំណាយតិចតួច គុណភាពល្អអាចទទួលយកបាននេះ អ្នកផ្តល់មតិចំនួន០៤នាក់ ក្នុងចំណោម១០នាក់ ត្រូវជា៤០ភាគរយ។

- មានភាពងាយស្រួលនិងអំណោយផលនេះ អ្នកផ្តល់មតិចំនួន០៧នាក់ ក្នុងចំណោម១០នាក់ ត្រូវជា៧០ភាគរយ។

- សាលារៀនល្អ ក្មេងមានវិន័យ អ្នកផ្តល់មតិចំនួន០៧នាក់ ក្នុងចំណោម១០នាក់ ត្រូវជា៧០ភាគរយ។

- ការបង់ថ្លៃសិក្សារបស់កូនអាចទទួលយកបាន ល្មមសមរម្យនេះ អ្នកផ្តល់មតិចំនួន០៦នាក់ ក្នុងចំណោម១០នាក់ ត្រូវជា៦០ភាគរយ។

- កុមារ អាយុ៥ឆ្នាំ រៀននៅមត្តេយ្យកម្រិតមធ្យមនេះ អ្នកផ្តល់មតិចំនួន០១នាក់ ក្នុងចំណោម១០នាក់ ត្រូវជា១០ភាគរយ។

**គ.គ្រូបង្រៀន**

មុខរបររបស់អ្នកឆ្លើយសម្ភាសន៍ដែលជាគ្រូបង្រៀនមានចំនួន០៦នាក់ ក្នុងចំណោម ១០១នាក់ស្មើនឹង៥.៩៤ភាគរយ តាមមតិយោបល់របស់គាត់ឆ្លើយនឹងសំណួរថាតើមូលហេតុអ្វីខ្លះ ដែលអ្នកយកកូនមករៀននៅសាលាមត្តេយ្យ៨មីនា? ពួកគាត់បានផ្តល់មតិយោបល់ជាច្រើនដូចខាងក្រោម៖៖

- កូនៗរៀននៅទីនេះទាំងអស់ ដោយសារវាជាសាលារដ្ឋ មានគ្រូល្អ សុវត្ថិភាព ការយកចិត្តទុកដាក់ ក្នុងចំណុចនេះអ្នកតបសម្ភាសន៍ចំនួន០១នាក់ ក្នុងចំណោម៦នាក់ ត្រូវជា១៦.៦៧ភាគរយ។

- សប្បាយចិត្តណាស់បានកូនរៀននៅទីនេះ ដោយសារសាលារៀនល្អ មានក្មេងច្រើន កូនបានលេង ហើយអាចទៅបំពេញកិច្ចការខ្លួនឯង រួចចូលយកកូនទៅផ្ទះវិញស្រួល មានអ្នកផ្តល់សម្ភាសន៍ចំនួន៣នាក់ ក្នុងចំណោម៦នាក់ ស្មើនឹង៥០ភាគរយ។

- នៅជិតផ្ទះ សាលាមានរបង មានកន្លែងលេង គ្រូយកចិត្តទុកដាក់ចំពោះក្មេងៗល្អ ត្រង់ចំណុចនេះមានអ្នកតបសម្ភាសន៍ចំនួន២នាក់ ក្នុងចំនោម៦នាក់ ត្រូវជា៣៣.៣៣ភាគ រយ។

- គ្រូនៅទីនេះរាក់ទាក់ មានគរុកោសល្យ អ្នកតបសម្ភាសន៍ចំនួន៣នាក់ ក្នុងចំណោម៦ នាក់ ត្រូវជា៥០ភាគរយ។

- គុណភាពល្អ សាលារដ្ឋ បង់ថ្លៃជូនសាលាសមល្មម តាមលទ្ធភាពប្រាក់ខែមន្ត្រីរាជការ អ្នកតបសម្ភាសន៍ចំនួន២នាក់ ក្នុងចំនោម៦នាក់ ត្រូវជា៣៣.៣៣ភាគរយ។

**ឃ. ទាហាន**

អ្នកដែលមានមុខរបរជាទាហានគឺមានចំនួន០៧នាក់ ក្នុងចំណោម១០១នាក់ គិតជា ភាគរយ ៦.៩៣ភាគរយតាមមតិយោបល់របស់គាត់ឆ្លើយនឹងសំណួរថាតើមូលហេតុអ្វីខ្លះ ដែលអ្នកយកកូនមករៀននៅសាលាមត្តេយ្យ៨មីនា? ពួកគាត់បានផ្តល់មតិយោបល់ជាច្រើនដូចខាងក្រោម៖

- សាលារៀនមានវិន័យនិងសណ្តាប់ធ្នាប់ល្អ វិន័យ ត្រង់ចំណុចនេះមានផ្តល់សម្ភាសន៍ ជាទាហានចំនួន០២នាក់ ក្នុងចំណោម៧នាក់ ត្រូវជា២៨.៥៨ភាគរយ។

- សាលារដ្ឋ លើកស្ទួយ ស្រលាញ់អ្វីដែលរដ្ឋមាន គុណភាពល្អ គ្រូយកចិត្តទុកដាក់ដល់ការបង្រៀន លេងកំសាន្ត ចំណុចនេះអ្នកផ្តល់សម្ភាសន៍ចំនួន០១នាក់ ក្នុងចំណោម៧ នាក់ ត្រូវជា១៤.២៩ ភាគរយ។

- សាលានេះមានប្រវត្តិយូរមកហើយ បង្រៀនក្មេងៗបានច្រើន មានបទពិសោធន៍ល្អ ក្នុងការបង្រៀនក្មេង ត្រង់ចំណុចនេះអ្នកផ្តល់សម្ភាសន៍ចំនួន២នាក់ ក្នុងចំនោម៧នាក់ ត្រូវជា ២៨.៥៨ភាគរយ។

- ការបង់ថ្លៃសាលាសមរម្យដល់មន្ត្រីរាជការទូទៅ ជួយសម្រាលដល់ការងារស្មុគស្មាញរបស់យើង ព្រោះកូនស្នាក់នៅពេញមួយថ្ងៃ មានពេលទំនេរនិងធ្វើការខ្លួនឯងផង ត្រង់ចំណុចនេះមានអ្នកតបសម្ភាសន៍ចំនួន២នាក់ក្នុងចំណោម៧នាក់ ស្មើនឹង២៨.៥៨ភាគរយ។

**ង.អ្នករកស៊ី**

អ្នកតបសម្ភាសន៍ដែលមានមុខរបរជាអ្នករកស៊ី (អ្នកលក់ដូរ) មានចំនួន២៧នាក់ ក្នុងចំណោម ១០១នាក់ ត្រូវជា២៦.៧៣ភាគរយ តាមមតិយោបល់របស់គាត់ឆ្លើយនឹងសំណួរថាតើមូលហេតុអ្វីខ្លះ ដែលអ្នកយកកូនមករៀននៅសាលាមត្តេយ្យ៨មីនា? ពួកគាត់បានផ្តល់មតិយោបល់ជាច្រើនដូចខាងក្រោម៖

ថ្លៃសាលាគឺសមល្មមមានលទ្ធភាពជាងសាលាឯកជន មានចំនួនអ្នកតបសម្ភាសន៍ត្រង់ ចំណុចនេះចំនួន៩នាក់ ក្នុងចំណោម២៧នាក់ ត្រូវជា៣៣.៣៣ភាគរយ។

ជាសាលារដ្ឋដែលមានគ្រូស្រីៗចេះថ្នាក់ថ្នមក្មេងបានល្អ អ្នកតបសម្ភាសន៍ចំនួន៧នាក់ ក្នុងចំណោម២៧នាក់ ត្រូវជា២៥.៩២ភាគរយ។

សាលារៀននៅជិតផ្ទះ មានអ្នកសម្ភាសន៍ចំនួន ១៥នាក់ ក្នុងចំណោម២៧នាក់ ត្រូវជា ៥៥.៥៦ភាគរយ។

សាលារៀនល្បី បង្រៀនក្មេងល្អ មានអ្នកសម្ភាសន៍ចំនួន៦នាក់ក្នុងចំណោម២៧នាក់ ត្រូវជា២២.២២ភាគរយ។

សាលាមានកន្លែងស្នាក់នៅពេញមួយថ្ងៃ មានអ្នកតបសម្ភាសន៍ចំនួន១០នាក់ ក្នុងចំណោម២៧នាក់ ត្រូវជា ៣៧.០៣ភាគរយ។

**ច. អ្នករត់ម៉ូតូឌុប**

អ្នកតបសម្ភាសន៍ដែលមានមុខរបរជាអ្នករត់ម៉ូតូឌុបមានចំនួន០៨នាក់ ក្នុងចំណោម១០១នាក់ ត្រូវជា ៧.៩២ភាគរយ តាមមតិយោបល់របស់គាត់ឆ្លើយនឹងសំណួរថាតើមូលហេតុអ្វីខ្លះ ដែលអ្នកយកកូនមករៀននៅសាលាមត្តេយ្យ៨មីនា? ពួកគាត់បានផ្តល់មតិយោបល់ជាច្រើនដូចខាងក្រោម៖

បង់ថ្លៃសាលាធូរថ្លៃ មានអ្នកតបសម្ភាសន៍ចំនួន៧នាក់ ក្នុងចំនោម៨នាក់ ត្រូវជា ៨៧.៥ភាគរយ។

សាលាមានគ្រូដែលមានបទពិសោធន៍បង្រៀនល្អ មានអ្នកផ្តល់សម្ភាសន៍ចំនួន២នាក់ ក្នុងចំណោម៨នាក់ ត្រូវជា ២៥ភាគរយ។

សាលាមានសុវត្ថិភាព មានអ្នកឆ្លើយតបចំនួន៤នាក់ ក្នុងចំនោម៨នាក់ ត្រូវជា៥០ភាគរយ។

# ជំពូកទី ៥
# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

ឆ្លងតាមការស្រាវជ្រាវខាងលើបង្ហាញពីបរិបទនៃការអប់រំក្នុងតំបន់ និងពិភពលោក ដែលកំពុងយកចិត្តទុកដាក់ដល់ការអប់រំមនុស្សដែលបំពេញឱ្យសេចក្ដីត្រូវការផ្សារ សេដ្ឋកិច្ច និងឧស្សាហកម្មជាដើម។ ទន្ទឹមនឹងនោះ ការអប់រំមនុស្សឱ្យមានសីលធម៌ដើម្បីរស់នៅ ជាមួយគ្នា នាំឱ្យសង្គមមានសុខដុមរមនាជាមួយគ្នាវាជាការចាំបាច់បំផុតសម្រាប់ជាតិនីមួយៗ។ លទ្ធផលទាំងនេះវានឹងកើតមានឡើងប្រសិនបើឪពុកម្ដាយ អាណាព្យាបាលសម្រេច បញ្ជូនកុមារទាំងឡាយទៅកាន់សាលារៀន ដែលជាថ្នាលបណ្ដុះបណ្ដាលពួកគេ តម្រង់ទិសសតិ ស្មារតីពួកគេឱ្យរៀនរស់នៅ រៀនលេងជាមួយគ្នា ដោះស្រាយបញ្ហាជាមួយគ្នា រីករាយជាមួយគ្នាជាដើម។

ក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងយកចិត្តទុកដាក់ក្នុងកសាងឱ្យសាលាមត្តេយ្យបន្តទៀតទៅតាមសហគមន៍ដើម្បីឱ្យកុមារតូចៗជាពិសេសកុមារដែលមានអាយុចន្លោះពី ៣ឆ្នាំទៅ៥ឆ្នាំ បានចូលរៀនស្របតាមកម្មវិធីសិក្សារបស់សាលាមត្តេយ្យដែលនាយកដ្ឋានកុមារតូច និងនាយកដ្ឋានជំនាញផ្សេងៗទៀតបានរៀបចំឡើង ក្នុងស្មារតីបណ្ដុះនៅបំនិន ផ្សេងៗដូចជាបំនិនទំនាក់ទំនង បំនិនការលេងជាមួយគ្នា បំនិនកាយសម្បទាជាដើម។

ឪពុកម្ដាយអាណាព្យាបាលតែងតែចង់បាននូវការអប់រំមួយល្អ សម្រាប់ជួយកូនៗរបស់ពួកគាត់បានទទួលការសិក្សាទូលំទូលាយ រួមជាមួយសុវត្ថិភាពផងដែរ។ ការខ្វល់ខ្វាយ និងការ យកចិត្តទុកដាក់របស់ពួកគាត់គឺកម្លាំងចលករមួយក្នុងវិស័យអប់រំរបស់យើង បង្ហាញពីសញ្ញាវិជ្ជមាន និងការឈានឡើងនៅការរីកចម្រើនដោយមានការចូលរួមពីមាតាបិតា ក្នុងការស្វែងរកការអប់រំឱ្យកូនរបស់ខ្លួនចាប់តាំងពីវ័យកុមារ។

តាមរយៈប្រធានបទនៃការស្រាវជ្រាវ ***ទស្សនៈយល់ឃើញរបស់មាតាបិតាក្នុងការបញ្ជូនកូនទៅរៀននៅមត្តេយ្យសិក្សា អាយុ៣ឆ្នាំ ៤ឆ្នាំ និង៥ឆ្នាំ (ករណីសិក្សានៅភ្នំពេញ)*** បានលទ្ធផលដែលមានកម្រិតខ្ពស់

ដែលនៅក្នុងលក្ខណៈវិនិច្ឆ័យ ដូចជាតួនាទីភារកិច្ចរបស់ឪពុក ម្ដាយ ការទទួលបានចំណេះដឹង សុវត្ថិភាព និងពេលទំនេរ គឺទី១ តួនាទីភារកិច្ចរបស់ឪពុក ម្ដាយ ទី២ សុវត្ថិភាព។ តាមរយៈលទ្ធផលនេះបង្ហាញថា ឪពុកម្ដាយសម័យថ្មីនេះគឺគាត់ដឹង ច្បាស់ពីតួនាទីរបស់ខ្លួនការបញ្ជូនកូនទៅសាលារៀន ថែមទាំងយកចិត្តទុកដាក់ចំពោះការ សិក្សារបស់កូនខ្លាំង នេះជាសញ្ញាមួយវិជ្ជមានសម្រាប់ការបង្កើតឱ្យមានសាលាមត្តេយ្យសិក្សារដ្ឋឱ្យបានច្រើនបន្ថែមទៀត ដើម្បីជួយដោះស្រាយការខ្វល់ខ្វាយរបស់មាតាបិតាអាណាព្យាបាលក្នុងការស្វែងរកសាលានោះ។ មិនតែប៉ុណ្ណោះសាលាមត្តេយ្យទាំងនោះត្រូវ មានសុវត្ថិភាពផងដែរ ដូចករណីសិក្សាសាលាមត្តេយ្យ៨មីនា ដែលឪពុកម្ដាយរបស់កុមារទទួលស្គាល់ថាមានសុវត្ថិភាពដែលអាចទុកចិត្តបាន។ ទស្សនៈដែលថាការបញ្ជូនកូន តូចៗទៅសាលារៀនដោយផ្អែកលើកាតព្វកិច្ចជាឪពុកម្ដាយ និងគិតគូរដល់សុវត្ថិភាពរបស់កូន

ដែលជាទស្សនៈយល់ឃើញរបស់មាតាបិតាដែលបានបញ្ជូនកូនទៅរៀននៅសាលាមត្តេយ្យ៨មីនានៅរាជធានីភ្នំពេញ។

សរុបមកមូលហេតុដែលពួកគាត់បញ្ជូនកូនមកសាលាមត្តេយ្យ៨មីនា គឺដោយសារ សាលាមានសុវត្ថិភាព គុណភាពនៃការបង្រៀនល្អ គ្រូមានគរុកោសល្យច្បាស់លាស់ សាលា មានវិន័យនិងសណ្តាប់ធ្នាប់ល្អ សាលាមានកេរ្តិ៍ឈ្មោះល្អ សាលាមានបង្រៀនពេញមួយថ្ងៃ សាលាតម្រូវបង់ថ្លៃសមល្មម សាលានៅជិតផ្ទះ និងមានកន្លែងកំសាន្តជាដើម។

### ៥.២ សំណូមពរ

បន្ទាប់ពីបញ្ចប់ការស្រាវជ្រាវខាងលើ ក្នុងនាមខ្ញុំជាអ្នកស្រាវជ្រាវមានសំណូមពរមួយចំនួនដល់អាណាព្យាបាល មាតាបិតា លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលាមត្តេយ្យ ៨មីនា ដូចខាងក្រោមៈ

- ការអប់រំដោយក្តីស្រឡាញ់ គឺជាការអប់រំវិជ្ជមាន

-ការប្រើប្រាស់ពាក្យសម្តីចំពោះកុមារល្អ គឺជាការអប់រំដែលនឹងមានផលជះល្អក្នុងសង្គម

-មាតាបិតា អាណាព្យាបាល គប្បីជ្រើសរើសសាលាមត្តេយ្យសិក្សារដ្ឋឱ្យកូនចូលរៀន ដោយសារសាលារដ្ឋមានកម្មវិធីសិក្សារដ្ឋល្អ គ្រូមានគរុកោសល្យច្បាស់លាស់

-លោកគ្រូ អ្នកគ្រូ គប្បីទម្លាប់ឱ្យក្មេងៗតូចចេះមានរបៀប អនាម័យ

-គណៈគ្រប់គ្រងសាលាបន្តការលើកទឹកចិត្ត ដល់អ្នកគ្រូដែលបង្រៀននៅមត្តេយ្យសិក្សាពីជាការពិបាកណាស់ក្នុងការគ្រប់គ្រងលើកុមារតូចៗ

-មាតាបិតាអាណាព្យាបាលគប្បីបញ្ជូនកូន ដែលមានអាយុ៣ឆ្នាំដល់៥ឆ្នាំចូលរៀន ដើម្បីត្រៀមបឋមសិក្សា ជាគ្រឹះរបស់កូនក្នុងការរៀនបន្តទៅថ្នាក់លើទៀត។

### ៥.៣ ការសិក្សាស្រាវជ្រាវបន្ត

ការស្រាវជ្រាវរបស់នាងខ្ញុំខាងលើគឺគ្រាន់តែជាផ្នែកមួយ នៃការបញ្ជូនកូនអាយុពី៣ឆ្នាំ ទៅ៥ឆ្នាំទៅរៀននៅសាលាមត្តេយ្យ៨មីនាប៉ុណ្ណោះ គឺនៅមានច្រើនផ្នែកទៀតដូចជា កត្តាទីតាំងសាលារៀន កត្តាគ្រូ កត្តាកម្មវិធីសិក្សា បរិស្ថានសាលារៀន កេរ្តិ៍ឈ្មោះសាលារៀន និងមានកត្តាផ្សេងៗទៀតជាច្រើនដែលត្រូវសិក្សាបន្ត។

# ឯកសារយោង

## ក- ឯកសារភាសាខ្មែរ

១-ជួនណាត, *វចនានុក្រមខ្មែរ ភាគ១,* រោងពុម្ពអប់រំ, ឆ្នាំ២០០១
២-គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច,***ផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៤-២០១៨,*** សម័យប្រជុំថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤
៣-ក្រសួងអប់រំ យុវជន និងកីឡា, ***សេចក្តីព្រាងចុងក្រោយផែនការវិស័យយុទ្ធសាស្ត្រអប់រំឆ្នាំ២០១៩-២០២៣,*** ខែ ឧសភា ឆ្នាំ២០១៩
៤- World Vision, ការអប់រំ ***គោលនយោបាយសង្ខេបឆ្នាំ២០១៧,*** បោះពុម្ព២០១៧
*៥*-នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ***ទំនាក់ទំនងរវាងសាលារៀននិងសហគមន៍,*** ឆ្នាំ២០០៤
៦-នាយកដ្ឋានអប់រំកុមារតូច, ***កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ,*** ឆ្នាំ២០១៨
៧-នាយកដ្ឋានអប់រំកុមារតូច, ***ការគ្រប់គ្រងតាមស្តង់ដាគុណភាព,*** ឆ្នាំ២០១៦
៨-នាយកដ្ឋានអប់រំកុមារតូច, ***របាយការណ៍បូកសរុបលទ្ធផលការងារអប់រំកុមារតូចឆ្នាំសិក្សា ២០១៧-២០១៨ និងលើកទិសដៅឆ្នាំសិក្សា២០១៨-២០១៩,*** ឆ្នាំ២០១៩
៩-ខ្មៅសាវន ប៉ាន់វុត្ថា, ***ប្រវត្តិទស្សនវិជ្ជា,*** បោះពុម្ពឆ្នាំ២០១៧
១០-គន្ធ ឱមសាម៉េន,ប្រវត្តិទស្សនៈសាសនា សីលធម៌ នយោបាយ, ទំ.១២-១៧, ឆ្នាំ២០០៥
១១- ស៊ន សំណាង,***ឯកសារជំនួយស្មារតីសំរាប់សិក្សាប្រវត្តិសាស្ត្រកម្ពុជា***, បោះពុម្ពឆ្នាំ១៩៨៧-៨៨
១២-នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ***ការគ្រប់គ្រងដឹកនាំសាលារៀន***, ១៨ មិថុនា ២០១៩
១៣-ជឿន សាវ៉ាន់, ***ទស្សនវិជ្ជាអប់រំ,*** ឆ្នាំ២០១៧

## ខ-ភាសាបរទេស

១៤- JOHN M. KOLLER. PATRICIA JOYCE KOLL, *ASIAN PHILOSOPHY*,3RD EDITION, 1998
១៥- Barnes, J. (1982) *Aristotle*, Oxford: Oxford University Press. An lively and concise introduction to Aristotle's work.
១៦- Jaeger, W. W. (1948) *Aristotle*, Oxford: Oxford University Press. Pretty much the standard work.
១៧- Brickhouse, Thomas C., and Nicholas D. Smith. 2000 The Philosophy of Socrates. Boulder, Colo.: Westview Press
១៨- Brickhouse, Thomas C., and Nicholas D. Smith. 1994 Plato's Socrates. New York: Oxford University Press
១៩- Benson, Hugh C., 2000 Socratic Wisdom. New York: Oxford University Press
២០- Easton, Stewart C., 1966 The Western Heritage. New York: Holt Rhinehart & Winston, Inc.

២១- Noonan, John P., 1957 General Metaphysics. Chicago, Ill. Loyola University Press

គ.Websites

២២- www.philosophypages.com/hy/29.htm#origins

២៣- www.2020site.org/socrates

២៤-www.san.beck.org/c&s-compared.htm#6

២៥-WWW.google.com/Philosophy of child education by Plato

២៦-WWW.google.com/Philosophy of child education by Aristotle

២៧-WWW.google.com/Philosophy of child education by J.J Rousseau

២៨-WWW.google.com/Philosophy of child education by Montessori

# ឧបសម្ព័ន្ធទី១
# កម្រងសំណួរ

**ព្រះរាជាណាចក្រកម្ពុជា**

វិទ្យាស្ថានជាតិអប់រំ **ជាតិ សាសនា ព្រះមហាក្សត្រ**

**កម្រងសំណួរសម្ភាសន៍មាតា បិតាសិស្ស**

**ផ្នែកទី១ ៖ ព័ត៌មានទូទៅ**

១-ភេទ ក. ☐ ស្រី ខ. ☐ ប្រុស

២-អាយុ ក. ☐ ២០ឆ្នាំ-៣០ឆ្នាំ ខ. ☐ ៣១ឆ្នាំ-៤០ឆ្នាំ គ. ☐ លើសពី៤១ឆ្នាំ

ឃ. ☐ ផ្សេង..................

៣-មុខរបរ ក. ☐ មេផ្ទះ ខ. ☐ គ្រូបង្រៀន គ ☐ ប៉ូលីស

ឃ. ☐ ផ្សេងៗ..................

៤-កម្រិតវប្បធម៌

ក. ☐ បឋមសិក្សា ខ. ☐ មធ្យមសិក្សាបឋមភូមិ

គ. ☐ មធ្យមសិក្សាទុតិយភូមិ ឃ. ☐ ផ្សេងៗ.....................

ផ្នែកទី២ កម្រងសំណួរ

| **តួនាទីភារកិច្ចរបស់ឪពុកម្តាយ** | ឯកភាព | មិនឯកភាព | គំនិតផ្សេងៗ |
|---|---|---|---|
| ១-ការបញ្ជូនកូនចូលរៀនជាតួនាទីរបស់ឪពុកម្តាយ | | | |
| ២-ឪពុកម្តាយត្រូវយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូន | | | |
| ៣-ការបញ្ជូនកូនចូលរៀនគឺធ្វើឱ្យកូនមានទីពំនឹងសម្រាប់អនាគត | | | |
| ៤-ឪពុកម្តាយត្រូវតែចាត់ទុកការសិក្សារបស់កូនជាភាពសំខាន់ | | | |
| **ទទួលបានចំណេះដឹង** | ឯកភាព | មិនឯកភាព | គំនិតផ្សេងៗ |

| | | | |
|---|---|---|---|
| ៥-ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះអាន ចេះសរសេរ | | | |
| ៦-ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះ សីលធម៌ក្នុងការរស់នៅ | | | |
| ៧-ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះអត់ ឱន និងអធ្យាស្រ័យឱ្យគ្នា | | | |
| ៨-ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះ ទំនាក់ទំនង | | | |
| ៩-ការបញ្ជូនកូនទៅសាលាឱ្យគាត់ចេះ លេងកំសាន្ត | | | |
| **សុវត្ថិភាព** | **ឯកភាព** | **មិនឯកភាព** | **គំនិតផ្សេងៗ** |
| ១០-ការរៀននៅសាលាមត្តេយ្យផ្ទះមិនមាន សុវត្ថិភាពដល់កូន | | | |
| ១១-មានភាពកក់ក្តៅមិនសូវបារម្ភ | | | |
| ១២-សាលាមានការយកចិត្តទុកដាក់ដល់ សុវត្ថិភាពសិស្សបានល្អ | | | |
| **ពេលទំនេរ** | **ឯកភាព** | **មិនឯកភាព** | **គំនិតផ្សេងៗ** |
| ១៣-មានពេលប្រកបរបររកស៊ី | | | |
| ១៤-មានពេលបន្តការសិក្សា | | | |
| ១៥-មានពេលវេលាគ្រប់គ្រាន់ក្នុងការ បំពេញការងារ | | | |

# ឧបសម្ព័ន្ធទី២
# រូបថតសកម្មភាពទាក់ទងការប្រមូលទិន្នន័យ











ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៨៤៤ អយក.វិស

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៨១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
-សាលារាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីជូនជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
"ដើម្បីជ្រាបជាព័ត៌មាន"
-កាលប្បវត្តិ
-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៨៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
លេខៈ ១១៥ ទជអ.ឥក

## លិខិតឧទ្ទេសនាម

**គោលបំណង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម នាមខ្លួន | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡេងទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអើល | ប | ខេត្តស្វាយរៀង |
| ៣ | យ៉េន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណារី | ប | រាជធានីភ្នំពេញ |
| ៥ | ផែត រ៉ាវុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ធន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ចាយ បូទិ | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា គត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណាក់ | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម តំនុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៊ុម សុគា | ប | ខេត្តកណ្តាល |
| ១៦ | ធុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ថូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

1

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ ស្មៀ | ស | ខេត្តត្បូងឃ្មុំ |
| ២០ | កោត តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្ដិ | ប | ខេត្តព្រៃវែង |
| ២៦ | សន ភាពរស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វឿស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុខិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈឿន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហ៊ែល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្ដរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ុន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ុំ សុធី | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ុម ស៊ីរីវុធ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធី | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខន្ធរា

**កន្លែងទទួល**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ
-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ
"ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៩៦២៤ អយក. ប្រក

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យត់ ឌុំយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **លាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ខយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុមុណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៦៣១ **អយក.** ក្រ
**(ការសម្គាល់)**

## លិខិតឧទ្ទេសនាម

**យោង ៖**-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្តាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប តេនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម ភ័ន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង ភសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៦២៩ **អយក.** ប្រក

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត ទូវ រ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក នី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារុំម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត នី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈុក ច័ន្ទតាយ៉ា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី វេង៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាគារលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ៦៧៣ / ២១០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh